# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២៩-៨-២០០៩ -ព្រះរាជក្រម នស/រកម/០៨០៩/០១៧ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន ៦៥៣៥


### ២~ព្រះរាជក្រឹត្យ


២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៦០ ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ០២ រូប ពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ មកក្នុងក្របខ័ណ្ឌនគរបាលជាតិ ក្រសួងមហាផ្ទៃ និង បំពាក់ឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ដោយរក្សាឋានៈ និង មុខងារដដែលនៅក្នុង អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៦៥៩៦

២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៦១ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោក និង លោកស្រី ចំនួន ០៣ រូប ៦៥៩៧

២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៦២ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះកងកម្លាំងប្រដាប់អាវុធ,លោក និង លោកស្រី ចំនួន ៣០ រូប ៦៥៩៨

២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៦៣ ស្តីពីការតែងតាំងឯកឧត្តម **គីម គន់** ជាទីប្រឹក្សា ក្រសួងសាធារណការ និង ដឹកជញ្ជូន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៦៦០០

២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៦៤ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ជូនលោកវរសេនីយ៍ឯក **ជៀប ស៊ុរិយា** ៦៦០១

២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៦៥ ស្តីពីការតែងតាំងឧត្តមសេនីយ៍ទោ **លន់ សុខុន** ជានាយកវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ នៃគ្រឹះស្ថានសាធារណៈ រដ្ឋបាល ក្រសួងការពារជាតិ មានឋានៈស្មើ អគ្គនាយក ៦៦០២

២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៦៦ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និង ជនបទ ៦៦០៣

# II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ស្តីពីការបង្កើតតំបន់ព្រៃការពារ និង អភិរក្សជីវៈចម្រុះ "សីមា" ខេត្តមណ្ឌលគិរី និង ខេត្តក្រចេះ ៦៦០៩
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤៤ អនក្រ.បក ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ៦៦១៦
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤៥ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦៦១៨
១៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៦២០
១៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦៦២១
១៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦៦២២
១៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦៦២៣
១៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៦២៤
១៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣៤០ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយសស្ថាបនាជាតិ ៦៦២៥
១៩-៨-២០០៩ -អនុក្រឹត្យលេខ ១៣៤១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៦៦២៦
១៩-៨-២០០៩ -អនុក្រឹត្យលេខ ១៣៤២ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយស ៦៦២៧

## ២-សេចក្តីសំរេច

០២-៩-២០០៩ -សេចក្តីសំរេចលេខ ៩៥ សសរ ស្តីពីការតែងតាំងសមាសភាព និង ទីប្រឹក្សាជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក ៦៦៤៩

# ព្រះរាជក្រម

នស/រកម/០៨០៩/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហូរហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើ
# កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន ដែលធ្វើនៅ ឆាអាម ព្រះរាជាណាចក្រថៃឡង់ដ៍ នាថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៩០៤.៨៤៦ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា** លេខ: ៤២៦ ច.ល

**គាត ឈន់** ចម្លងចែក

ភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន

**រដ្ឋា**ភិបាលនៃប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រទេសសមាជិកនៃប្រជាជាតិអាស៊ីអគ្នេយ៍ (ដែលហៅថា " បណ្តាប្រទេសសមាជិក") ឬតែមួយហៅថា "ប្រទេសសមាជិក"):

**ដោយរំលឹកឡើងវិញ** នូវសេចក្តីសម្រេចរបស់ប្រមុខដឹកនាំ ដើម្បីបង្កើតសហគមន៍អាស៊ាន មានសសរស្តម្ភបីគឺ សហគមន៍នយោបាយ-សន្តិសុខអាស៊ាន (APSC) សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងសហគមន៍សង្គម-វប្បធម៌អាស៊ាន (ASCC) ដែលមានចែងក្នុងសេចក្តីប្រកាសអាស៊ាន Concord II ដែលបានចុះហត្ថលេខានៅថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៣ នៅបាលី ប្រទេសឥណ្ឌូណេស៊ី និងនៅក្នុងធម្មនុញ្ញអាស៊ានដែលបានចុះហត្ថលេខានៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នៅប្រទេសសឹង្ហបុរី

**ប្តេជ្ញា** ធ្វើឱ្យសម្រេចគោលដៅក្នុងការបង្កើតអាស៊ានជាទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយដែលមានចរិកលក្ខណៈនៃសេរីកម្មទំនិញ សេវា វិនិយោគ ពលកម្មជំនាញ និងធ្វើឱ្យមានសេរីកម្មជាងមុននៃលំហូរទុនដូចមានគ្រោងទុកដោយធម្មនុញ្ញអាស៊ាន និងប្រកាសស្តីពីផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលបានចុះហត្ថលេខាដោយប្រមុខអាស៊ាន នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នៅប្រទេសសឹង្ហបុរី

**ដោយទទួលស្គាល់** សមិទ្ធិផលសំខាន់ៗ និងការចូលរួមចំណែកទៅនឹងបណ្តាកិច្ចព្រមព្រៀង និងឧបករណ៍សេដ្ឋកិច្ចអាស៊ានដែលមានស្រាប់នៅក្នុងវិស័យផ្សេងៗ ក្នុងការសម្របសម្រួលលំហូរទំនិញដោយសេរីនៅក្នុងតំបន់ រួមទាំងកិច្ចព្រមព្រៀងស្តីពីការរៀបចំពាណិជ្ជកម្មអនុគ្រោះអាស៊ាន (១៩៧៧) កិច្ចព្រមព្រៀងស្តីពីកម្មវិធីអនុគ្រោះពន្ធរួមសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (១៩៩២) កិច្ចព្រមព្រៀងអាស៊ានស្តីពីគយ (១៩៩៧) កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការរៀបចំការទទួលស្គាល់គ្នាទៅវិញទៅមក (១៩៩៨) កិច្ចព្រមព្រៀងក្របខ័ណ្ឌ អ៊ី-អាស៊ាន (២០០០) ពិធីសារស្តីពីការអនុវត្តឈ្មោះទំនិញរួមអាស៊ាន (២០០៣) កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានសម្រាប់សមាហរណកម្មវិស័យអាទិភាព (២០០៤) កិច្ចព្រមព្រៀងសម្រាប់ការបង្កើត និងអនុវត្តច្រកអាស៊ានតែមួយ (២០០៥)

**ដោយប្រាថ្នា** ធ្វើឱ្យទៅមុខដោយការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញទូលំទូលាយអាស៊ានដែលស្ថាបនាឡើងផ្អែកលើការសន្យាក្រោមកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានដែលមានស្រាប់ ដើម្បីផ្តល់នូវក្របខ័ណ្ឌច្បាប់ដើម្បីធ្វើឱ្យសម្រេចសេរីកម្មលំហូរទំនិញនៅក្នុងតំបន់

**ដោយជឿជាក់ថា** កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញទូលំទូលាយអាស៊ាន អាចបន្ថយជាអប្បបរមារបាំង និង ជំរុញការផ្សារភ្ជាប់សេដ្ឋកិច្ចក្នុងចំណោមបណ្តាសមាជិក បន្ថយតម្លៃនៃការធ្វើពាណិជ្ជកម្ម បង្កើនពាណិជ្ជកម្ម វិនិយោគ និងប្រសិទ្ធិភាពសេដ្ឋកិច្ច បង្កើតទីផ្សារធំជាង ព្រមជាមួយនឹងកាលានុវត្តភាពប្រសើរជាង និង សេដ្ឋកិច្ចមាត្រដ្ឋានធំជាង សម្រាប់ការធ្វើពាណិជ្ជកម្មរបស់បណ្តាប្រទេសសមាជិក និងបង្កើត និងរក្សាភាព តំបន់វិនិយោគប្រកបដោយភាពប្រកួតប្រជែង

**ដោយទទួលស្គាល់ថា** កម្រិតខុសគ្នានៃការអភិវឌ្ឍសេដ្ឋកិច្ចរវាង និងក្នុងចំណោមបណ្តាប្រទេសសមាជិក និង សេចក្តីត្រូវការដើម្បីបំបាត់គម្លាតនៃការអភិវឌ្ឍ និងសម្រួលការចូលរួមកាន់តែច្រើនឡើងរបស់ប្រទេស សមាជិក ជាពិសេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានតាមរយៈផ្តល់ ភាពទន់ភ្លន់ និងសហប្រតិបត្តិការបច្ចេកទេស និងអភិវឌ្ឍន៍

**ដោយទទួលស្គាល់** ថែមទៀត បទប្បញ្ញត្តិនៃសេចក្តីប្រកាសរដ្ឋមន្ត្រីរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពី វិធានការអនុគ្រោះដល់ប្រទេសអភិវឌ្ឍន៍តិចតួច

**ដោយទទួលស្គាល់ថា** តួនាទីសំខាន់ និងការចូលរួមចំណែករបស់វិស័យពាណិជ្ជកម្មក្នុងការបង្កើនពាណិជ្ជកម្ម និងវិនិយោគក្នុងចំណោមប្រទេសសមាជិក និងតម្រូវការជំរុញ និងសម្រួលបន្ថែមការចូលរួមតាមរយៈ សហគមន៍ពាណិជ្ជកម្មអាស៊ានផ្សេងៗ ក្នុងការធ្វើឱ្យសម្រេចនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន និង

**ដោយទទួលស្គាល់ថា** តួនាទីនៃបណ្តាកិច្ចសម្រុះសម្រួលពាណិជ្ជកម្មតំបន់ ដូចជាកត្តាលីករក្នុងការជំរុញ សេរីកម្មពាណិជ្ជកម្មនៅក្នុងតំបន់ និងពិភពលោក និងការសម្រួលពាណិជ្ជកម្ម និងដូចជាមូលដ្ឋានគ្រឹះក្នុង ក្របខ័ណ្ឌនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគី

បានព្រមព្រៀងដូចតទៅនេះ :

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីសម្រេចបាននូវសេរីកម្មលំហូរទំនិញនៅក្នុងអាស៊ាន ដូច ជាមធ្យោបាយមូលដ្ឋានក្នុងការបង្កើតទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយសម្រាប់សមាហរណកម្មសេដ្ឋកិច្ច

នៅក្នុងតំបន់ឱ្យស៊ីជម្រៅជាង ដើម្បីឈានឆ្ពោះទៅរកការសម្រេចសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) នៅឆ្នាំ ២០១៥។

**មាត្រា ២.- និយមន័យទូទៅ**

១. សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែបរិបទតម្រូវផ្សេងពីនេះ :

(ក) **អាស៊ាន** មានន័យថា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលរួមមាន ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

(ខ) **អាជ្ញាធរគយ** មានន័យថា អាជ្ញាធរមានសមត្ថកិច្ចដែលទទួលខុសត្រូវក្រោមច្បាប់របស់ប្រទេសសមាជិកសម្រាប់ការគ្រប់គ្រងច្បាប់គយ។

(គ) **ពន្ធគយ** មានន័យថា ពន្ធគយ ឬពន្ធនាំចូល និងបន្ទុកណាមួយដែលត្រូវទារ ពាក់ព័ន្ធដល់ការនាំចូលទំនិញ ប៉ុន្តែមិនដាក់បញ្ចូលនូវ :

(i) បន្ទុកណាមួយដែលស្មើទៅនឹងពន្ធក្នុងស្រុកដែលបានដាក់ឱ្យជាប់ពន្ធស្របតាមបទប្បញ្ញត្តិនៃកថាខ័ណ្ឌ ២ មាត្រា III នៃ GATT ១៩៩៤ ដោយគោរពទៅតាមទំនិញដូចនឹងទំនិញក្នុងស្រុក ឬចំពោះទំនិញដែលទំនិញនាំចូលត្រូវបានផលិតទាំងស្រុង ឬផ្នែកណាមួយ។

(ii) ពន្ធលើការលក់បង្ខូចតម្លៃ និងពន្ធរក្សាតុល្យភាព អនុវត្តស្របទៅនឹងបទប្បញ្ញត្តិនៃមាត្រា VI នៃ GATT ១៩៩៤ កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VI នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីវិធានការឧបត្ថម្ភធន និងរក្សាតុល្យភាពនៅក្នុងឧបសម្ព័ន្ធ 1A នៃកិច្ចព្រមព្រៀង WTO ឬ។

(iii) កម្រៃ និងបន្ទុកណាមួយសមាមាត្រនឹងតម្លៃសេវាដែលបានផ្តល់។

(ឃ) **ច្បាប់គយ** មានន័យថា បណ្តាច្បាប់ និងបទបញ្ជាដែលគ្រប់គ្រង និងប្រតិបត្តិដោយអាជ្ញាធរគយនៃប្រទេសសមាជិកនីមួយៗ ពាក់ព័ន្ធទៅនឹងការនាំចូល នាំចេញ ឆ្លងកាត់ ផ្ទេរ និងរក្សាទំនិញ ដែលទាំងអស់នោះពាក់ព័ន្ធទៅពន្ធគយ បន្ទុក និងពន្ធអាករផ្សេងៗ ទៀត ឬទៅ

និងការហាមឃាត់ ការដាក់កម្រិត និងការត្រួតពិនិត្យដូចគ្នាអំពីចលនានៃទំនិញដែលត្រូវត្រួតពិនិត្យនៅពេលឆ្លងកាត់ព្រំដែនគយនៃប្រទេសសមាជិកនីមួយៗ។

(ង) **តម្លៃគិតពន្ធគយនៃទំនិញ** មានន័យថា តម្លៃនៃទំនិញសម្រាប់គោលបំណងនៃការទារពន្ធតាមពន្ធគយផ្អែកលើតម្លៃទំនិញនាំចូល។

(ច) **ថ្ងៃ** មានន័យថា បណ្តាថ្ងៃនៃប្រតិទិន រាប់បញ្ចូលទាំងចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក។

(ឆ) **ការរឹតត្បិតលើការប្តូររូបិយប័ណ្ណ** មានន័យថា វិធានការដែលអនុវត្តដោយសមាជិកក្នុងទម្រង់នៃការរឹតត្បិត និងនីតិវិធីរដ្ឋបាលដទៃក្នុងការប្តូររូបិយប័ណ្ណដែលប៉ះពាល់ដល់ការរឹតត្បិតពាណិជ្ជកម្ម។

(ជ) GATT មានន័យថា កិច្ចព្រមព្រៀងពាណិជ្ជកម្មទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ ១៩៩៤ រួមបញ្ចូលទាំងសេចក្តីកំណត់ និងបទប្បញ្ញត្តិបន្ថែមរបស់វាដែលមាននៅក្នុងឧបសម្ព័ន្ធ ១ A នៃ កិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោក។

(ឈ) **ប្រព័ន្ធចុះសម្រុងគ្នា ឬ HS** មានន័យថា ដែលមានចែងក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាអន្តរជាតិស្តីពីប្រព័ន្ធលេខកូដ និងការបរិយាយទំនិញចុះសម្រុងគ្នា រួមទាំងវិសោធនកម្មណាក៏ដោយដែលបានអនុម័ត និងអនុវត្តដោយប្រទេសសមាជិក ទៅតាមច្បាប់ក្នុងស្រុករៀងៗ ខ្លួន។

(ញ) MFN មានន័យថា ប្រព្រឹត្តិកម្មប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតនៅក្នុង WTO។

(ដ) **របាំងមិនមែនពន្ធ** មានន័យថា បណ្តាវិធានការមិនមែនពន្ធ ដែលជាក់ស្តែងហាមឃាត់ ឬរឹតត្បិតការនាំចូល ឬការនាំចេញទំនិញនៅក្នុងបណ្តាប្រទេសសមាជិក។

(ឋ) **ទំនិញដើមកំណើត** មានន័យថា ទំនិញមានលក្ខណៈពេញលេញថាមានដើមកំណើតនៅក្នុងប្រទេសសមាជិកមួយ ដូចដែលមានចែងនៅក្នុងបណ្តាបទប្បញ្ញត្តិនៃជំពូក ៣។

(ឌ) **ប្រព្រឹត្តិកម្មពន្ធអនុគ្រោះ** មានន័យថា សម្បទានពន្ធចំពោះទំនិញដើមកំណើតដូចដែលមានចែងដោយអត្រាពន្ធដែលអាចអនុវត្តបានប្រើក្រោមកិច្ចព្រមព្រៀងនេះ។

(ឍ) **ការដាក់កម្រិតបរិមាណ** មានន័យថា វិធានការដែលមានបំណងហាមឃាត់ ឬដាក់កម្រិតបរិមាណនៃពាណិជ្ជកម្មជាមួយបណ្តាសមាជិកដទៃ ទោះបីជាធ្វើតាមរយៈកូតា អាជ្ញាប័ណ្ណ ឬវិធានការដទៃដែលមានប្រសិទ្ធិភាពប្រហាក់ប្រហែល រួមទាំងវិធានការរដ្ឋបាល និងបណ្តាតម្រូវការដែលដាក់កម្រិតពាណិជ្ជកម្ម។

(ន) កិច្ចព្រមព្រៀងនេះ ឬ ATIGA មានន័យថា កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ។

(ប) WTO មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក និង ។

(ផ) កិច្ចព្រមព្រៀង WTO មានន័យថា កិច្ចព្រមព្រៀងម៉ារ៉ាកេសបង្កើតអង្គការពាណិជ្ជកម្មពិភពលោក បានធ្វើនៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៤ និងបណ្តាកិច្ចព្រមព្រៀងផ្សេងទៀត ដែលបានចរចាក្រោមកិច្ចព្រមព្រៀងនេះ ។

២. នៅក្នុងកិច្ចព្រមព្រៀងនេះ ពាក្យទាំងអស់ជាឯកវចនៈត្រូវបញ្ចូលទាំងពហុវចនៈ និងពាក្យទាំងអស់ជាពហុវចនៈត្រូវបញ្ចូលទាំងឯកវចនៈ លើកលែងតែបានបញ្ជាក់ផ្សេងពីនេះនៅក្នុងបរិបទ ។

## មាត្រា ៣.- ចំណាត់ថ្នាក់ទំនិញ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ចំណាត់ថ្នាក់ទំនិញសម្រាប់ពាណិជ្ជកម្មរវាង និងក្នុងចំណោមបណ្តាប្រទេសសមាជិក ត្រូវតែអនុលោមទៅតាមអាស៊ាននាមវលីតារាងពន្ធចុះសម្រុង (AHTN) ដូចដែលមានចែងនៅក្នុងពិធីសារគ្របដណ្តប់ការអនុវត្តនៃអាស៊ាននាមវលីតារាងពន្ធចុះសម្រុង ដែលបានចុះហត្ថលេខានៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ និងវិសោធនកម្មណាមួយនៅក្នុងនោះ ។

## មាត្រា ៤.- ទំនិញគ្របដណ្តប់

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះផលិតផលទាំងអស់ក្រោមអាស៊ាននាមវលីតារាងពន្ធចុះសម្រុង (AHTN) ។

## មាត្រា ៥.- ប្រព្រឹត្តិកម្មប្រជាជាតិអនុគ្រោះបំផុត

ចំពោះពន្ធនាំចូលក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ប្រសិនបើប្រទេសសមាជិកមួយចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយជាមួយប្រទេសមិនមែនជាសមាជិក ដែលការសន្យាមានលក្ខណៈអនុគ្រោះជាង ដូចដែលមានចែងនៅក្រោមកិច្ចព្រមព្រៀងនេះ សមាជិកដទៃមានសិទ្ធិស្នើសុំការចរចាជាមួយសមាជិកនោះ ដើម្បីស្នើបញ្ចូលប្រព្រឹត្តិកម្មនោះ ដែលការអនុគ្រោះមិនតិចជាងការអនុគ្រោះដែលបានផ្តល់ឱ្យនៅក្រោមកិច្ចព្រមព្រៀងនោះ ។ ការសម្រេចផ្តល់ភាពអនុគ្រោះពន្ធនេះត្រូវផ្អែកលើមូលដ្ឋានឯកតោភាគី ។ ការផ្តល់នៃភាពអនុគ្រោះនេះ ត្រូវជូនដល់បណ្តាប្រទេសសមាជិកទាំងអស់ ។

**មាត្រា ៦.- ប្រព្រឹត្តិកម្មជាតិស្តីពីពន្ធ និង បទបញ្ញាក្នុងស្រុក**

សមាជិកនីមួយៗ ត្រូវផ្តល់ប្រព្រឹត្តិកម្មជាតិចំពោះទំនិញរបស់បណ្តាសមាជិកដទៃ ស្របទៅតាម មាត្រា III នៃ GATT ១៩៩៤។ ក្នុងន័យនេះ មាត្រា III នៃ GATT ១៩៩៤ ត្រូវបានបញ្ចូល និងជាផ្នែកមួយ នៃកិច្ចព្រមព្រៀងនេះ *ដូចដែលបានកែប្រែ*។

**មាត្រា ៧.- កម្រៃ និងបន្ទុកនានាដែលពាក់ព័ន្ធដល់ការនាំចូល និងនាំចេញ**

១. ប្រទេសសមាជិកនីមួយៗ ត្រូវធានាថា យោងទៅតាមមាត្រា VIII.1 នៃ GATT ១៩៩៤ កម្រៃ និងបន្ទុកនានា ទោះជាប្រភេទណាក៏ដោយ (ផ្សេងក្រៅពីពន្ធនាំចូល និងនាំចេញ បន្ទុកនានាដែលមាន តម្លៃស្មើនឹងពន្ធក្នុងស្រុក ឬបន្ទុកក្នុងស្រុកដទៃទៀតដែលអនុវត្តស្របទៅនឹងមាត្រា III.2 នៃ GATT ១៩៩៤ និង ពន្ធលើការលក់បង្ខូចតម្លៃ និងពន្ធរក្សាតុល្យភាព) ដែលបានដាក់ ឬទាក់ទងនឹងការនាំចូល និងនាំចេញ ត្រូវបានកំណត់ប្រហាក់ប្រហែលទៅនឹងតម្លៃសេវាផ្តល់ និងមិនមែនជាការការពារ ដោយប្រយោលចំពោះ ទំនិញក្នុងស្រុក ឬការយកពន្ធលើការនាំចូល ឬនាំចេញសម្រាប់គោលបំណងសារពើពន្ធ។

២. ប្រទេសសមាជិកនីមួយៗ ត្រូវផ្សព្វផ្សាយជាបន្ទាន់នូវសេចក្តីលំអិតនៃកម្រៃ និងបន្ទុក ពាក់ព័ន្ធដល់ការនាំចូល និងនាំចេញ ហើយត្រូវធ្វើឱ្យមានព័ត៌មានទាំងនោះនៅលើអ៊ីនធឺណែត។

**មាត្រា ៨.- ការលើកលែងទូទៅ**

ស្ថិតក្រោមល័ក្ខខ័ណ្ឌដែលតម្រូវថាវិធានទាំងនោះ មិនអាចអនុវត្តតាមរបៀបដែលអាចជា មធ្យោបាយអាជ្ញាកណ្តាល ឬរើសអើងតាមអំពើចិត្ត និងមិនអាចដោះសារបានក្នុងចំណោមប្រទេសសមាជិក នៅក្រោមល័ក្ខខ័ណ្ឌដូចគ្នា ឬការរឹតត្បិតបែបលាក់បំបាំងលើពាណិជ្ជកម្មអន្តរជាតិ គ្មានអ្វីនៅក្នុងកិច្ច ព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីរារាំងការអនុម័ត ឬការអនុវត្តន៍ដោយប្រទេសសមាជិកនូវវិធានការៈ

(ក) ចាំបាច់ដើម្បីការពារសីលធម៌សាធារណៈ។

(ខ) ចាំបាច់ដើម្បីការពារជីវិត ឬសុខភាពមនុស្ស សត្វ និងរុក្ខជាតិ។

(គ) ពាក់ព័ន្ធដល់ការនាំចូល ឬនាំចេញមាស ឬប្រាក់។

(ឃ) ចាំបាច់ដើម្បីធានាការអនុវត្តច្បាប់ ឬបទបញ្ជាដែលមិនសមស្របទៅនឹងបទប្បញ្ញត្តិនៃកិច្ច ព្រមព្រៀងនេះ រួមទាំងច្បាប់ ឬបទបញ្ជា ដែលពាក់ព័ន្ធទៅនឹងការប្រតិបត្តិការគយ ការប្រតិបត្តិ

ឯកាធិភាពដែលប្រតិបត្តិនៅក្រោមកថាខណ្ឌ ៤ នៃមាត្រា II និងមាត្រា XVII នៃ GATT ១៩៩៤ ការការពារប៉ាតង់ ផ្លាកសញ្ញា និងកម្មសិទ្ធិបញ្ញា និងការការពារនៃការអនុវត្តខុស ។

(ង) ទាក់ទងទៅនឹងផលិតផលនៃពលកម្មពន្ធនាគារ ។

(ច) ដាក់ឱ្យជាប់ពន្ធសម្រាប់ការពារសម្បត្តិសិល្បៈជាតិ តម្លៃប្រវត្តិសាស្ត្រ ឬផ្នែកបុរាណវិទ្យា ។

(ឆ) ពាក់ព័ន្ធទៅនឹងការថែរក្សាធនធានធម្មជាតិដែលជិតបាត់បង់ ប្រសិនបើវិធានការទាំងនោះត្រូវបានធ្វើប្រកបដោយប្រសិទ្ធិភាពជាមួយនឹងការដាក់កម្រិតទៅលើផលិតផល ឬការប្រើប្រាស់ ។

(ជ) ធ្វើដោយអនុលោមទៅតាមកាតព្វកិច្ចនៃកិច្ចព្រមព្រៀងទំនិញអន្តររដ្ឋាភិបាលដែលអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលបានដាក់ជូន WTO និងមិនត្រូវបានអនុញ្ញាត ឬដែលបានដាក់ជូនហើយ ត្រូវបានអនុញ្ញាត ។

(ឈ) ពាក់ព័ន្ធទៅនឹងការដាក់កម្រិតលើការនាំចេញវត្ថុធាតុដើមក្នុងស្រុកដែលចាំបាច់ដើម្បីធានាបរិមាណចាំបាច់នៃវត្ថុធាតុដើមនោះសម្រាប់ឧស្សាហកម្មកែច្នៃក្នុងស្រុក នៅក្នុងកំឡុងពេលដែលតម្លៃក្នុងស្រុកនៃវត្ថុធាតុដើមនោះទាបជាងតម្លៃទីផ្សារពិភពលោក ជាផ្នែកមួយនៃផែនការរក្សាស្ថេរភាពរបស់រដ្ឋាភិបាល ដោយផ្តល់ថា ការដាក់កម្រិតទាំងនោះមិនត្រូវបានធ្វើឱ្យកើនឡើងការនាំចេញ ឬការពារឧស្សាហកម្មក្នុងស្រុក និងមិនត្រូវធ្វើឱ្យប្រាសចាកពីបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងការមិនមានការរើសអើង និង ។

(ញ) ចាំបាច់ទៅនឹងការទទួលយក និងការចែកចាយផលិតផលជាទូទៅ ឬការផ្គត់ផ្គង់រយៈពេលខ្លី ដោយផ្តល់ថា រាល់វិធានការទាំងនោះត្រូវតែស្របទៅតាមគោលការណ៍ដែលប្រទេសសមាជិកមានសិទ្ធិទទួលបានចំណែកស្មើគ្នានៃការផ្គត់ផ្គង់អន្តរជាតិនៃផលិតផលនោះ ហើយវិធានការទាំងឡាយណាដែលមិនស្របទៅនឹងបទប្បញ្ញត្តិដទៃទៀតនៃកិច្ចព្រមព្រៀងនេះ ត្រូវបញ្ចប់ភ្លាមៗ នៅពេលដែលល័ក្ខខ័ណ្ឌដែលកើតឡើងលែងមាន ។

**មាត្រា ៩.- ការលើកលែងខាងសន្តិសុខ**

គ្មានអ្វីដែលកិច្ចព្រមព្រៀងនេះ ត្រូវបានរៀបរាប់ពី :

(ក) តម្រូវឱ្យប្រទេសសមាជិកណាមួយផ្តល់ ឬផ្សព្វផ្សាយព័ត៌មាន ដែលគេគិតថាផ្ទុយទៅនឹងផលប្រយោជន៍ខាងសន្តិសុខចាំបាច់ ឬ ។

(ខ) ការពារប្រទេសសមាជិកណាមួយពីការធ្វើសកម្មភាពដែលគេគិតថាចាំបាច់សម្រាប់ការពារផលប្រយោជន៍ខាងសន្តិសុខរបស់ប្រទេសនោះ :

(i) ពាក់ព័ន្ធទៅនឹងវត្ថុធាតុផ្ទុះ ឬវត្ថុធាតុដែលចេញពីធាតុផ្ទុះ ។

(ii) ពាក់ព័ន្ធទៅនឹងចរាចរអាវុធ ជាតិផ្ទុះ និងឧបករណ៍សង្គ្រាម និងការចរាចរទំនិញដទៃ និងវត្ថុធាតុដែលកំពុងបន្តដោយផ្ទាល់ ឬប្រយោលសម្រាប់គោលបំណងផ្គត់ផ្គង់ការបង្កើតទ័ព ។

(iii) សកម្មភាពដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈដ៏សំខាន់ រួមមានទូរគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធថាមពល និងទឹក ពីគោលបំណងធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធនោះ ។

(iv) សកម្មភាពទាន់ពេលវេលានូវភាពអាសន្នក្នុងស្រុក ឬសង្គ្រាម ឬភាពអាសន្នផ្សេងៗទៀតខាងទំនាក់ទំនងអន្តរជាតិ ឬ ។

(គ) ការពារប្រទេសសមាជិកណាមួយពីការចាត់វិធានការដោយអនុលោមទៅតាមកាតព្វកិច្ចក្រោមធម្មនុញ្ញអង្គការសហប្រជាជាតិសម្រាប់ការថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

**មាត្រា ១០.- វិធានការការពារតុល្យភាពទូទាត់**

គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានរៀបរាប់ពីការការពារប្រទេសសមាជិកមួយពីការចាត់វិធានការសម្រាប់គោលបំណងតុល្យភាពទូទាត់ ។ ប្រទេសសមាជិកមួយដែលប្រើប្រាស់វិធានការទាំងនោះអាចធ្វើដូច្នោះ ដោយយោងទៅតាមល័ក្ខខ័ណ្ឌដែលបានបង្កើតនៅក្រោមមាត្រា XII នៃ GATT ១៩៩៤ និងការយោគយល់ស្តីពីបទប្បញ្ញត្តិតុល្យភាពទូទាត់នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ ១ A នៃកិច្ចព្រមព្រៀង WTO ។

**មាត្រា ១១.- នីតិវិធីជូនព័ត៌មាន**

១. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ប្រទេសសមាជិកត្រូវជូនព័ត៌មាននូវរាល់សកម្មភាព ឬវិធានការដែលគេមានបំណងអនុវត្ត :

(ក) ដែលអាចជាមោឃៈភាព ឬប៉ះពាល់ផលប្រយោជន៍ប្រទេសសមាជិកដទៃ ដោយផ្ទាល់ ឬប្រយោលក្រោមកិច្ចព្រមព្រៀងនេះ ឬ ។

(ខ) នៅពេលដែលសកម្មភាព ឬវិធានការអាចរារាំងការសម្រេចទិសដៅនៃកិច្ចព្រមព្រៀងនេះ។

២. ដោយគ្មានការប៉ះពាល់ទូទៅនៃកាតព្វកិច្ចរបស់ប្រទេសសមាជិកក្រោមកថាខណ្ឌ ១ នៃ មាត្រានេះ នីតិវិធីជូនព័ត៌មានត្រូវអនុវត្ត ប៉ុន្តែត្រូវតែមានដែនកំណត់ ដើម្បីផ្លាស់ប្តូរវិធានការដែលមានរៀបរាប់នៅក្នុងបញ្ជីឧបសម្ព័ន្ធ ១ និងការកែប្រែទាំងនោះ។

៣. ប្រទេសសមាជិកមួយត្រូវធ្វើការជូនព័ត៌មានទៅកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ច (SEOM) និងលេខាធិការដ្ឋានអាស៊ានមុនពេលសកម្មភាព ឬវិធានការមានប្រសិទ្ធិភាព ដែលមានចែងនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ។ លើកលែងតែមានការចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ ការជូនព័ត៌មានត្រូវតែធ្វើឡើងយ៉ាងតិចបំផុតហុកសិប (៦០) ថ្ងៃ មុនពេលដែលសកម្មភាព និងវិធានការទាំងនោះចូលជាធរមាន។ ប្រទេសសមាជិកមួយ ដែលស្នើសុំអនុវត្តសកម្មភាព និងវិធានការត្រូវផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ការពិភាក្សាមុនជាមួយប្រទេសសមាជិកទាំងនោះ ដែលមានចំណាប់អារម្មណ៍ទៅនឹងសកម្មភាព និងវិធានការពាក់ព័ន្ធ។

៤. ការជូនព័ត៌មាននៃគោលបំណងសកម្មភាព និងវិធានការដែលបានផ្តល់ដោយសមាជិកមួយត្រូវរួមមាន :

(ក) រៀបរាប់ពីសកម្មភាព ឬវិធានការដែលត្រូវប្រើប្រាស់។

(ខ) មូលហេតុនៃការប្រើប្រាស់សកម្មភាព ឬវិធានការ និង។

(គ) កាលបរិច្ឆេទនៃការអនុវត្ត និងរយៈពេលនៃសកម្មភាព ឬវិធានការ។

៥. អត្ថន័យនៃការជូនព័ត៌មាន និងព័ត៌មានពាក់ព័ន្ធត្រូវតែរក្សាការសម្ងាត់។

៦. លេខាធិការដ្ឋានអាស៊ានត្រូវធ្វើ/ដើរតួនាទីភ្នាក់ងារកណ្តាលនៃការជូនព័ត៌មាន រួមទាំងការផ្តល់យោបល់ជាលាយល័ក្ខអក្សរ និងលទ្ធផលនៃការពិភាក្សា។ ប្រទេសសមាជិកដែលពាក់ព័ន្ធត្រូវផ្តល់លេខាធិ-ការដ្ឋានអាស៊ាននូវច្បាប់ចម្លងមួយច្បាប់នៃការផ្តល់យោបល់ដែលបានទទួល។ លេខាធិការដ្ឋានអាស៊ានត្រូវយកចិត្តទុកដាក់ទៅលើប្រទេសសមាជិកនីមួយៗ ដើម្បីជូនព័ត៌មានដែលតម្រូវ ដូចដែលមានចែងនៅក្នុងកថាខណ្ឌ ៤ នៃមាត្រានេះ ដែលមិនទាន់មានលក្ខណៈពេញលេញទាំងស្រុង។ លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធការជូនព័ត៌មាននីមួយៗ ទៅតាមការស្នើសុំទៅប្រទេសសមាជិកណាមួយ។

៧. ប្រទេសសមាជិកពាក់ព័ន្ធត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដោយគ្មានការរើសអើងសម្រាប់សមាជិកដទៃក្នុងការផ្តល់យោបល់របស់គេជាលាយល័ក្ខអក្សរ និងពិភាក្សាយោបល់ទាំងនេះនៅពេលដែលមានការស្នើសុំ។ ការចូលរួមពិភាក្សាដោយសមាជិកពាក់ព័ន្ធជាមួយនឹងសមាជិកដទៃ ត្រូវតែសម្រាប់គោលបំណង ដើម្បី

សាកសួរពីការបញ្ជាក់បន្ថែមស្តីអំពីសកម្មភាព ឬវិធានការ។ ប្រទេសសមាជិកអាចគិតការពិចារណា ចំពោះយោបល់ជាលាយល័ក្ខអក្សរ និងពិភាក្សានៅក្នុងការអនុវត្តសកម្មភាព ឬវិធានការ។

៨. ប្រទេសសមាជិកដទៃត្រូវបង្ហាញយោបល់របស់គេក្នុងកំឡុងដប់ប្រាំ (១៥)ថ្ងៃ នៃការជូនព័ត៌មាន។ ការខកខានរបស់សមាជិកណាមួយក្នុងការផ្តល់យោបល់ក្នុងកំឡុងពេលកំណត់ មិនត្រូវប៉ះពាល់ដល់សិទ្ធិក្នុងការស្វែងរកឧបាស្រ័យក្រោមមាត្រា ៨៨ ទេ។

**មាត្រា ១២.- ការបោះពុម្ព និង រដ្ឋបាលនៃបទបញ្ញាពាណិជ្ជកម្ម**

១. មាត្រា X នៃ GATT ១៩៩៤ ត្រូវបានដាក់បញ្ចូល និងបង្កើតជាផ្នែករួមមួយនៃកិច្ចព្រមព្រៀងនេះ *ដូចដែលបានកែប្រែ*។

២. តាមលទ្ធភាពដែលអាចទៅបាន ប្រទេសសមាជិកមួយត្រូវធ្វើច្បាប់ បទបញ្ជា សេចក្តីសម្រេច និង វិធានផ្សេងៗ ដែលមានចែងនៅក្នុងមាត្រា X នៃ GATT ១៩៩៤ ដែលមាននៅលើអ៊ីនធឺណែត។

**មាត្រា ១៣.- ការតម្កល់ឯកសារពាណិជ្ជកម្មអាស៊ាន**

១. ការតម្កល់ឯកសារពាណិជ្ជកម្មអាស៊ានរួមមានច្បាប់ និងនីតិវិធីស្តីពីពាណិជ្ជកម្ម និងគយ ដែលប្រទេសសមាជិកទាំងអស់ត្រូវបង្កើត និងធ្វើឱ្យអាចចូលបានដោយសាធារណៈតាមរយៈអ៊ីនធឺណែត។

២. ការតម្កល់ឯកសារពាណិជ្ជកម្មត្រូវមានព័ត៌មានពាក់ព័ន្ធដល់ពាណិជ្ជកម្មដូចជា (i) តារាងពន្ធគយ (ii) ពន្ធ MFN ពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងដទៃរបស់អាស៊ានជាមួយដៃគូពាណិជ្ជកម្ម (iii) វិធានដើមកំណើត (iv) វិធានការមិនមែនពន្ធគយ (v) ពាណិជ្ជកម្មជាតិ និងច្បាប់ និងវិធានគយ (vi) នីតិវិធី និងឯកសារតម្រូវ (vii) វិធានរដ្ឋបាល (viii) ការអនុវត្តល្អដែលប្រទេសសមាជិកនីមួយៗ បានប្រើប្រាស់ក្នុងការសម្របសម្រួលពាណិជ្ជកម្ម និង (ix) បញ្ជីពាណិជ្ជករដែលបានផ្តល់សិទ្ធិដោយប្រទេសសមាជិក។

៣. លេខាធិការដ្ឋានអាស៊ានត្រូវរក្សា និងធ្វើបច្ចុប្បន្នភាពនូវការតម្កល់ឯកសារពាណិជ្ជកម្មដោយឈរលើមូលដ្ឋានជូនព័ត៌មានដែលបានផ្តល់ដោយប្រទេសសមាជិក ដូចមានចែងនៅក្នុងមាត្រា ១១។

**មាត្រា ១៤._ ការសម្ងាត់**

១. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ តម្រូវឱ្យប្រទេសសមាជិកមួយផ្តល់ព័ត៌មានសម្ងាត់បើកចំហរ ដែលប៉ះពាល់ដល់ការប្រតិបត្តិច្បាប់របស់ប្រទេសសមាជិកនោះ ឬមិនដូច្នោះទេ ផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬនាំមកនូវសេចក្តីលំអៀងដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់នៃសហគ្រាស សាធារណៈ ឬឯកជនណាមួយ។

២. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរៀបរាប់ពីការតម្រូវឱ្យប្រទេសសមាជិកមួយក្នុងការផ្តល់ព័ត៌មាន ពាក់ព័ន្ធទៅនឹងកិច្ចការ និងគណនីនៃអតិថិជនរបស់ស្ថាប័នហិរញ្ញវត្ថុ។

៣. ប្រទេសសមាជិកនីមួយៗ ត្រូវអនុលោមទៅតាមច្បាប់ និងបទបញ្ជារក្សាការសម្ងាត់នូវព័ត៌មាន ដែលបានផ្តល់ថា សម្ងាត់ដោយសមាជិកដទៃដោយអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ។

៤. ថ្វីបើមានចែងខាងលើ កថាខណ្ឌ ១ ២ និង ៣ នៃមាត្រានេះមិនអាចអនុវត្តបានចំពោះជំពូក ៦ ទេ។

**មាត្រា ១៥._ ទំនាក់ទំនង**

រាល់ការទំនាក់ទំនងផ្លូវការ និងការផ្លាស់ប្តូរឯកសារក្នុងចំណោមសមាជិកដែលពាក់ព័ន្ធដល់ការអនុវត្តនៃកិច្ចព្រមព្រៀងនេះ ត្រូវតែជាលាយល័ក្ខអក្សរ និងជាភាសាអង់គ្លេស។

**មាត្រា ១៦._ ការលើកកម្ពស់ការចូលរួមរបស់ប្រទេសសមាជិក**

ការលើកកម្ពស់ការចូលរួមរបស់ប្រទេសសមាជិកត្រូវតែសម្រួលដោយភាពទន់ភ្លន់ ដែលឯកភាពជាមុន តាមរយៈការចរចាលើបទប្បញ្ញត្តិក្រោមកិច្ចព្រមព្រៀងនេះ។ ភាពទន់ភ្លន់ដែលឯកភាពជាមុននេះ ត្រូវតែមានចែង នៅក្នុងបទប្បញ្ញត្តិផ្សេងៗ ដាច់ដោយឡែក។

**មាត្រា ១៧._ ការកសាងសមត្ថភាព**

ការកសាងសមត្ថភាពត្រូវផ្តល់តាមរយៈការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធិភាព ដើម្បីពង្រឹងសមត្ថភាព ប្រសិទ្ធិភាព និងភាពប្រកួតប្រជែងក្នុងស្រុករបស់ប្រទេសសមាជិកនីមួយៗ កម្មវិធីការងារក្រោមគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI) និងគំនិតផ្តួចផ្តើមកសាងសមត្ថភាពដទៃទៀត។

**មាត្រា ១៨.- រដ្ឋាភិបាលក្នុងតំបន់ និងក្នុងស្រុក និងស្ថាប័នក្រៅរដ្ឋាភិបាល**

១. សមាជិកមួយត្រូវប្រើប្រាស់វិធានការសមរម្យដែលមាន ដើម្បីធានាថាការប្រតិបត្តិតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដោយរដ្ឋាភិបាលក្នុងតំបន់ និងក្នុងស្រុក និងអាជ្ញាធរនៅក្នុងដែលដីរបស់ខ្លួន។

២. ក្នុងការសម្រេចឱ្យបានកាតព្វកិច្ច និងការសន្យាក្រោមកិច្ចព្រមព្រៀងនេះ សមាជិកនីមួយៗ ត្រូវធានាការប្រតិបត្តិតាមបទប្បញ្ញត្តិ ដោយស្ថាប័នក្រៅរដ្ឋាភិបាល ក្នុងការអនុវត្តអំណាចដែលផ្តល់ដោយរដ្ឋាភិបាល ឬអាជ្ញាធរកណ្តាលក្នុងតំបន់ ឬក្នុងស្រុកនៅក្នុងទឹកដីរបស់ខ្លួន។

## ជំពូកទី ២
## សេរីកម្មពន្ធនាំចូល

**មាត្រា ១៩.- ការកាត់បន្ថយ ឬការលុបបំបាត់ពន្ធនាំចូល**

១. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ សមាជិកត្រូវលុបពន្ធនាំចូលចំពោះផលិតផលដែលធ្វើពាណិជ្ជកម្មរវាងសមាជិកនៅឆ្នាំ ២០១០ សម្រាប់អាស៊ាន-៦[១] និង ឆ្នាំ ២០១៥ រួមជាមួយភាពទន់ភ្លន់ដល់ឆ្នាំ ២០១៨ សម្រាប់ CLMV[២] ។

២. សមាជិកនីមួយៗ ត្រូវកាត់បន្ថយ និង/ឬលុបពន្ធនាំចូលលើទំនិញដើមកំណើតរបស់សមាជិកដទៃទៅតាមបែបបទខាងក្រោម :

(ក) ពន្ធនាំចូលលើផលិតផលដែលដាក់នៅក្នុងកម្មវិធី A នៃកម្មវិធីសេរីកម្មពន្ធនាំចូលរបស់សមាជិកនីមួយៗ ត្រូវលុបនៅឆ្នាំ ២០១០ សម្រាប់អាស៊ាន-៦ និងឆ្នាំ ២០១៥ សម្រាប់ CLMV ទៅតាមកម្មវិធីដែនមានចែងនៅក្នុងនោះ។ កម្មវិធី A របស់សមាជិកនីមួយៗ ត្រូវធានាថាល័ក្ខខ័ណ្ឌខាងក្រោមត្រូវបានបំពេញ :

(i) សម្រាប់អាស៊ាន-៦ នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ :

- ពន្ធនាំចូល យ៉ាងតិចបំផុត (៨០%) បន្ទាត់ពន្ធគយត្រូវលុប។

---

[១] " CLMV " សំដៅទៅលើ កម្ពុជា ឡាវ មីយ៉ានម៉ា និងវៀតណាម។

[២] " CLMV " សំដៅទៅលើ កម្ពុជា ឡាវ មីយ៉ានម៉ា និងវៀតណាម។

- ពន្ធនាំចូលលើផលិតផលបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍(ICT) ដូចដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀង អ៊ី-អាស៊ាន ត្រូវលុប។

- ពន្ធនាំចូលលើផលិតទាំងអស់នៃវិស័យសមាហរណកម្មអាទិភាព (PIS) នៅ (០%) លើកលែងតែបន្ទាត់ពន្ធគយដែលនៅក្នុងបញ្ជីអវិជ្ជមាននៃពិធីសារស្តីពីកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានសម្រាប់វិស័យសមាហរណកម្មអាទិភាព និងការកែប្រែទៅតាមនោះ និង។

- ពន្ធនាំចូលលើផលិតផលទាំងអស់ដែលស្មើ ឬតិចជាងប្រាំភាគរយ (៥%)។

(ii) សម្រាប់ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ពន្ធនាំចូលលើផលិតផលទាំងអស់ដែលស្មើ ឬតិចជាងប្រាំភាគរយ (៥%) នៅ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩។

(iii) សម្រាប់កម្ពុជា ពន្ធនាំចូលយ៉ាងតិចបំផុតប៉ែតសិបភាគរយ (៨០%) បន្ទាត់ពន្ធគយដែលស្មើ និងតិចជាងប្រាំភាគរយ ( ៥%) នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ និង។

(iv) ពន្ធនាំចូលលើផលិតផលមួយចំនួនរបស់ CLMV មិនលើសប្រាំពីរភាគរយ (៧%) នៃបន្ទាត់ពន្ធគយត្រូវលុបនៅឆ្នាំ ២០១៨។ បញ្ជីផលិតផល និងកម្មវិធីកាត់បន្ថយពន្ធនាំចូលផលិតផលទាំងនេះត្រូវកំណត់ដោយ CLMV មិនយឺតជាងថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤។

(ខ) ពន្ធនាំចូលលើផលិតផល ICT ដែលមាននៅក្នុងបញ្ជីកម្មវិធី B នៃសមាជិកនីមួយៗ ត្រូវលុបជាបី (៣)ចំណែកនៅឆ្នាំ ២០០៨ ២០០៩ និង ២០១០ ទៅតាមកម្មវិធីដែលមានចែងនៅក្នុងនោះ។

(គ) ពន្ធនាំចូលលើផលិតផល PIS ដែលមាននៅក្នុងកម្មវិធី C នៃសមាជិកនីមួយៗ ត្រូវលុបនៅឆ្នាំ ២០១២ ទៅតាមកម្មវិធីដែលមានចែងនៅក្នុងនោះ។

(ឃ) ពន្ធនាំចូលចំពោះកសិផលមិនទាន់កែច្នៃដែលមានចែងនៅក្នុងកម្មវិធី D នៃសមាជិកនីមួយៗ ទៅតាមរបៀបរបស់វា ត្រូវកាត់បន្ថយ និងលុបឱ្យនៅសូន្យទៅ ៥ ភាគរយ (០-៥%) នៅឆ្នាំ ២០១០ សម្រាប់អាស៊ាន-៦ ២០១៣ សម្រាប់វៀតណាម ២០១៥ សម្រាប់ឡាវ និង

មីយ៉ាន់ម៉ា និង ២០១៧ សម្រាប់កម្ពុជា ទៅតាមកម្មវិធីដែលមានចែងនៅក្នុងនោះ។ ថ្វីបើមានដូចនេះ ពន្ធនាំចូលលើផលិតផលស្ករបស់វៀតណាម ត្រូវលុបឱ្យនៅសូន្យ ទៅប្រាំភាគរយ (០-៥%) នៅឆ្នាំ ២០១០។

(ង) ផលិតផលកសិផលមិនទាន់កែច្នៃដែលដាក់នៅក្នុងកម្មវិធី E នៃប្រទេសនីមួយៗ ទៅតាមរបៀបរបស់វា ត្រូវអនុវត្តពន្ធនាំចូល MFN និងកាត់បន្ថយទៅតាមកម្មវិធីដែលមានចែងនៅក្នុងនោះ។

(ច) ផលិតផលដែលមានចែងនៅក្នុងកម្មវិធី F របស់ថៃឡង់ដ៍ និង វៀតណាមត្រូវកាត់បន្ថយអត្រាពន្ធកូតាចេញឱ្យស្របទៅនឹងកម្មវិធីកាត់បន្ថយពន្ធដែលឆ្លើយតបទៅនឹងចំណាត់ផលិតផលរៀងៗខ្លួន។

(ឆ) ពន្ធនាំចូលលើផលិតផលប្រេងឥន្ធនៈ ដែលមានចែងនៅក្នុងកម្មវិធី G របស់កម្ពុជា និង វៀតណាមត្រូវកាត់បន្ថយស្របទៅតាមកម្មវិធីដែលបានព្រមព្រៀងទៅវិញទៅមកដោយសមាជិកទាំងអស់ដែលមានចែងក្នុងនោះ។

(ជ) ផលិតផលដែលដាក់នៅក្នុងកម្មវិធី H នៃសមាជិកនីមួយៗ មិនត្រូវជាទិសដៅសម្រាប់កាត់បន្ថយ ឬលុបពន្ធនាំចូល ដោយយោងទៅលើមូលហេតុដែលមានចែងនៅក្នុងមាត្រា ៨។

(ឈ) ការកាត់បន្ថយ និង លុបពន្ធនាំចូលត្រូវអនុវត្តនៅថ្ងៃទី ០១ ខែ មករា នៃឆ្នាំនីមួយៗ និង

(ញ) អត្រាមូលដ្ឋានពីពន្ធនាំចូលដែលត្រូវកាត់បន្ថយ ឬលុបត្រូវតែអត្រាពន្ធអនុគ្រោះដែលមានប្រសិទ្ធិភាពរួម នៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

៣. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ គ្មានសមាជិកណាមួយត្រូវមោឃៈភាព ឬធ្វើឱ្យខូចខាតពន្ធសម្បទានណាមួយដែលបានអនុវត្ត យោងទៅតាមកម្មវិធីពន្ធនាំចូលដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២ នៅក្នុងកថាខណ្ឌ ៥ នៃមាត្រានេះ។

៤. លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ គ្មានសមាជិកណាមួយអាចបង្កើនពន្ធនាំចូលដែលមានស្រាប់បានបញ្ជាក់នៅក្នុងកម្មវិធីដែលអាចបានធ្វើ ដោយអនុលោមទៅតាមបណ្តាបទប្បញ្ញត្តិនៅក្នុងកថាខណ្ឌ ២ នៃមាត្រានេះស្តីពីការនាំចូលទំនិញដើមកំណើត។

៥. លើកលែងតែមានការផ្តល់នៅក្នុងកថាខណ្ឌ ២ (ក)(iv) នៃមាត្រានេះ កម្មវិធីពន្ធនាំចូលលំអិតដើម្បីអនុវត្តបែបបទនៃការកាត់បន្ថយ ឬលុបពន្ធនាំចូលដែលមានចែងនៅក្នុងកថាខណ្ឌ ២ នៃមាត្រានេះត្រូវបញ្ចប់មុនពេលកិច្ចព្រមព្រៀងនេះសម្រាប់អាស៊ាន-៦ ចូលជាធរមាន និងប្រាំមួយ (៦) ខែបន្ទាប់ពី

កិច្ចព្រមព្រៀងនេះសម្រាប់ CLMV ចូលជាធរមាន និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ដូច ឧបសម្ព័ន្ធ ២។

**មាត្រា ២០.- ការលុបអត្រាពន្ធកូតា**

១. លើកលែងតែមានការផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះ សមាជិកនីមួយៗ មិនត្រូវដាក់ទំនាម អត្រាពន្ធកូតា (TRQs) លើការនាំចូលទំនិញដើមកំណើតរបស់សមាជិកដទៃ ឬលើការនាំចេញទំនិញណាមួយ ឆ្ពោះទៅដែនដីរបស់សមាជិក។

២. វៀតណាម និង ថៃឡង់ដ៏ត្រូវលុប TRQs ដែលមានស្រាប់ដូចខាងក្រោម :

( ក ) ថៃឡង់ដ៏ ត្រូវលុបជាបី (៣) ចំណែក នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៨ ២០០៩ និង ២០១០។

(ខ) វៀតណាម ត្រូវលុបជាបី (៣) ចំណែក នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៣ ២០១៤ និង ២០១៥ ជាមួយនឹងភាពទន់ភ្លន់រហូតដល់ឆ្នាំ ២០១៨។

**មាត្រា ២១.- ការចេញប្រកាសអនុម័តផ្លូវច្បាប់**

១. (ក) សមាជិកនីមួយៗ មិនតិចជាងកៅសិប (៩០)ថ្ងៃ សម្រាប់អាស៊ាន-៦ និងប្រាំមួយ (៦) ខែសម្រាប់ CLMV បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ត្រូវចេញប្រកាស អនុម័តផ្លូវច្បាប់ យោងទៅតាមច្បាប់ និងបទបញ្ញាក្នុងស្រុកដើម្បីផ្តល់ប្រសិទ្ធិភាពនៃការ អនុវត្តកម្មវិធីសេរីកម្មពន្ធនាំចូលដែលបានសន្យាមាត្រា ១៩។

(ខ) ប្រកាសអនុម័តផ្លូវច្បាប់ដែលបានចេញដោយអនុលោមទៅតាមកថាខណ្ឌ ១ (ក) នៃ មាត្រានេះត្រូវអនុវត្តជាប្រតិសកម្មដែលមានប្រសិទ្ធិភាពចាប់ពីថ្ងៃតី ០១ ខែ មករា នៃឆ្នាំចូល ជាធរមាននៃកិច្ចព្រមព្រៀងនេះ។

(គ) នៅក្នុងករណីដែលប្រកាសអនុម័តផ្លូវការមួយមិនអាចចេញបាន ប្រកាសអនុម័តផ្លូវច្បាប់ ដើម្បីផ្តល់ប្រសិទ្ធិភាពសម្រាប់ការអនុវត្តន៏ការកាត់បន្ថយ ឬលុបពន្ធនាំចូលនៃឆ្នាំនីមួយៗ ត្រូវ ចេញយ៉ាងតិចបី (៣) ខែមុនកាលបរិច្ឆេទប្រសិទ្ធិភាពនៃការអនុវត្ត។

២. សមាជិកអាចសម្រេចចិត្តធ្វើការសើរើឡើងវិញចំពោះផលិតផលដែលស្ថិតនៅក្នុងកម្មវិធី D និង E ក្នុងគំនិតដើម្បីលើកកម្ពស់ការឈានចូលទីផ្សារសម្រាប់ផលិតផលទាំងនោះ។ ប្រសិនបើផលិតផលជា

ទិសដៅសម្រាប់ការសើរើត្រូវបានឯកភាពដើម្បីផ្ទេរចេញពីកម្មវិធីដែលបានរៀបរាប់នោះ វាត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធី A របស់សមាជិក និងជាទិសដៅសម្រាប់លុបពន្ធនាំចូលទៅតាមកម្មវិធីនោះ។

**មាត្រា ២២.- ការទទួលបាននូវសម្បទាន**

១. ផលិតផលដែលពន្ធនាំចូលនៃសមាជិកនាំចេញឈានទៅ ឬមានអត្រាម្ភៃភាគរយ (២០%) ឬទាបជាង និងបានបំពេញទៅនឹងវិធានដើមកំណើតដែលមានចែងនៅក្នុងជំពូក ៣ ត្រូវទទួលសម្បទានដោយស្វ័យប្រវត្តិ ដែលផ្តល់ដោយសមាជិកនាំចូលដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៩។

២. ផលិតផលដែលមានចែងនៅក្នុងកម្មវិធី H មិនត្រូវទទួលបានការផ្តល់ពន្ធសម្បទានក្រោមកិច្ចព្រមព្រៀងនេះទេ។

**មាត្រា ២៣.- ការកែប្រែបណ្តោះអាសន្ន ឬពន្យារនៃសម្បទាន**

១. នៅក្នុងកាលៈទេសៈលើកលែងពីអ្វីដែលបានចែងក្នុងមាត្រា ១០ មាត្រា ២៤ និងមាត្រា ៨៦ ដែលសមាជិកមួយប្រឈមមុខនឹងការលំបាកជាយថាហេតុក្នុងការអនុវត្តការសន្យាពន្ធនាំចូល សមាជិកនោះអាចកែប្រែបណ្តោះអាសន្ន ឬពន្យារសម្បទានដែលមាននៅក្នុងកម្មវិធីក្នុងមាត្រា ១៩។

២. សមាជិកមួយដែលចង់ប្រើបទប្បញ្ញត្តិនៃកថាខណ្ឌ ១ នៃមាត្រានេះ (ដែលហៅកាត់ថា "សមាជិកបេក្ខភាព") ត្រូវជូនព័ត៌មានជាលាយល័ក្ខអក្សរស្តីពីកាកែប្រែបណ្តោះអាសន្ន ឬពន្យារនៃសម្បទានទៅក្រុមប្រឹក្សាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) យ៉ាងតិចមួយរយប៉ែតសិប (១៨០) ថ្ងៃ មុនកាលបរិច្ឆេទដែលការកែប្រែបណ្តោះអាសន្ន ឬការពន្យារនៃសម្បទានមានប្រសិទ្ធិភាព។

៣. សមាជិកដែលមានចំណាប់អារម្មណ៍ធ្វើការពិគ្រោះ ឬចរចាជាមួយសមាជិកដែលជាបេក្ខភាពអនុលោមទៅតាមកថាខណ្ឌ ៤ នៃមាត្រានេះ ត្រូវជូនព័ត៌មានទៅសមាជិកអាស៊ានទាំងអស់ពីចំណាប់អារម្មណ៍នេះ ក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ បន្ទាប់ពីការជូនព័ត៌មានពីកាកែប្រែបណ្តោះអាសន្ន ឬពន្យារនៃសម្បទានរបស់សមាជិកបេក្ខភាព។

៤. បន្ទាប់ពីការជូនព័ត៌មានអនុលោមទៅតាមកថាខណ្ឌ ២ នៃមាត្រានេះ សមាជិកបេក្ខភាពត្រូវចូលពិគ្រោះ ឬចរចាជាមួយសមាជិកដែលបានជូនព័ត៌មានអនុលោមទៅតាមកថាខណ្ឌ ៣ នៃមាត្រានេះ។ ក្នុងការ

ចរចាជាមួយសមាជិកដែលផលប្រយោជន៍ផ្គត់ផ្គង់ជាដុំកំភួន[៣] សមាជិកបេក្ខភាពត្រូវរក្សាកម្រិតសម្បទានគុណសម្បត្តិទៅវិញទៅមក ឬបដិការី ដោយការអនុគ្រោះពាណិជ្ជកម្មមិនតិចជាងទៅសមាជិកដទៃដែលផ្តល់ផលប្រយោជន៍ផ្គត់ផ្គង់ជាដុំកំភួនលើសពីអ្វីដែលបានផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះ មុនពេលចរចាដែលអាចបញ្ចូលទាំងការកែតម្រូវទូទាត់សងទៅនឹងទំនិញដទៃ។ វិធានការកែតម្រូវទូទាត់សង ក្នុងទម្រង់ជាពន្ធនាំចូលត្រូវផ្តល់ទៅដល់សមាជិកទាំងអស់ដោយមិនមានការរើសអើង។

៥. ក្រុមប្រឹក្សា AFTA ត្រូវបានជូនព័ត៌មានពីលទ្ធផលនៃការពិគ្រោះ ឬចរចាអនុលោមទៅតាមកថាខណ្ឌ ៣ និង ៤ នៃមាត្រានេះ យ៉ាងតិចសែសិបប្រាំ (៤៥) ថ្ងៃ មុនពេលសមាជិកបេក្ខភាពមានបំណងដាក់ការកែប្រែបណ្តោះអាសន្ន ឬពន្យារនៃសម្បទានដោយចូលជាធរមាន។ ការជូនព័ត៌មានត្រូវរួមបញ្ចូលទាំងការសម្រួលរបស់សមាជិកបេក្ខភាពដើម្បីអនុម័តវិធានការ និងត្រូវផ្តល់ដល់សមាជិកនូវកម្មវិធីការកែប្រែបាននឹងធ្វើការកែប្រែ ឬការពន្យារសម្បទាន និងពេលវេលាដែលសមាជិកមានបំណងអនុវត្តបណ្តាវិធានការនោះ។

៦. នៅក្នុងស្ថានភាពដែលមិនឈានទៅដល់ការព្រមព្រៀងបន្ទាប់ពីការពិគ្រោះ ឬចរចាដោយអនុលោមទៅតាមកថាខណ្ឌ ៣ និង ៤ នៃមាត្រានេះ ការជូនព័ត៌មានទៅក្រុមប្រឹក្សា AFTA ត្រូវរួមបញ្ចូលទាំងសំណើសម្រាប់ការផ្តល់អនុសាសន៍របស់ក្រុមប្រឹក្សា AFTA។

៧. ក្រុមប្រឹក្សា AFTA ត្រូវចេញការអនុញ្ញាតយល់ព្រម ឬអនុសាសន៍ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីទទួលការជូនព័ត៌មានអនុលោមទៅតាមកថាខណ្ឌ ៥ នៃមាត្រានេះ។

៨. នៅក្នុងស្ថានភាពដែលមានកាលៈទេសៈក្នុងការស្នើសម្រាប់ការកែប្រែបណ្តោះអាសន្ន ឬពន្យារនៃសម្បទានត្រូវបានបញ្ឈប់សមាជិកបេក្ខភាពត្រូវស្តាបនាឡើងវិញជាបន្ទាន់នូវសម្បទានពន្ធនាំចូល និងជូនព័ត៌មានទៅក្រុមប្រឹក្សា AFTA ឱ្យបានសមស្រប។ ក្នុងពេលស្តាបនានៃសម្បទានពន្ធនាំចូល ឬបញ្ឈប់ការពន្យារសមាជិកបេក្ខភាពត្រូវអនុវត្តអត្រាដែលបានអនុវត្តទៅតាមកម្មវិធីសន្យា ប្រសិនបើការបង្អង់ ឬពន្យារមិនទាន់បានកើតឡើងនៅឡើយទេ។

៩. ក្នុងស្ថានភាពដែលមិនមានការអនុញ្ញាត ឬអនុសាសន៍របស់ក្រុមប្រឹក្សា AFTA អនុលោមទៅតាមកថាខណ្ឌ ៧ នៃមាត្រានេះ និងសមាជិកបេក្ខភាព យ៉ាងណាក៏ដោយដំណើរការជាមួយនឹងការកែប្រែ

---

[៣] សមាជិកមួយមួយដែលចាត់ទុកថាមានផលប្រយោជន៍ផ្គត់ផ្គង់ជាដុំកំភួន ប្រសិនបើវាមាន ឬមូលហេតុនៃសម្បទានពន្ធនាំចូលវាត្រូវតែមានមូលហេតុសមហេតុផលសង្ឃឹមថាមាន ចំណែកចាំបាច់យ៉ាងតិចបំផុតម្ភៃភាគរយ (២០%) នៃការនាំចូលសរុបពីអាស៊ានចំពោះផលិតផលនោះក្នុងកំឡុងបី (៣) ឆ្នាំ ជាមធ្យមនៅលើទីផ្សារនៃសមាជិកបេក្ខភាព។

បណ្ដោះអាសន្ន ឬពន្ធរ៉ាវនៃសម្បទាន សមាជិកដែលមានផលប្រយោជន៍ផ្គត់ផ្គង់ដុំកំភួន ត្រូវមានសេរីភាពក្នុងការចាត់វិធានការបន្ទាប់ពីសាមសិប (៣០) ថ្ងៃ តែមិនឱ្យយឺតជាងកៅសិប (៩០) ថ្ងៃ បន្ទាប់ពីសមាជិកបេក្ខភាពចូលជាធរមាននៃការកែប្រែបណ្ដោះអាសន្ន ឬពន្ធរ៉ាវនៃសម្បទាន ត្រូវកែប្រែ ឬពន្ធរ៉ាវសម្បទានជាដុំកំភួនដែលមានតម្លៃស្មើនឹងសមាជិកបេក្ខភាព។ សមាជិកពាក់ព័ន្ធត្រូវជូនព័ត៌មានទៅក្រុមប្រឹក្សា AFTA នូវសកម្មភាពទាំងនោះ។

**មាត្រា ២៤.- ប្រព្រឹត្តិកម្មពិសេសចំពោះអង្ករ និង ស្ករ**

ពិធីសារស្ដីពីការផ្ដល់ការពិចារណាពិសេសសម្រាប់អង្ករ និងស្ករ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ ត្រូវផ្គុំជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

## ជំពូកទី ៣
## វិធានដើមកំណើត

**មាត្រា ២៥.- និយមន័យ**

សម្រាប់គោលបំណងនៃជំពូកនេះ :

(ក) **វារីវប្បកម្ម** មានន័យថា របរកសិកម្ម នៃសរីរាង្គរស់នៅក្នុងទឹកដែលរួមមាន : ត្រីពួកសត្វ សន្ទាន ខ្យង គ្រំ បង្កង ក្ដាម កម្ពឹស ។ល។ និបិដ្យាដ្ឋិតសត្វដែលគ្មានឆ្អឹងខ្នងរស់នៅក្នុងទឹកផ្សេងៗ ទៀត និងរុក្ខជាតិតូចៗ ដែលរស់នៅក្នុងទឹក ហើយមានអាហារបម្រុងដូចជាពង (ពងសត្វ និងរុក្ខជាតិក្នុងទឹក) កូនត្រី ឬង់តុង និងកូនក្អុក ដែលចូលរួមក្នុងដំណើរការជួយធ្វើឱ្យមានការរីកធំធាត់ ដើម្បីពង្រឹងផលិតកម្ម ដូចជាការចិញ្ចឹម ការឱ្យចំណី ឬការការពារពីជម្ងឺផ្សេងៗ។

(ខ) **ថ្លៃ ការធានារ៉ាប់រង និងការដឹកជញ្ជូន** (CIF) មានន័យថា តម្លៃនៃទំនិញដែលបាននាំចូល និងរួមទាំងថ្លៃដឹកជញ្ជូន និងធានារ៉ាប់រងដល់កំពង់ផែ ឬទីកន្លែងនៃប្រទេសដែលនាំចូល។ តម្លៃត្រូវតែធ្វើទៅតាមមាត្រា VII នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងស្ដីពីការអនុវត្តមាត្រា VII នៃ GATT ១៩៩៤ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១ A នៃកិច្ចព្រមព្រៀង WTO។

(គ) FOB មានន័យថា តម្លៃដឹកជញ្ជូននៃទំនិញរួមបញ្ចូលទាំងថ្លៃដឹកជញ្ជូនទៅដល់កំពង់ផែ ឬទីកន្លែងចុងក្រោយនៅក្រៅប្រទេស។ តម្លៃត្រូវតែធ្វើទៅតាមមាត្រា VII នៃ GATT ១៩៩៤ និង

កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃ GATT ១៩៩៤ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១ A នៃកិច្ចព្រមព្រៀង WTO ។

(ឃ) **គោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ទូទៅ** (GAAP) មានន័យថា ទទួលស្គាល់ កុងសង់ស៊ីសការគាំទ្រជាច្រើនពីអាជ្ញាធរដែនដីនៃសមាជិក ដោយគោរពទៅតាមកំណត់ត្រា ចំណូល ចំណាយ ថ្លៃចំណាយ ទ្រព្យសកម្ម និងបំណុល ព័ត៌មានផ្សព្វផ្សាយ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ស្តង់ដារនេះអាចដាក់ជុំវិញគោលការណ៍នៃការអនុវត្តទូទៅក៏ដូចជាស្តង់ដារ ការអនុវត្ត និងនីតិវិធីលំអិត។

(ង) **ទំនិញ** រួមបញ្ចូលទាំងវត្ថុធាតុដើម និង/ឬផលិតផល ដែលអាចមានវត្ថុធាតុ ឬផលិតទាំងស្រុង ទោះជាទំនិញនោះ មានគោលដៅសម្រាប់ប្រើប្រាស់បន្ទាប់ជាវត្ថុធាតុក្នុងសង្វាក់ផលិតកម្មណាមួយទៀតក៏ដោយ។ សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យ "ទំនិញ" និង "ផលិតផល" អាចប្រើជំនួសគ្នាបាន។

(ច) **វត្ថុធាតុដែលមានលក្ខណៈដូច និងវត្ថុធាតុដែលអាចផ្លាស់ប្តូរគ្នាបាន** មានន័យថា វត្ថុធាតុដែលមានលក្ខណៈដូចគ្នា និងគុណភាពពាណិជ្ជកម្ម សង្វាក់ផលិតកម្មដោយប្រើបច្ចេកទេស និងចរិកលក្ខណៈរូបរាងដូច និងបន្ទាប់មកដាក់បញ្ចូលទៅក្នុងផលិតផលចុងក្រោយ ដោយមិនអាចកំណត់បានថា មួយណាជាមួយណាសម្រាប់គោលបំណងដើមកំណើតដោយអាស្រ័យលើការកត់សម្គាល់ ។ល។

(ឆ) **វត្ថុធាតុ** មានន័យថា រូបធាតុ ឬសារធាតុដែលបានប្រើប្រាស់ ឬប្រើនៅក្នុងការផលិតទំនិញ ឬបញ្ចូលឱ្យទៅជាទំនិញដទៃទៀត ឬជាប្រធានបទរបស់សង្វាក់ផលិតនៃទំនិញផ្សេងទៀត។

(ជ) **ទំនិញដើម ឬវត្ថុធាតុដើម** មានន័យថា ទំនិញ ឬវត្ថុធាតុដែលគ្រប់លក្ខណៈជាដើមកំណើត យោងទៅតាមបទប្បញ្ញត្តិនៃជំពូកនេះ។

(ឈ) **វត្ថុធាតុវេចខ្ចប់ និងភាជនៈសម្រាប់ដឹកជញ្ជូន** មានន័យថា ទំនិញដែលបានប្រើប្រាស់សម្រាប់ការពារទំនិញមួយនៅក្នុងពេលដឹកជញ្ជូន ដែលខុសពីភាជនៈ ឬវត្ថុធាតុបានប្រើប្រាស់សម្រាប់ការលក់រាយរបស់វា។

(ញ) **ផលិតកម្ម** មានន័យថា វិធីសាស្ត្រក្នុងការទទួលបានទំនិញរួមទាំង ការដាំដុះ ជីករ៉ែ ច្រូតកាត់ ចិញ្ចឹម បង្កាត់ពូជ ចម្រាញ់ចេញ ប្រមូលផ្តុំ ប្រមូល ចាប់ នេសាទ លំអ បរបាញ់ ផលិត សង្វាក់ផលិតកម្ម ឬតម្លើងទំនិញ។

(ដ) **វិធានផលិតផលដោយឡែក** មានន័យថា វិធានដែលបញ្ជាក់ថាវត្ថុធាតុទាំងនោះបានឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ ឬដំណើរការផលិត ឬសង្វាក់ផលិតដោយឡែក ឬគ្រប់លក្ខខ័ណ្ឌតម្លៃបូកបន្ថែមតំបន់ ឬរួមបញ្ចូលលក្ខខ័ណ្ឌទាំងនោះ។

**មាត្រា ២៦.- លក្ខខ័ណ្ឌដើមកំណើត**

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ទំនិញដែលបាននាំចូលក្នុងដែនដីរបស់សមាជិកមួយពីសមាជិកដទៃត្រូវតែចាត់ទុកថាជាទំនិញដើមកំណើត ប្រសិនបើវាអនុលោមទៅតាមតម្រូវការវិធានដើមក្រោមលក្ខខ័ណ្ឌណាមួយខាងក្រោមនេះ :

(ក) ទំនិញដែលមាន ឬផលិតទាំងស្រុងនៅក្នុងសមាជិកនាំចេញដែលមានចែង និងកំណត់នៅក្នុងមាត្រា ២៧ ឬ។

(ខ) ទំនិញដែលមិនមាន ឬផលិតទាំងស្រុងនៅក្នុងសមាជិកនាំចេញ ដោយផ្តល់ថាទំនិញទាំងនោះអាចទទួលបានក្រោមមាត្រា ២៨ និង មាត្រា ៣០។

**មាត្រា ២៧.- ទំនិញដែលមាន ឬផលិតទាំងស្រុង**

ក្នុងអត្ថន័យនៃមាត្រា ២៦ (ក) ខាងក្រោមនេះ ត្រូវពិចារណាជាទំនិញដែលមាន ឬផលិតទាំងស្រុងនៅក្នុងសមាជិកនាំចេញ :

(ក) រុក្ខជាតិ និងផលិតផលពីរុក្ខជាតិ រួមទាំងផ្លែ ផ្កា បន្លែ ដើមឈើ សារាយសមុទ្រ ផ្សិត រុក្ខជាតិមានជីវិត ដាំដុះ និងប្រមូលផល បេះ ឬប្រមូលផ្តុំនៅក្នុងសមាជិកនាំចេញ។

(ខ) សត្វរស់ រួមមានទាំង សត្វចិញ្ចឹមកូនដោយទឹកដោះ សត្វស្លាប ត្រី សត្វវង្គសត្វ សិប្បសត្វ ល្មូនបាក់តេរី និងមេរោគ កើត និងចិញ្ចឹមនៅក្នុងសមាជិកនាំចេញ។

(គ) ទំនិញដែលបានមកពីសត្វរស់នៅក្នុងសមាជិកនាំចេញ។

(ឃ) ទំនិញដែលបានមកពីការបរបាញ់ ដាក់អន្ទាក់ នេសាទ កសិកម្ម វារីវប្បកម្ម ប្រមូលផ្តុំ ឬចាប់បាននៅក្នុងសមាជិកនាំចេញ។

(ង) រ៉ែ និងធនធានធម្មជាតិដទៃទៀតដែលមិនមានបញ្ចូលនៅក្នុងកថាខណ្ឌរង (ក) ដល់ (ឃ) នៃមាត្រានេះ បានចម្រាញ់ ឬយកចេញពីដី ទឹក សមុទ្រ ឬបាតសមុទ្រនៃសមុទ្រនោះ។

(ច) ទំនិញដែលបានពីការនេសាទសមុទ្រ ដោយនាវាដែលបានចុះបញ្ជីជាមួយសមាជិកមួយ និងបង្ហោះទង់ជាតិរបស់វា និងផលិតផលដទៃទៀត[៤] យកពីទឹកសមុទ្រ ឬបាតសមុទ្រក្រៅដែនទឹក[៥] នៃសមាជិកដោយផ្តល់ថា សមាជិកនោះមានសិទ្ធិរុករកដែនទឹក សមុទ្រ និងបាតសមុទ្រនោះដោយយោងទៅតាមច្បាប់អន្តរជាតិ[៦] ។

(ឆ) ទំនិញពីការនេសាទសមុទ្រ និងផលិតផលពីសមុទ្រដែលយកពីសមុទ្រអន្តរជាតិដោយនាវា ដែលបានចុះបញ្ជីជាមួយសមាជិកមួយ និងបានបង្ហោះទង់ជាតិរបស់សមាជិកនោះ ។

(ជ) ទំនិញដែលឆ្លងកាត់សង្វាក់ផលិត និង/ឬផលិតនៅលើនាវារោងចក្រដែលបានចុះបញ្ជីនៅក្នុងសមាជិកមួយ និងមានសិទ្ធិបង្ហោះទង់ជាតិរបស់សមាជិកនោះ រួមទាំងផលិតផលដែលមានចែងនៅក្នុងកថាខណ្ឌ (ឆ) នៃមាត្រានេះ ។

(ឈ) របស់របរដែលប្រមូលនៅទីនោះ ដែលមិនអាចរក្សាសភាពដើមបានយូរ ឬស្តាបនាឡើងវិញ ឬជួសជុលឡើងវិញ ដែលរបស់របរទាំងនោះស័ក្តិសមសម្រាប់តែបោះចោល ឬសម្រាប់ប្រើដើម្បីកែប្រែលើផ្នែកផ្សេងទៀតនៃវត្ថុធាតុដើម ឬក្នុងគោលបំណងសម្រាប់រំលាយធ្វើម្តងទៀត ។

(ញ) កម្ទេច និងកាកសំណល់ដែលបានមកពី :

(i) សង្វាក់ផលិតនៅក្នុងសមាជិកនាំចេញ ឬ ។

(ii) ទំនិញដែលប្រើប្រាស់រួចប្រមូលនៅក្នុងសមាជិកនាំចេញ ដោយផ្តល់ថាទំនិញនោះស័ក្តិសមសម្រាប់ប្រើដើម្បីកែប្រែវត្ថុធាតុដើម និង ។

(ដ) ទំនិញដែលមាន ឬផលិតនៅក្នុងសមាជិកនាំចេញ ពីផលិតផលដែលមានចែងនៅក្នុងកថាខណ្ឌ (ក) ដល់ (ញ) នៃមាត្រានេះ ។

## មាត្រា ២៨.- ទំនិញដែលមិនមាន ឬផលិតទាំងស្រុង

១. (ក) សម្រាប់គោលបំណងនៃមាត្រា ២៦ (ខ) ទំនិញអាចចាត់ទុកថាមានដើមកំណើតនៅក្នុង

---

[៤] "ផលិតផលដទៃ"សំដៅទៅលើរ៉ែ និងធនធានធម្មជាតិដទៃទៀតដែលយកចេញពីទឹក សមុទ្រ ឬបាតសមុទ្រក្រៅដែនទឹក ។

[៥] សម្រាប់ផលិតផលនេសាទសមុទ្រដែលបានមកពីដែនទឹកក្រៅ (ឧ. តំបន់សេដ្ឋកិច្ចពិសេស) ដើមកំណើតត្រូវតែផ្តល់ទៅសមាជិកដែលបានប្រើប្រាស់នាវាសម្រាប់ទាញយកផលិតផលនោះ ដែលបានចុះបញ្ជីដោយមានទង់ជាតិបង្ហោះលើនាវានោះ និងផ្តល់ថាសមាជិកនោះមានសិទ្ធិរុករកក្រោមច្បាប់អន្តរជាតិ ។

[៦] អនុលោមទៅតាមច្បាប់អន្តរជាតិ ការចុះបញ្ជីនាវាអាចធ្វើបាននៅក្នុងតែសមាជិកមួយប៉ុណ្ណោះ ។

សមាជិក ដែលការងារ ឬសម្ញាក់ផលិតនៃទំនិញបានធ្វើនៅទីនោះ :

(i) ប្រសិនបើទំនិញមានតម្លៃចំណុះតំបន់ (ដែលហៅថា "តម្លៃចំណុះអាស៊ាន" ឬ "តម្លៃចំណុះតំបន់ (RVC) មិនតិចជាង (៤០%) គណនាដោយប្រើរូបមន្តដែលមានចែងនៅក្នុងមាត្រា ២៩ ឬ។

(ii) ប្រសិនបើវត្ថុធាតុទាំងអស់ដែលមិនមែនដើមកំណើត បានប្រើនៅក្នុងការផលិត ទំនិញដោយឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ (ដែលហៅថា "CTC") នៅកម្រិតបួនខ្ទង់ (ឧ. ផ្លាស់ប្តូរជំពូករង) នៃប្រព័ន្ធរួម។

(ខ) សមាជិកនីមួយៗ ត្រូវអនុញ្ញាតឱ្យអ្នកនាំចេញទំនិញក្នុងការសម្រេចថាតើត្រូវប្រើកថាខណ្ឌ ១ (ក) (i) ឬ ១ (ក) (ii) នៃមាត្រានេះនៅពេលកំណត់គុណភាពទំនិញជាទំនិញដើមកំណើតរបស់សមាជិក។

២. (ក) ថ្វីបើមានកថាខណ្ឌ ១ នៃមាត្រានេះ ទំនិញដែលស្ថិតនៅក្នុងឧសម្ព័ន្ធ ៣ ត្រូវគ្រប់លក្ខណៈជាទំនិញដើមកំណើត ប្រសិនបើទំនិញទាំងនោះ បំពេញទៅនឹងវិធានផលិតដោយឡែក ដែលមានចែងនៅក្នុងនេះ។

(ខ) ទីណាដែលវិធានផលិតដោយឡែកផ្តល់វិធានជម្រើសពីវិធានដើមកំណើតមូលដ្ឋាន RVC វិធានដើមកំណើតមូលដ្ឋាន CTC វិធានដើមកំណើតសម្ញាក់ហត្ថកម្ម ឬប្រតិបត្តិការបន្ត ឬការបន្សំនៃវិធានទាំងនេះ សមាជិកនីមួយៗ ត្រូវអនុញ្ញាតឱ្យអ្នកនាំចេញទំនិញសម្រេចក្នុងការកំណត់ប្រើប្រាស់វិធានដែលទំនិញគ្រប់លក្ខណៈជាទំនិញដើមកំណើតរបស់សមាជិក។

(គ) ទីណាដែលវិធានផលិតដោយឡែកចំពោះ RVC វាតម្រូវថា ទំនិញ RVC ត្រូវគណនាដោយប្រើរូបមន្តដែលមានចែងនៅក្នុងមាត្រា ២៩។

(ឃ) ទីណាដែលវិធានផលិតដោយឡែកតម្រូវថា វត្ថុធាតុដែលប្រើប្រាស់បានឆ្លងកាត់ CTC ឬសម្ញាក់ហត្ថកម្ម ឬប្រតិបត្តិការបន្ត វិធានត្រូវតែអនុវត្តចំពោះវត្ថុធាតុមិនមែនដើមកំណើត។

៣. ថ្វីបើមានកថាខណ្ឌ ១ និង ២ នៃមាត្រានេះ ទំនិញដែលគ្របដណ្តប់នៅក្នុងការចងភ្ជាប់ ក និង ខ នៃសេចក្តីប្រកាសរដ្ឋមន្ត្រីស្តីពីពាណិជ្ជកម្មផលិតផលព័ត៌មានបច្ចេកវិទ្យាអនុម័តនៅក្នុងសន្និសីទរដ្ឋមន្ត្រី WTO ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ៤ ត្រូវតែជាដើមកំណើត នៅក្នុងសមាជិកមួយប្រសិនបើវាតម្លើងពីវត្ថុធាតុគ្របដណ្តប់ក្រោមឧបសម្ព័ន្ធដូច។

**មាត្រា ២៩.- ការគណនាតម្លៃតំបន់**

១. សម្រាប់គោលបំណងនៃមាត្រា ២៨ រូបមន្តសម្រាប់ការគណនាតម្លៃចំណុះអាស៊ាន ឬ RVC គឺដូចខាងក្រោម :

(ក) វិធីសាស្ត្រផ្ទាល់

$$RVC = \frac{\text{ថ្លៃវត្ថុធាតុអាស៊ាន} + \text{ថ្លៃពលកម្មផ្ទាល់} + \text{ថ្លៃផលិត} + \text{ថ្លៃផ្សេងៗ} + \text{ប្រាក់ចំណេញ}}{\text{តម្លៃ FOB}} \times ១០០\%$$

ឬ

(ខ) វិធីសាស្ត្រប្រយោល

$$RVC = \frac{\text{តម្លៃ FOB} \quad \text{តម្លៃនៃវត្ថុធាតុ គ្រឿងបន្លាស់ ឬទំនិញ ដែលមិនមានដើមកំណើត}}{\text{តម្លៃ FOB}} \times ១០០\%$$

២. សម្រាប់គោលបំណងនៃការគណនា RVC ដែលបានផ្តល់នៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ :

(ក) ថ្លៃវត្ថុធាតុអាស៊ាន គឺជាតម្លៃ CIF នៃវត្ថុធាតុ គ្រឿងបន្លាស់ ឬទំនិញដើមកំណើតដែលបានមក ឬផលិតខ្លួនឯងដោយអ្នកផលិតសម្រាប់ផលិតកម្មនៃទំនិញ។

(ខ) តម្លៃនៃវត្ថុធាតុ គ្រឿងបន្លាស់ ឬទំនិញមិនមែនដើមកំណើតត្រូវតែ :

(i) តម្លៃ CIF នៅពេលដែលនាំចូលទំនិញ ឬការនាំចូលដែលអាចបញ្ជាក់ ឬ។

(ii) តម្លៃជាក់លាក់ដំបូងដែលបានចំណាយសម្រាប់ទំនិញក្នុងការកំណត់ដើមកំណើតនៅក្នុងដែនដីរបស់សមាជិកដែលការងារ និងសង្វាក់ផលិតធ្វើនៅទីនោះ។

(គ) ថ្លៃពលកម្មផ្ទាល់ ត្រូវរួមមាន ប្រាក់បៀវត្សរ៍ លាភការ និងផលប្រយោជន៍ដទៃទៀតសម្រាប់និយោជិកចូលរួមជាមួយនឹងសង្វាក់ហត្ថកម្ម។

(ឃ) ការគណនាថ្លៃផលិតផ្ទាល់ គួររួមមាន ប៉ុន្តែមិនកំណត់ទ្រព្យសម្បត្តិពិតប្រាកដដែលទាក់ទងជាមួយសង្វាក់ផលិត (ធានារ៉ាប់រង រោងចក្រជួល ឬជាប់កិច្ចសន្យា រំលោះអគារ ជួសជុល និងថែរក្សា ពន្ធអាករ ការប្រាក់លើអចលនទ្រព្យ) ថ្លៃជួល និងការប្រាក់ សម្រាប់រោងចក្រ និងបរិក្ខារ សុវត្ថិភាពរោងចក្រ ធានារ៉ាប់រង (រោងចក្រ បរិក្ខារ និងវត្ថុធាតុដែលបានប្រើក្នុងការផលិតទំនិញ) ការប្រើប្រាស់ (ថាមពល អេឡិចត្រូនិច ទឹក និងការប្រើប្រាស់ដោយផ្ទាល់ក្នុងការផលិតទំនិញ) ស្រាវជ្រាវ អភិវឌ្ឍន៍ គម្រោងប្លង់ និងវិស្វកម្ម លាប ចាក់ពុម្ព ឧបករណ៍ជាង និងការរំលស់ រក្សា និងជួសជុលរោងចក្រ និងបរិក្ខារ តម្លៃសិទ្ធិ ឬអាជ្ញាប័ណ្ណ (ដែលទាក់ទងទៅនឹងបាតង់ម៉ាស៊ីន ឬដំណើរការដែលបានប្រើប្រាស់ក្នុងការផលិតទំនិញ ឬសិទ្ធិក្នុងការផលិតទំនិញ) ត្រួតពិនិត្យ និងសាកល្បងវត្ថុធាតុ និងទំនិញ រក្សាទុក និងប្រើប្រាស់នៅក្នុងរោងចក្រសំរាម និងកាកសំណល់សម្រាប់កែច្នៃឡើងវិញ ថ្លៃសមាសធាតុក្នុងការគណនាតម្លៃវត្ថុធាតុនៅ ឧ. ថ្លៃកំពង់ផែ និងសំអាតទំនិញ និងពន្ធនាំចូល ដែលបានចំណាយសម្រាប់សមាសភាពដែលត្រូវបង់ពន្ធ និង។

(ង) តម្លៃ FOB មានន័យថា តម្លៃ fee-on-board នៃទំនិញដែលមានអត្ថន័យនៅក្នុងមាត្រា ២៥។ តម្លៃ FOB ត្រូវកំណត់ដោយបន្ថែមតម្លៃវត្ថុធាតុ ថ្លៃផលិត ប្រាក់ចំណេញ និងថ្លៃផ្សេងៗទៀត។

៣. សមាជិកត្រូវកំណត់ដោយប្រកាន់ខ្ជាប់វិធីសាស្ត្រគណនា RVC តែមួយ។ សមាជិកត្រូវបានផ្តល់ភាពទន់ភ្លន់ក្នុងការផ្លាស់ប្តូរវិធីសាស្ត្រគណនារបស់គេដោយផ្តល់ថា ការផ្លាស់ប្តូរនោះត្រូវបានជូនព័ត៌មានទៅក្រុមប្រឹក្សា AFTA យ៉ាងតិចប្រាំមួយ (៦) ខែ មុនពេលអនុម័តវិធីសាស្ត្រថ្មី។ រាល់ការពិនិត្យបញ្ជាក់ការគណនាតម្លៃចំណុះអាស៊ានដោយសមាជិកនាំចូលត្រូវតែធ្វើដោយផ្អែកលើមូលដ្ឋានវិធីសាស្ត្រ ដែលបានប្រើប្រាស់ដោយសមាជិកនាំចេញ។

៤. ក្នុងការកំណត់តម្លៃចំណុះអាស៊ាន សមាជិកត្រូវប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍សម្រាប់របៀបគណនាថ្លៃ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ៥។

៥. វត្ថុធាតុដែលមានស្រាប់ក្នុងស្រុក ផលិតដោយសហគ្រាសបង្កើតអាជ្ញាប័ណ្ណ ស្របទៅតាមបទបញ្ជាផ្ទៃក្នុងត្រូវចាត់ទុកថាបានបំពេញតម្រូវការដើមកំណើតនៃកិច្ចព្រមព្រៀងនេះ វត្ថុធាតុដែលមានស្រាប់ក្នុងស្រុកពីប្រភពដទៃទៀត ត្រូវតែជាកម្មវត្ថុការបញ្ជាក់ដើមកំណើត អនុលោមទៅតាមមាត្រា ៥៧ សម្រាប់គោលបំណងនៃការកំណត់ដើមកំណើត។

៦. តម្លៃនៃទំនិញនៅក្រោមជំពូកនេះ ត្រូវបានកំណត់អនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ៥៧។

**មាត្រា ៣០.- ការរួបរួម**

១. លើកលែងតែមានការផ្តល់ផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ទំនិញដើមកំណើតនៅក្នុងសមាជិកមួយដែលត្រូវបានប្រើនៅក្នុងសមាជិកដទៃជាវត្ថុធាតុសម្រាប់ទំនិញចុងក្រោយ ក្នុងការទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូល ត្រូវពិចារណាថាមានដើមកំណើតនៅក្នុងសមាជិកបន្ទាប់ដែលការងារ និងសង្វាក់សម្រាប់ទំនិញចុងក្រោយបានធ្វើនៅទីនោះ។

២. ប្រសិនបើ RVC នៃវត្ថុធាតុតិចជាងសែសិបភាគរយ (៤០%) តម្លៃចំណុះអាស៊ានគ្រប់ល័ក្ខខ័ណ្ឌសម្រាប់បូកបញ្ចូលដោយប្រើល័ក្ខខ័ណ្ឌ RVC ត្រូវតែសមាមាត្រផ្ទាល់ទៅនឹងចំណុះក្នុងស្រុក ប្រសិនបើវាស្មើគ្នា ឬច្រើនជាងម្ភៃភាគរយ (២០%)។ គោលការណ៍អនុវត្តន៍មានចែងនៅក្នុងឧបសម្ព័ន្ធ ៦។

**មាត្រា ៣១.- ប្រតិបត្តិ និងសង្វាក់ផលិតកម្មតិចតួច**

១. ប្រតិបត្តិ និងសង្វាក់ផលិតកម្មដែលបានធ្វើដោយខ្លួនគេ ឬសហោគជាមួយសមាជិកដទៃណាមួយសម្រាប់គោលបំណងដែលមានរៀបរាប់ខាងក្រោម ត្រូវបានពិចារណាថាតិចតួច និងមិនត្រូវបានយកទៅពិចារណា ដើម្បីកំណត់ថាទំនិញនោះ មានដើមកំណើតនៅក្នុងសមាជិកមួយ :

(ក) ធានាការរក្សាទំនិញឱ្យស្ថិតនៅក្នុងល័ក្ខខ័ណ្ឌល្អ ក្នុងគោលបំណងសម្រាប់ដឹកជញ្ជូន និងរក្សាទុក។

(ខ) សម្រួលដល់ការលើកដាក់ ឬដឹកជញ្ជូន។

(គ) វេចខ្ចប់ ឬបង្ហាញទំនិញសម្រាប់លក់។

២. ទំនិញដើមកំណើតនៅក្នុងដែនដីរបស់សមាជិកមួយ ត្រូវតែរក្សាស្ថានភាពដើមកំណើតដំបូង នៅពេលដែលនាំចេញពីសមាជិកដទៃ ដែលប្រតិបត្តិមិនបានប្រព្រឹត្តហួសពីអ្វីដែលមាននៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ។

**មាត្រា ៣២.- ដឹកជញ្ជូនផ្ទាល់**

១. ប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូលត្រូវអនុវត្តចំពោះទំនិញដែលបំពេញទៅនឹងតម្រូវការនៃជំពូកនេះ និងបានដឹកជញ្ជូនផ្ទាល់រវាងដែនដីនៃសមាជិកនាំចេញ និងសមាជិកនាំចូល។

២. ខាងក្រោមនេះ ត្រូវបានពិចារណាថាបានដឹកជញ្ជូនផ្ទាល់ពីសមាជិកនាំចេញទៅសមាជិកនាំចូល :

(ក) ទំនិញដែលបានដឹកជញ្ជូនពីសមាជិកនាំចេញ ទៅសមាជិកនាំចូល ឬ។

(ខ) ទំនិញដែលដឹកជញ្ជូនដោយឆ្លងកាត់សមាជិកមួយ ឬច្រើន លើកលែងសមាជិកនាំចេញ និងនាំចូល ឬឆ្លងកាត់ប្រទេសមិនមែនសមាជិក :

(i) ច្រកឆ្លងកាត់ត្រូវបានបញ្ជាក់ដោយមូលហេតុភូមិសាស្ត្រ ឬពិចារណាថាពាក់ព័ន្ធទៅនឹងតម្រូវការដឹកជញ្ជូន។

(ii) ទំនិញមិនទាន់ធ្វើចរាចរពាណិជ្ជកម្ម ឬប្រើប្រាស់នៅទីនោះ និង។

(iii) ទំនិញមិនបានឆ្លងកាត់ការប្រតិបត្តិនៅទីនោះ លើកលែងតែ លើកចេញ ដាក់ចូល ឬ ការប្រតិបត្តិដទៃ ដើម្បីរក្សាទំនិញឱ្យស្ថិតក្នុងល័ក្ខខ័ណ្ឌល្អ។

**មាត្រា ៣៣.- ដឹមីនីមុីស**

១. ទំនិញដែលមិនឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ត្រូវបានពិចារណាថាជាដើមកំណើត ប្រសិនបើតម្លៃនៃវត្ថុធាតុមិនមែនដើមកំណើតទាំងអស់បានប្រើប្រាស់នៅក្នុងការផលិតដែលមិនឆ្លងកាត់ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ មិនលើសដប់ភាគរយ (១០%) តម្លៃ FOB នៃទំនិញ និងទំនិញបានបំពេញរាល់ល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ សម្រាប់ទំនិញដើមកំណើត។

២. តម្លៃវត្ថុធាតុមិនមែនដើមកំណើតយោងទៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ យ៉ាងណាក៏ដោយត្រូវរួមបញ្ចូលទៅក្នុងតម្លៃវត្ថុធាតុមិនមែនដើមកំណើតសម្រាប់ការទាមទារ RVC ចំពោះទំនិញ។

**មាត្រា ៣៤.- ប្រព្រឹត្តិកម្មវេចខ្ចប់ និង វត្ថុធាតុវេចខ្ចប់**

១. ការវេចខ្ចប់ និង វត្ថុធាតុវេចខ្ចប់សម្រាប់លក់រាយ :

(ក) ប្រសិនបើទំនិញជាកម្មវត្ថុវិធានដើមកំណើតមូលដ្ឋាន RVC តម្លៃនៃការវេចខ្ចប់ និងវត្ថុធាតុវេចខ្ចប់សម្រាប់លក់រាយត្រូវតែយកមកវាយតម្លៃដើមកំណើតរបស់វា ដែលការវេចខ្ចប់និងវត្ថុធាតុវេចខ្ចប់សម្រាប់លក់រាយត្រូវបានពិចារណាថាចូលរួមបង្កើតទំនិញទាំងស្រុង។

(ខ) នៅពេលដែលកថាខណ្ឌ ១ (ក) នៃមាត្រានេះមិនអាចរកបាន ការវេចខ្ចប់ និងវត្ថុធាតុវេចខ្ចប់សម្រាប់លក់រាយ ពេលដែលចាត់ចំណាត់ថ្នាក់ជាមួយគ្នាទៅនឹងការវេចខ្ចប់ទំនិញមិនត្រូវបានយកមកពិចារណា ទោះបីជាវត្ថុធាតុមិនមែនដើមកំណើតទាំងអស់ដែលបានប្រើនៅក្នុងការ

ផលិតទំនិញបានបំពេញឆ្លើយតបទៅនឹងការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញដែលបានពោលខាងលើ ។

២. ភាជន៍ និងសំបកវេចខ្ចប់វត្ថុធាតុដែលរួមបញ្ចូលសម្រាប់ការដឹកជញ្ជូនទំនិញមិនត្រូវបានយកទៅសម្រាប់កំណត់ដើមកំណើតនៃទំនិញដែលបានពោលនោះទេ ។

**មាត្រា ៣៥.- សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍ប្រើប្រាស់ផ្សេងៗ**

១. ប្រសិនបើទំនិញជាកម្មវត្ថុសម្រាប់តម្រូវការ CTC ឬសង្វាក់ហត្ថកម្ម ឬប្រតិបត្តិការបន្ត ដើមកំណើតនៃសម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបរណ៍ប្រើប្រាស់ផ្សេងៗ និងគំនូសបង្ហាញ ឬព័ត៌មានពីវត្ថុធាតុផ្សេងៗ ដែលមានវត្តមានជាមួយទំនិញមិនត្រូវបានយកទៅកំណត់ពីល័ក្ខខ័ណ្ឌដើមកំណើតទំនិញប្រសិនបើ៖

(ក) សម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបរណ៍ប្រើប្រាស់ផ្សេងៗ និងគំនូសបង្ហាញ ឬព័ត៌មានពីវត្ថុធាតុផ្សេងៗ មិនបានដាក់នៅក្នុងវិក្កយបត្រដោយឡែកពីទំនិញ និង

(ខ) បរិមាណ និងតម្លៃសម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបរណ៍ប្រើប្រាស់ផ្សេងៗ និងគំនូសបង្ហាញ ឬព័ត៌មានពីវត្ថុធាតុផ្សេងៗ ជាទម្លាប់របស់ទំនិញ ។

២. ប្រសិនបើទំនិញជាកម្មវត្ថុវិធានដើមកំណើតមូលដ្ឋាន RVC តម្លៃសម្ភារៈបន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបរណ៍ប្រើប្រាស់ផ្សេងៗ និងគំនូសបង្ហាញ ឬព័ត៌មានពីវត្ថុធាតុផ្សេងៗ អាចត្រូវយកទៅគិតជាតម្លៃដើមកំណើត ឬវត្ថុធាតុមិនមែនដើមកំណើតក្នុងការគណនា RVC នៃដើមកំណើតទំនិញ ។

**មាត្រា ៣៦.- វត្ថុធាតុផ្ទាល់**

ដើម្បីកំណត់ដើមកំណើតទំនិញ វាមិនមានសារៈសំខាន់ក្នុងការកំណត់ដើមកំណើតទំនិញតាមសមាសធាតុខាងក្រោមដែលអាចនឹងប្រើប្រាស់ក្នុងការផលិត និងមិនដាក់បញ្ចូលទៅក្នុងទំនិញ ៖

(ក) ប្រេងឥន្ធនៈ និងថាមពល ។

(ខ) គ្រឿងប្រដាប់ប្រដារ ពុម្ព និងចាក់ពុម្ព ។

(គ) គ្រឿងបន្លាស់ និងវត្ថុធាតុដែលបានប្រើក្នុងការរក្សាគ្រឿងបរិក្ខារ និងអគារ ។

(ឃ) ប្រេងសម្រាប់ដាក់គ្រឿងយន្ត ខ្លាញ់ វត្ថុធាតុផ្សំ និងរាល់វត្ថុធាតុដែលបានប្រើប្រាស់ក្នុងផលិតកម្ម ឬបានប្រើក្នុងការប្រតិបត្តិគ្រឿងបរិក្ខារ ឬអគារ ។

(ង) ស្រោមដៃ វ៉ែនតា ស្បែកជើង សម្លៀកបំពាក់ ឧបករណ៍សុវត្ថិភាព និងវត្ថុធាតុផ្គត់ផ្គង់ផ្សេងៗ ។

(ច) ឧបករណ៍ គ្រឿង និងវត្ថុធាតុផ្គត់ផ្គង់ដែលបានប្រើប្រាស់សម្រាប់ការសាកល្បង ឬត្រួតពិនិត្យទំនិញ។

(ឆ) សារធាតុដាក់បន្ថែមដើម្បីឱ្យឆាប់ប្រតិកម្មគីមី និងទឹកសម្រាប់រំលាយ និង។

(ជ) រាល់ទំនិញណាមួយដែលមិនចូលរួមឱ្យទៅជាទំនិញ ប៉ុន្តែប្រើនៅក្នុងការផលិតទំនិញដែលអាចមានហេតុផលសមរម្យដើម្បីបង្ហាញថាជាផ្នែកមួយនៃការផលិត។

**មាត្រា ៣៧.- វត្ថុធាតុដែលមានលក្ខណៈដូច និង វត្ថុធាតុដែលអាចផ្លាស់ប្តូរគ្នាបាន**

១. ការកំណត់ថាវត្ថុធាតុនោះជាវត្ថុធាតុដែលមានលក្ខណៈដូច និងវត្ថុធាតុដែលអាចផ្លាស់ប្តូរគ្នាបានជាវត្ថុធាតុដើមកំណើតត្រូវធ្វើឡើងដោយវិយោគកម្មរូបរាងចំពោះវត្ថុធាតុនីមួយៗ ឬដោយប្រើគោលការណ៍គណនេយ្យ ដែលទទួលស្គាល់ទូទៅនៃការត្រួតពិនិត្យហ៊ុនដែលមាន ឬបញ្ជីគ្រប់គ្រងសារពើភ័ណ្ឌអនុវត្តជាក់ស្តែងនៅក្នុងសមាជិកនាំចេញ។

២. នៅពេលដែលការសម្រេចត្រូវបានធ្វើឡើងចំពោះវិធីសាស្ត្រគ្រប់គ្រងសារពើភ័ណ្ឌ វិធីសាស្ត្រត្រូវតែប្រើប្រាស់ពេញឆ្នាំសារពើភ័ណ្ឌ។

**មាត្រា ៣៨.- វិញ្ញាបនបត្រដើមកំណើត**

ការទាមទារថា ទំនិញត្រូវតែទទួលស្គាល់សម្រាប់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូល ត្រូវគាំទ្រដោយវិញ្ញាបនបត្រ (Form D) ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៧ ដែលបានចេញដោយអាជ្ញាធររដ្ឋាភិបាលបានចាត់តាំងដោយសមាជិកនាំចេញ និងបានជូនព័ត៌មានទៅបណ្តាសមាជិកអនុលោមទៅតាមនីតិវិធីប្រតិបត្តិវិញ្ញាបនបត្រ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ៨។

**មាត្រា ៣៩.- អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត**

១. សម្រាប់គោលបំណងនៃប្រសិទ្ធិភាព និងភាពដូចគ្នាក្នុងការអនុវត្តនៃជំពូកនេះ អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើតត្រូវតែបង្កើតដោយយោងទៅតាមមាត្រា ៥០។

២. មុខងាររបស់អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើតត្រូវរួមមាន :

(ក) ត្រួតពិនិត្យការអនុវត្ត និងការប្រតិបត្តិនៃជំពូកនេះ។

(ខ) នៅពេលដែលចាំបាច់ រំលឹកឡើងវិញនូវជំពូកនេះ ដើម្បីផ្តល់អនុសាសន៍សមរម្យក្នុងគំនិតពង្រឹងជំពូកនេះ ឱ្យឆ្លើយតបបានទៅតាមការផ្លាស់ប្តូរជាថាមវន្តនៅក្នុងសង្វាក់ផលិតកម្មតំបន់ និងពិភពលោកក្នុងការសម្របសម្រួលពាណិជ្ជកម្ម និងវិនិយោគរវាងសមាជិក លើកកម្ពស់ប្រព័ន្ធផលិតតំបន់ជំរុញការអភិវឌ្ឍឧស្សាហកម្មធុនតូច និងមធ្យម (SMEs) និងធ្វើឱ្យគម្លាតអភិវឌ្ឍន៍រួមតូច ។

(គ) នៅពេលដែលចាំបាច់ រំលឹកឡើងវិញនូវនីតិវិធីប្រតិបត្តិនៃជំពូកនេះជាមួយគំនិតធ្វើឱ្យមាននីតិវិធីងាយស្រួល និងធ្វើឱ្យមានតម្លាភាពដែលអាចព្យាករណ៍បាន និងមានស្តង់ដារ ដោយយកចិត្តទុកដាក់ទៅលើការអនុវត្តគំរូល្អរបស់តំបន់ដទៃ និងបណ្តាកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ ។

(ឃ) ពិចារណាបញ្ហាផ្សេងៗ ដូចដែលមានការព្រមព្រៀងពីសមាជិកពាក់ព័ន្ធទៅនឹងជំពូកនេះ ។

(ង) អនុវត្តមុខងារដទៃទៀតដែលផ្តល់ដោយគណៈកម្មាធិការសម្របសម្រួលប្រព័ន្ធអនុគ្រោះពន្ធរួមឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងក្រុមប្រឹក្សា AFTA ។

៣. អនុគណៈកម្មាធិការស្តីពីដើមកំណើតទំនិញត្រូវមានសមាសភាពតំណាងរដ្ឋាភិបាលពីសមាជិក និងអាចអញ្ជើញតំណាងពីស្ថាប័នផ្សេងក្រៅពីរដ្ឋាភិបាលរបស់សមាជិកដែលមានជំនាញចាំបាច់ពាក់ព័ន្ធទៅនឹងបញ្ហាចូលរួមពិភាក្សា នៅពេលមានការឯកភាពពីសមាជិកទាំងអស់ ។

## ជំពូកទី ៤
## វិធានការមិនមែនពន្ធនាំចូល

**មាត្រា ៤០.- បែបបទនៃវិធានការមិនមែនពន្ធនាំចូល**

១. សមាជិកនីមួយៗ មិនត្រូវអនុម័ត ឬរក្សាវិធានការមិនមែនពន្ធនាំចូលណាមួយចំពោះការនាំចូលទំនិញណាមួយពីសមាជិកណាមួយ ឬលើការនាំចេញទំនិញណាមួយសំដៅទៅដែនដីសមាជិកដទៃណាមួយ លើកលែងអនុលោមទៅតាមសិទ្ធិ និងកាតព្វកិច្ចរបស់វានៅក្នុង WTO ឬអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ ។

២. សមាជិកនីមួយៗ ត្រូវធានានូវតម្លាភាពនៃវិធានការមិនមែនពន្ធនាំចូលដែលអនុញ្ញាតនៅក្នុងកថាខណ្ឌ ១ នៃកិច្ចព្រមព្រៀងនេះអនុលោមទៅតាមមាត្រា ១២ និងត្រូវធ្វើឱ្យប្រាកដថាវិធានការទាំងនោះមិនបានរៀបចំអនុម័ត ឬអនុវត្តក្នុងគំនិត ឬជាមួយការប៉ះពាល់ បង្កើតឧបសគ្គដែលមិនសំខាន់នៅក្នុងពាណិជ្ជកម្មរវាងសមាជិក ។

៣. វិធានការថ្មីណាមួយ ឬការកែប្រែណាមួយទៅនឹងវិធានការដែលមានស្រាប់ត្រូវតែជូនព័ត៌មានអនុលោមទៅតាមមាត្រា ១១។

៤. ស្ថិតិស្តីពីវិធានការមិនមែនពន្ធនាំចូលដែលបានអនុវត្តនៅក្នុងសមាជិកត្រូវអភិវឌ្ឍបន្ថែម និងត្រូវដាក់បញ្ចូលទៅក្នុងការតម្កល់ឯកសារអាស៊ានដូចដែលមានចែងនៅក្នុងមាត្រា ១៣។

**មាត្រា ៤១.- ការលុបចោលនូវនូវការដាក់កម្រិតបរិមាណ**

សមាជិកនីមួយៗ មិនត្រូវអនុម័ត ឬរក្សាទំនិញហាមឃាត់ ឬដាក់កម្រិតបរិមាណណាមួយចំពោះការនាំចូលទំនិញណាមួយពីសមាជិកដទៃ ឬលើការនាំចេញទំនិញណាមួយសំដៅទៅដែនដីសមាជិកដទៃ លើកលែងតែអនុលោមទៅតាមសិទ្ធិ និងកាតព្វកិច្ចរបស់វានៅក្នុង WTO ឬបទប្បញ្ញត្តិដទៃនៅក្នុងកិច្ចព្រមព្រៀងនេះ។ ក្នុងន័យនេះ មាត្រា XI នៃ GATT ១៩៩៤ គួរត្រូវរួមផ្សំ និងបង្កើតជាផ្នែកនៃកិច្ចព្រមព្រៀងនេះ *ដូចដែលបានកែប្រែ*។

**មាត្រា ៤២.- ការលុបរបាំងមិនមែនពន្ធនាំចូល**

១. សមាជិកត្រូវលើកឡើងវិញនូវវិធានការមិនមែនពន្ធនាំចូលនៅក្នុងស្ថិតិដែលមានយោងនៅក្នុងកថាខណ្ឌ ៤ នៃមាត្រា ៤០ ក្នុងគំនិតដើម្បីកំណត់របាំងមិនមែនពន្ធនាំចូល (NTBs) ក្រៅពីការដាក់កម្រិតបរិមាណសម្រាប់លុបបំបាត់។ ការលុបបំបាត់ NTBs ដែលបានកំណត់ត្រូវទាក់ទងជាមួយនឹងគណៈកម្មាធិការសម្របសម្រួលសម្រាប់ការអនុវត្ត ATIGA (CCA) គណៈកម្មាធិការពិគ្រោះស្តីពីស្តង់ដារ និងគុណភាព (ACCSQ) គណៈកម្មាធិការស្តីពីអនាម័យ និងភូតគាមអនាម័យ បណ្តាក្រុមការងារ ក្រោមអគ្គនាយកគយ និងស្ថាប័នអាស៊ានពាក់ព័ន្ធដទៃទៀត ត្រូវផ្តល់អនុសាសន៍ស្តីពីការកំណត់របាំងមិនមែនពន្ធនាំចូលទៅក្រុមប្រឹក្សា AFTA តាមរយៈ SEOM។

២. លើកលែងតែមានការព្រមព្រៀងដោយក្រុមប្រឹក្សា AFTA ការកំណត់ NTBs ត្រូវលុបជាបីផ្នែកដូចខាងក្រោម :

(ក) ប្រ៊ុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សិង្ហបុរី និងថៃឡង់ដ៍ត្រូវលុបជាបីផ្នែកចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០០៨ ២០០៩ និង ២០១០

(ខ) ហ្វីលីពីនត្រូវលុបជាបីផ្នែកចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០១០ ២០១១ និង ២០១២

(គ) កម្ពុជា ឡាវ ភូមា និងវៀតណាមត្រូវលុបជាបីផ្នែកចាប់ពីថ្ងៃ ០១ ខែ មករា ឆ្នាំ ២០១៣ ២០១៤ និង ២០១៥។

៣. បញ្ជីកំណត់ NTBs ដែលត្រូវលុបបំបាត់ទៅតាមផ្នែកនីមួយៗ ត្រូវតែព្រមព្រៀងដោយកិច្ចប្រជុំក្រុមប្រឹក្សា AFTA មុនឆ្នាំដែលកាលបរិច្ឆេទលុប TNBs នោះមានប្រសិទ្ធិភាព។

៤. ថ្វីបើមានកថាខណ្ឌ ១ និង ៣ នៃមាត្រានេះ CCA ដោយពិគ្រោះជាមួយស្ថាប័នអាស៊ានពាក់ព័ន្ធ ត្រូវរំលឹកឡើងវិញនូវវិធានការមិនមែនពន្ធនាំចូលដែលបានជូនព័ត៌មាន និងបានរាយការណ៍ដោយសមាជិកដទៃណាមួយ ឬដោយវិស័យឯកជន ក្នុងគំនិតដើម្បីកំណត់ថាតើវិធានការទាំងនោះបង្កើតជា NTBs ឬយ៉ាងណា ប្រសិនបើការពិនិត្យឡើងវិញបណ្តាលឱ្យមានការបង្ហាញ NTBs នោះ NTBs ត្រូវលុបដោយសមាជិកអនុវត្ត NTBs ទាំងនោះដោយអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ។

៥. CCA ត្រូវបម្រើជាចំណុចទំនាក់ទំនងសម្រាប់ការជូនព័ត៌មាន និងរំលឹកឡើងវិញដូចមានចែងនៅក្នុងកថាខ័ណ្ឌ ៤ នៃមាត្រានេះ។

៦. ការលើកលែងនៃមាត្រានេះ គួរត្រូវបានអនុញ្ញាតសម្រាប់តែមូលហេតុដែលបានផ្តល់នៅក្នុងមាត្រា ៨។

៧. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរារាំងសមាជិកដែលជាភាគីនៃ *Basel Convention on the Control of Transboundary Movements of Hazardous Wastes and their Disposal* ឬពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិដទៃ ពីការអនុម័ត ឬប្រតិបត្តិវិធានការណាមួយដែលមានទំនាក់ទំនងទៅនឹង *hazardous wastes or substances* ដោយផ្អែកលើមូលដ្ឋានច្បាប់ និងបទបញ្ជារបស់វាអនុលោមទៅតាមកិច្ចព្រមព្រៀងអន្តរជាតិទាំងនោះ។

## មាត្រា ៤៣.- ការរឹតត្បិតរូបិយប័ណ្ណ

សមាជិកត្រូវលើកលែងចំពោះការរឹតត្បិតរូបិយប័ណ្ណ ដែលពាក់ព័ន្ធទៅនឹងការទូទាត់ផលិតផលនៅក្រោមកិច្ចព្រមព្រៀងនេះ ក៏ដូចជាការនាំចូលមកវិញនៃការទូទាត់ទាំងនោះដោយមិនបានវិនិច្ឆ័យចំពោះសិទ្ធិរបស់គេនៅក្រោមមាត្រា XVIII នៃ GATT ១៩៩៤ និងបទប្បញ្ញត្តិពាក់ព័ន្ធទៅបណ្តាមាត្រានៃកិច្ចព្រមព្រៀងរូបិយប័ណ្ណអន្តរជាតិ (IMF)។

**មាត្រា ៤៤.- នីតិវិធីអាជ្ញាបណ្ណនាំចូល**

១. សមាជិកនីមួយៗ ត្រូវធានាថានីតិវិធីអាជ្ញាបណ្ណស្វ័យប្រវត្តិ ឬមិន-ស្វ័យប្រវត្តិត្រូវបានអនុវត្ត ដោយតម្លាភាព និងអាចនិទស្សន៍បាន និងអនុវត្តទៅតាមកិច្ចព្រមព្រៀងស្តីពីនីតិវិធីអាជ្ញាបណ្ណនាំចូល ដូច ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១ A នៃកិច្ចព្រមព្រៀង WTO ។

២. បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន សមាជិកនីមួយៗ ត្រូវជូនព័ត៌មានទៅសមាជិកដទៃពី នីតិវិធីអាជ្ញាបណ្ណនាំចូលដែលមានស្រាប់ ។ បន្ទាប់ពីនោះសមាជិកនីមួយៗ ត្រូវជូនព័ត៌មានទៅសមាជិកដទៃ នូវរាល់នីតិវិធីអាជ្ញាបណ្ណនាំចូលថ្មីណាមួយ និងការកែប្រែណាមួយទៅនឹងនីតិវិធីអាជ្ញាបណ្ណនាំចូលដែលមាន ស្រាប់ហុកសិប (៦០) ថ្ងៃមុនពេលចូលជាធរមានប៉ុន្តែនៅក្នុងករណីណាក៏ដោយ ក៏មិនឱ្យយឺតជាង កាលបរិច្ឆេទនៃការចូលជាធរមាននៃតម្រូវការអាជ្ញាបណ្ណនោះទេ ។ ការជូនព័ត៌មានដែលបានផ្តល់នៅក្រោម មាត្រានេះ ត្រូវរួមបញ្ចូលទាំងព័ត៌មានដែលបានបញ្ជាក់នៅក្នុងមាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីនីតិវិធី អាជ្ញាបណ្ណនាំចូលដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១ A នៃកិច្ចព្រមព្រៀង WTO ។

៣. សមាជិកនីមួយៗ ត្រូវឆ្លើយក្នុងកំឡុងហុកសិប (៦០) ថ្ងៃ នូវរាល់ការទាមទារទាំងឡាយពី សមាជិកដទៃ ចំពោះល័ក្ខខ័ណ្ឌដែលបានប្រើដោយអាជ្ញាធរផ្តល់អាជ្ញាបណ្ណនៅក្នុងការផ្តល់ ឬបដិសេធ អាជ្ញាបណ្ណនាំចូល ។ សមាជិកនាំចូលត្រូវពិចារណាបោះពុម្ពផ្សាយល័ក្ខខ័ណ្ឌទាំងនោះ ។

៤. សមាសភាពដែលនៅក្នុងនីតិវិធីអាជ្ញាបណ្ណមិន-ស្វ័យប្រវត្តិដែលបានរកឃើញនៅក្នុងការបង្អាក់ ពាណិជ្ជកម្មត្រូវបានកំណត់ ក្នុងគំនិតដកចេញរបាំងទាំងនោះ និងបើអាចទៅបាន ធ្វើឱ្យទៅជានីតិវិធីអាជ្ញាបណ្ណ នាំចូលស្វ័យប្រវត្តិ ។

## ជំពូកទី ៥

## ការសម្របសម្រួលពាណិជ្ជកម្ម

**មាត្រា ៤៥.- កម្មវិធីការងារស្តីពីការសម្របសម្រួលពាណិជ្ជកម្ម និងគោលបំណងរបស់វា**

១. សមាជិកត្រូវអភិវឌ្ឍ និងអនុវត្តកម្មវិធីការងារសម្របសម្រួលពាណិជ្ជកម្មទូលំទូលាយដែលបាន រៀបចំនូវរាល់សកម្មភាព និងវិធានការរួបីមានកំណត់ និងពេលវេលាច្បាស់លាស់ចំពោះការអនុវត្តចាំបាច់ សម្រាប់បង្កើតឱ្យមានស្ថេរភាព តម្លាភាព និងបរិស្ថានដែលអាចព្យាករណ៍បានសម្រាប់កិច្ចការពាណិជ្ជកម្ម

អន្តរជាតិដែលបង្កើតឱ្យមានកាលានុវត្តភាពពាណិជ្ជកម្ម និងជួយធុរកិច្ច រួមទាំងឧស្សាហកម្មធុនតូច និងមធ្យម (SMEs) ក្នុងការសន្សំសំចៃពេលវេលា និងកាត់បន្ថយចំណាយ ។

២. កម្មវិធីការងារសម្របសម្រួលពាណិជ្ជកម្មអាស៊ានត្រូវរៀបចំសកម្មភាព និងវិធានការសម្រាប់ការអនុវត្តឱ្យបានទាំងក្នុងកម្រិតអាស៊ាន និងកម្រិតជាតិ ។

**មាត្រា ៤៦.- ទំហំនៃកម្មវិធីការងារសម្របសម្រួលពាណិជ្ជកម្មអាស៊ាន**

កម្មវិធីការសម្របសម្រួលពាណិជ្ជកម្មអាស៊ានដែលមានចែងនៅក្នុងមាត្រា ៤៥ ត្រូវគ្របដណ្តប់ទៅលើវិស័យ នីតិវិធីគយ បទបញ្ញ និងនីតិវិធីពាណិជ្ជកម្ម ស្តង់ដារ និងអនុលោមភាព អនាម័យ និងភូតគាមអនាម័យ ច្រកចេញតែមួយអាស៊ាន និងវិស័យដទៃទៀតដែលបានកំណត់ដោយក្រុមប្រឹក្សា AFTA ។

**មាត្រា ៤៧.- គោលការណ៍ស្តីពីការសម្របសម្រួលពាណិជ្ជកម្ម**

សមាជិកត្រូវបានណែនាំទៅតាមគោលការណ៍ខាងក្រោមពាក់ព័ន្ធទៅនឹងវិធានការ និងគំនិតផ្តួចផ្តើមសម្របសម្រួលពាណិជ្ជកម្មទាំងកម្រិតអាស៊ាន និងកម្រិតជាតិ :

(ក) តម្លាភាព ព័ត៌មានស្តីពីគោលនយោបាយ ច្បាប់ បទបញ្ញា វិធានរដ្ឋបាល អាជ្ញាបណ្ណ វិញ្ញាបនបត្រ លក្ខណៈសម្បត្តិ និងតម្រូវការចុះបញ្ជី បទបញ្ញាបច្ចេកទេស ស្តង់ដារ ការណែនាំ នីតិវិធី និងគោលនយោបាយពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មទំនិញ (ដែលហៅថា វិធាន និងនីតិវិធីពាក់ព័ន្ធពាណិជ្ជកម្ម) ត្រូវធ្វើឱ្យរកបានសម្រាប់ភាគីចំណាប់អារម្មណ៍ទាំងអស់ ប្រកបដោយសង្គតភាព និងទាន់ពេលវេលាដោយមិនចំណាយ ឬចំណាយក្នុងតម្លៃសមហេតុផល ។

(ខ) ទំនាក់ទំនង និងការពិគ្រោះយោបល់ : អាជ្ញាធរទាំងអស់ត្រូវព្យាយាមសម្របសម្រួល និងលើកកម្ពស់យន្តការ ,ប្រសិទ្ធិភាពសម្រាប់ផ្លាស់ប្តូរពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម រួមទាំងឱកាសសម្រាប់ពិគ្រោះយោបល់នៅពេលបង្កើតអនុវត្ត រំលឹកឡើងវិញនូវវិធាន និងនីតិវិធីពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម ។

(គ) ការធ្វើឱ្យងាយស្រួល ភាពជាក់ស្តែងបាន និងប្រសិទ្ធិភាពល្អ : វិធាន និង នីតិវិធីដែលពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មត្រូវធ្វើឱ្យងាយស្រួល ដើម្បីប្រាដកថា វាមិនមានភាពស្មុគស្មាញ ឬដាក់កម្រិតជាងការចាំបាច់ដើម្បីទៅសម្រេចគោលបំណងស្របច្បាប់របស់ពួកវា ។

(ឃ) ការមិនរើសអើង : វិធាន និងនីតិវិធីពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មត្រូវអនុវត្ត ដោយមិនមានការរើសអើង និងត្រូវមានមូលដ្ឋានគោលការណ៍ទីផ្សារ ។

(ង)សង្គតភាព និងការព្យាករណ៍ : វិធាន និងនីតិវិធីពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មត្រូវអនុវត្តឱ្យបានស៊ីសង្វាក់ ព្យាករណ៍បាន និងមានទម្រង់ដូចដែលទាំងនេះអាចកាត់បន្ថយភាពមិនប្រាកដនៃពាណិជ្ជកម្មបណ្តាភាគីដលពាក់ព័ន្ធ។ វិធាន និងនីតិវិធីពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មត្រូវផ្តល់ឱ្យច្បាស់លាស់ និងត្រឹមត្រូវពីនីតិវិធីណែនាំទៅអាជ្ញាធរជាមួយនឹងស្តង់ដារគោលនយោបាយ និងនីតិវិធីប្រតិបត្តិ និងការអនុវត្តដោយមិនមានការរើសអើង ។

(ច) សុខដុមនីយកម្ម ស្តង់ដារ និងការទទួលស្គាល់ : នៅពេលដែលទទួលយកតម្រូវការរបស់សមាជិកនីមួយៗ ដើម្បីធ្វើការរៀបរយ ឬបង្កើតវិធានសម្រាប់គោលបំណងស្របច្បាប់ដូចជាការការពារសុខភាព សុវត្ថិភាព ឬសីលធម៌សាធារណៈ និងការអភិរក្សធនធានធម្មជាតិដែលស្ទើរតែបាត់បង់ បទបញ្ជា វិធានការ និងនីតិវិធីដែលប៉ះពាល់ដល់ទំនិញរវាងសមាជិក ត្រូវតែធ្វើឱ្យមានសុខដុមនីយកម្មដូចដែលអាចធ្វើទៅបានដោយនៅលើមូលដ្ឋាននៃស្តង់ដារអន្តរជាតិដែលសមរម្យ ។ ការអភិវឌ្ឍស្តីពីការរៀបចំទទួលស្គាល់គ្នាទៅវិញទៅមកសម្រាប់ស្តង់ដារ លទ្ធផលវាយតម្លៃអនុលោមភាព និងបន្តសហប្រតិបត្តិការលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសត្រូវតែជំរុញការលើកទឹកចិត្ត ។

(ឆ) ទំនើបកម្ម និងការប្រើបច្ចេកវិទ្យាថ្មី : វិធាន និងនីតិវិធីពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មត្រូវរំលឹកឡើងវិញ និងធ្វើឱ្យបច្ចុប្បន្នភាពប្រសិនបើចាំបាច់ ដោយយកចិត្តទុកដាក់ទៅលើហេតុការណ៍ដែលបានផ្លាស់ប្តូរ រួមបញ្ចូលទាំងព័ត៌មានថ្មីៗ និងការអនុវត្តន៍ពាណិជ្ជកម្មថ្មីៗ ដោយផ្តោតលើការអនុម័តដែលសមរម្យនៃវិធីសាស្ត្រទំនើប និងបច្ចេកវិទ្យាថ្មី ។ ទីណាដែលបច្ចេកវិទ្យាថ្មីត្រូវបានប្រើប្រាស់អាជ្ញាធរពាក់ព័ន្ធត្រូវខិតខំប្រឹងប្រែង ដើម្បីផ្សាយលើកតម្លៃផលប្រយោជន៍ទៅសមាជិកទាំងអស់តាមរយៈការបើកចំហរនៃព័ត៌មានស្តីពីបច្ចេកវិទ្យាដែលបានអនុម័ត និងពង្រីកសហប្រតិបត្តិការទៅអាជ្ញាធរនៃសេដ្ឋកិច្ចដទៃ និងវិស័យឯកជន ក្នុងការបង្កើតការប្រតិបត្តិទៅវិញទៅមក និង/ឬការផ្សារភ្ជាប់ទៅវិញទៅមកនៃបច្ចេកវិទ្យា ។

(ជ) ដំណើរការកំណត់ពេល : ការចូលទៅដល់នីតិវិធីច្បាប់ធ្វើឧទ្ធរណ៍ ដោយបន្ថែមឱ្យច្រើនជាងភាពប្រាកដនិយម ចំពោះការផ្លាស់ប្តូរពាណិជ្ជកម្ម ដោយអនុលោមទៅតាមច្បាប់ដែលអាចអនុវត្តបានរបស់សមាជិក និង ។

(ឈ) សហប្រតិបត្តិការ ៖ សមាជិកត្រូវខិតខំធ្វើការងារឱ្យបានជិតដិតជាមួយវិស័យឯកជននៅក្នុងការឧទ្ទេសនាមវិធានការដែលអំណោយផលសម្រាប់ការសម្របសម្រួលពាណិជ្ជកម្ម រួមទាំងការបើកប្រព័ន្ធទំនាក់ទំនង និងសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងពាណិជ្ជកម្មទាំងពីរ។ សមាជិកត្រូវបន្តធ្វើការងារជាដៃគូដើម្បីផ្តោតទៅលើឱកាសសម្រាប់បង្កើនសហប្រតិបត្តិការ រួមទាំងសមាហរណកម្មជំនួយបច្ចេកទេស និងការកសាងសមត្ថភាព ផ្លាស់ប្តូរនូវការអនុវត្តល្អក្នុងការអនុវត្តគំនិតផ្តួចផ្តើមសម្របសម្រួលពាណិជ្ជកម្ម សហប្រតិបត្តិការលើគោលជំហរពាក់ព័ន្ធទៅនឹងប្រធានបទដែលមានផលប្រយោជន៍រួមដែលបានពិភាក្សានៅក្នុងក្របខ័ណ្ឌតំបន់ និងអង្គការអន្តរជាតិ។

## មាត្រា ៤៨.- ការត្រួតពិនិត្យវឌ្ឍនភាពនៃការសម្របសម្រួលពាណិជ្ជកម្ម

១. សមាជិករៀងខ្លួនៗ ត្រូវធ្វើការវាយតម្លៃរៀងៗ ខ្លួន និងរួមគ្នាមួយដងក្នុងរយៈពេលពីរ (២) ឆ្នាំលើការអនុវត្តវិធានការសម្របសម្រួលពាណិជ្ជកម្មដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ និងនៅក្នុងកម្មវិធីការងារសម្របសម្រួលពាណិជ្ជកម្មអាស៊ាន ដើម្បីធានានូវប្រសិទ្ធិភាពអនុវត្តវិធានការសម្របសម្រួលពាណិជ្ជកម្ម។ សម្រាប់គោលបំណងនេះ ក្របខ័ណ្ឌសម្របសម្រួលពាណិជ្ជកម្មអាស៊ានត្រូវព្រមព្រៀងដោយសមាជិក ក្នុងកំឡុងប្រាំមួយ (៦) ខែ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ត្រូវបម្រើការណែនាំដើម្បីធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនូវការសម្របសម្រួលពាណិជ្ជកម្មអាស៊ាន។

២. កម្មវិធីការងារអាស៊ានស្តីពីការសម្របសម្រួលពាណិជ្ជកម្មត្រូវពិនិត្យឡើងវិញ ដោយឈរលើមូលដ្ឋានលទ្ធផលនៃការវាយតម្លៃជាប្រចាំអនុលោមទៅតាមកថាខណ្ឌ ១ នៃមាត្រានេះ។ កម្មវិធីការងារសម្របសម្រួលពាណិជ្ជកម្មអាស៊ាន និងក្របខ័ណ្ឌសម្របសម្រួលពាណិជ្ជកម្មអាស៊ាន និងការពិនិត្យមើលសារឡើងវិញណាមួយរបស់វា ត្រូវតែជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ និងបម្រើជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ៤៩.- ការបង្កើតច្រកចេញចូលតែមួយរបស់អាស៊ាន

សមាជិកត្រូវយកចិត្តទុកដាក់លើវិធានការចាំបាច់ដើម្បីបង្កើត និងប្រតិបត្តិច្រកចេញចូលតែមួយថ្នាក់ជាតិរបស់គេ និងច្រកចេញចូលតែមួយរបស់អាស៊ានដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនៃការបង្កើត និងអនុវត្តច្រកចេញចូលតែមួយអាស៊ាន និងពិធីសារស្តីពីការបង្កើត និងអនុវត្តច្រកចេញចូលតែមួយអាស៊ាន។

**មាត្រា ៥០.- ការរៀបចំការអនុវត្ត**

១. ដំណើរការក្នុងការអនុវត្តកម្មវិធីការងារអាស៊ានស្តីពីការសម្របសម្រួលពាណិជ្ជកម្ម និង លទ្ធផលនៃការវាយតម្លៃរបស់វាត្រូវតែរាយការណ៍ទៅក្រុមប្រឹក្សា AFTA។ ឧត្តមមន្ត្រីសេដ្ឋកិច្ចដែលជួយ ដោយគណៈកម្មាធិការសម្របសម្រួលស្តីពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ត្រូវតែជា អ្នកសម្របសម្រួលចម្បង នៅក្នុងការត្រួតពិនិត្យដំណើរការរីកចម្រើននៃការអនុវត្តកម្មវិធីការងារអាស៊ាន ស្តីពីការសម្របសម្រួលពាណិជ្ជកម្ម ដោយសហការជិតស្និទ្ធជាមួយគណៈកម្មាធិការអាស៊ានផ្សេងៗ ទៀតក្នុង ការទទួលបន្ទុកអនុវត្តវិធានការនៅក្រោមកម្មវិធីការងារ។

២. សមាជិកនីមួយៗ ត្រូវបង្កើតគណៈកម្មាធិការសម្របសម្រួលសម្រាប់សម្របសម្រួលពាណិជ្ជកម្ម ឬចំណុចទំនាក់ទំនងពាក់ព័ន្ធកម្រិតជាតិ។

## ជំពូកទី ៦

## គយ

**មាត្រា ៥១.- គោលបំណង**

គោលបំណងនៃជំពូកនេះគឺ :

(ក) ធានានូវការព្យាករណ៍បាន សង្គតភាព និងតម្លាភាពនៅក្នុងបែបបទនៃច្បាប់គយរបស់ សមាជិក។

(ខ) ជំរុញការគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធិភាព និងសន្សំសំចៃស្តីពីនីតិវិធីគយ និងការ សម្អាតទំនិញយ៉ាងរហ័ស។

(គ) ធ្វើឱ្យងាយស្រួល និងសុដុមនីយភាពនូវនីតិវិធីគយ និងការអនុវត្តនាក់ស្តែងទៅតាម លទ្ធភាពដែលអាច និង។

(ឃ) ជំរុញសហប្រតិបត្តិការរវាងអាជ្ញាធរគយ។

**មាត្រា ៥២.- និយមន័យ**

សម្រាប់គោលនៃជំពូកនេះ :

(ក) **ប្រតិបត្តិករសេដ្ឋកិច្ចដែលត្រូវបានផ្តល់សិទ្ធិ** មានន័យថា ភាគីដែលបានចូលរួមក្នុងចរាចរទំនិញអន្តរជាតិ នៅក្នុងមុខងារដែលបានអនុញ្ញាតដោយអាជ្ញាធរគយដោយប្រតិបត្តិតាមតម្រូវការលក្ខន្តិកៈ និង/ឬបទបញ្ជារបស់សមាជិក ដោយយកចិត្តទុកដាក់ទៅលើស្តង់ដារសន្តិសុខផ្គត់ផ្គង់។

(ខ) **ការត្រួតពិនិត្យគយ** មានន័យថា វិធានការដែលបានអនុវត្តដោយអាជ្ញាធរគយ ដើម្បីធានាការអនុវត្តច្បាប់គយរបស់សមាជិក។

(គ) **នីតិវិធីគយ** មានន័យថា ប្រព្រឹត្តិកម្មដែលបានអនុវត្តដោយអាជ្ញាធរគយនៃសមាជិកនីមួយៗទៅនឹងទំនិញដែលជាទិសដៅសម្រាប់ច្បាប់គយ។

(ឃ) **កិច្ចព្រមព្រៀងវាយតម្លៃគយ** មានន័យថាកិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធ និងពាណិជ្ជកម្ម ១៩៩៤ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១ A របស់កិច្ចព្រមព្រៀង WTO។

(ង) **ការដកត្រឡប់** មានន័យថា ចំនួនពន្ធនាំចូល និងពន្ធអាករសងត្រឡប់វិញក្រោមនីតិវិធីដកត្រឡប់វិញ។

(ច) **នីតិវិធីដកត្រឡប់** មានន័យថា នីតិវិធីគយពេលដែលទំនិញត្រូវបាននាំចេញ ដោយផ្តល់ថាការសងត្រឡប់វិញ (ទាំងស្រុង ឬផ្នែកណាមួយ) ដែលបានធ្វើដោយគោរពទៅតាមការបង់ពន្ធនាំចូល និងពន្ធអាករលើចំណុះទំនិញ ឬលើវត្ថុធាតុ ឬបានប្រើប្រាស់នៅក្នុងការផលិត។

(ឆ) **ប្រកាសទំនិញ** មានន័យថា ជាសេចក្តីថ្លែងការណ៍ដែលបានធ្វើដោយប្រកាន់តាមវិធីរបស់អាជ្ញាធរគយ ដែលបុគ្គលពាក់ព័ន្ធបង្ហាញប្រាប់នីតិវិធីគយដែលត្រូវអនុវត្តចំពោះទំនិញ និងរបស់របរប្រើប្រាស់ដោយឡែកដែលអាជ្ញាធរគយតម្រូវចំពោះការអនុវត្ត។

(ជ) **ការសងត្រឡប់** មានន័យថា ឱ្យប្រាក់មកវិញទាំងស្រុង ឬផ្នែកណាមួយនៃពន្ធនាំចូល និងពន្ធអាករដែលចំណាយលើទំនិញ និងការអត់ឱនទាំងស្រុង ឬផ្នែកណាមួយនៃពន្ធនាំចូល និងពន្ធអាករទីណាដែលការចំណាយមិនទាន់បានធ្វើ។

(ឈ) **សន្តិសុខ** មានន័យថា អ្វីដែលធានានូវការពេញចិត្តនៃអាជ្ញាធរគយ នោះជាកាតព្វកិច្ចដែលអាជ្ញាធរគយនឹងត្រូវបានបំពេញ និង។

(ញ) **ការអនុញ្ញាតឱ្យចូលបណ្តោះអាសន្ន** មានន័យថា នីតិវិធីគយចំពោះទំនិញដែលនាំចូលមកក្នុងដែនដីគយដែលមានល័ក្ខខ័ណ្ឌទទួលរងទាំងស្រុង ឬផ្នែកណាមួយពីការបង់ពន្ធនាំចូល និងពន្ធអាករទំនិញទាំងនោះត្រូវបាននាំចូលសម្រាប់តែគោលបំណងជាក់លាក់ និងត្រូវនាំចេញទៅវិញក្នុងកំឡុង

ដែលបានបញ្ជាក់ និងមិនឆ្លងកាត់ការផ្លាស់ប្តូរ លើកលែងតែរំលស់ធម្មតាដែលបានពីការប្រើប្រាស់ពួកវា។

**មាត្រា ៥៣.- ទំហំ**

ជំពូកនេះ អនុវត្តដោយអនុលោមទៅតាមច្បាប់ បទបញ្ជា និងគោលនយោបាយរបស់សមាជិកទៅលើនីតិវិធីគយ ដែលបានអនុវត្តចំពោះទំនិញដែលបានធ្វើពាណិជ្ជកម្មក្នុងចំណោមសមាជិក។

**មាត្រា ៥៤.- នីតិវិធីគយ និង ការត្រួតពិនិត្យ**

១. សមាជិកនីមួយៗ ត្រូវធានាថា នីតិវិធីគយ និងការអនុវត្តរបស់វាអាចព្យាករបាន ដោយមានសង្គតភាព តម្លាភាព និងសម្របសម្រួលពាណិជ្ជកម្ម រួមបញ្ចូលទាំងតាមរយៈការសំអាតទំនិញយ៉ាងរហ័ស។

២. នីតិវិធីគយរបស់សមាជិកត្រូវ ដែលអាចទៅបាន និងត្រូវបានអនុញ្ញាតដោយច្បាប់គយរបស់គេ អនុលោម ទៅតាមស្តង់ដារ និងការអនុវត្តដែលបានផ្តល់ដោយអង្គការគយពិភពលោក និងអង្គការអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធទៅនឹងគយ។

៣. អាជ្ញាធរគយរបស់សមាជិកនីមួយៗ ត្រូវរំលឹកឡើងវិញពីនីតិវិធីគយរបស់ខ្លួនក្នុងគំនិតធ្វើឱ្យងាយស្រួល ដល់ការសម្របសម្រួលពាណិជ្ជកម្ម។

៤. ការត្រួតពិនិត្យគយត្រូវមានដែនកំណត់ទៅតាមការចាំបាច់ ដើម្បីធានាការអនុវត្តតាមច្បាប់គយរបស់សមាជិក។

**មាត្រា ៥៥.- ឯកសារមុនមកដល់**

សមាជិកត្រូវខិតខំប្រឹងប្រែងធ្វើបទប្បញ្ញត្តិសម្រាប់កន្លែងស្នាក់អាស្រ័យ និងចុះបញ្ជី ឬត្រួតពិនិត្យប្រកាសទំនិញ និងឯកសារគាំទ្រមុនពេលដែលទំនិញមកដល់។

**មាត្រា ៥៦.- ការគ្រប់គ្រងហានិភ័យ**

សមាជិកត្រូវការគ្រប់គ្រងហានិភ័យ ដើម្បីកំណត់វិធានការត្រួតពិនិត្យក្នុងគំនិត ដើម្បីសម្របសម្រួល សម្អាតគយ និងបញ្ចេញទំនិញ។

**មាត្រា ៥៧.- វាយតម្លៃគយ**

១. សម្រាប់គោលបំណងនៃការកំណត់តម្លៃគយចំពោះទំនិញដែលបានធ្វើពាណិជ្ជកម្មរវាង និងក្នុងចំណោមសមាជិក បទប្បញ្ញត្តិនៃផ្នែក I នៃកិច្ចព្រមព្រៀងវាយតម្លៃគយ ត្រូវអនុវត្ត *ដូចដែលបានកែប្រែ*[7] ។

២. សមាជិកត្រូវធ្វើឱ្យសុដុមនីយកម្ម តាមលទ្ធភាពដែលអាចទៅបាននូវនីតិវិធីរដ្ឋបាល និងការអនុវត្តក្នុងការវាយតម្លៃ តម្លៃនៃទំនិញសម្រាប់គោលបំណងគយ ។

**មាត្រា ៥៨.- បែបបទនៃព័ត៌មានបច្ចេកវិទ្យា**

សមាជិក ពេលដែលអាចទៅបាន ត្រូវអនុវត្តព័ត៌មានបច្ចេកវិទ្យានៅក្នុងការប្រតិបត្តិគយ ដោយឈរលើមូលដ្ឋានស្តង់ដារដែលទទួលស្គាល់ជាអន្តរជាតិសម្រាប់ការសំអាតគយ និងបញ្ចេញទំនិញឱ្យរហ័ស ។

**មាត្រា ៥៩.- ប្រតិបត្តិករសេដ្ឋកិច្ចដែលត្រូវបានផ្តល់សិទ្ធិ**

១. សមាជិកត្រូវខិតខំប្រឹងប្រែងបង្កើតកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចដែលបានផ្តល់សិទ្ធិ (AEO) ដើម្បីជំរុញការអនុវត្ត និងប្រសិទ្ធិភាពនៃការត្រួតពិនិត្យគយ ។

២. សមាជិកត្រូវខិតខំប្រឹងប្រែង ធ្វើការងារដើម្បីឈានទៅរកការទទួលស្គាល់ទៅវិញទៅមកនៃប្រតិបត្តិករសេដ្ឋកិច្ចដែលបានផ្តល់សិទ្ធិ ។

**មាត្រា ៦០.- ការសងត្រឡប់វិញ ការដកហូតវិញ និងសន្តិសុខ**

១. ការសម្រេចលើការទាមទារសម្រាប់ការសងត្រឡប់វិញត្រូវតែអាចឈានដល់ និងបានជូនព័ត៌មានជាលាយល័ក្ខអក្សរទៅបុគ្គលពាក់ព័ន្ធ ដោយមិនមានការពន្យារ និងការសងត្រឡប់វិញនូវចំនួនដែលបានបង់លើសត្រូវធ្វើឱ្យបានកាន់តែឆាប់ បន្ទាប់ពីការចុះត្រួតពិនិត្យនៃការទាមទារ ។

២. ការដកហូតវិញត្រូវតែបានចំណាយឱ្យបានឆាប់ បន្ទាប់ពីការចុះត្រួតពិនិត្យនៃការទាមទារ ។

៣. ទីណាដែលសន្តិសុខត្រូវបានផ្តល់ វាត្រូវបានបន្ធូរបន្ថយឱ្យបានឆាប់រហ័សបន្ទាប់ពីអាជ្ញាធរគយពេញចិត្តថាកាតព្វកិច្ចដែលសន្តិសុខតម្រូវត្រូវបានបំពេញ ។

---

[៧] ក្នុងករណីរបស់កម្ពុជា កិច្ចព្រមព្រៀងស្តីពីវាយតម្លៃគយ ដូចដែលបានអនុវត្តអនុលោមទៅតាមបទប្បញ្ញត្តិនៃពិធីសារស្តីពីការបញ្ចូលរាជាណាចក្រកម្ពុជាទៅ WTO ត្រូវអនុវត្ត *ដូចដែលបានកែប្រែ*

**មាត្រា ៦១.- សវនកម្មសម្អាតតាមក្រោយ**

សមាជិកត្រូវបង្កើត និងប្រតិបត្តិសវនកម្មសំអាតតាមក្រោម (PCA) សម្រាប់ការសម្អាតគយឱ្យបានរហ័ស និងបង្កើនការត្រួតពិនិត្យ ។

**មាត្រា ៦២.- វិធានទៅមុន**

១. សមាជិកនីមួយៗ តាមរយៈអាជ្ញាធរគយរបស់វា និង/ឬអាជ្ញាធរពាក់ព័ន្ធត្រូវពង្រីកការអនុញ្ញាតទៅតាមច្បាប់ បទបញ្ជា ការកំណត់រដ្ឋបាល ផ្តល់ជាលាយល័ក្ខអក្សរនូវវិធានទៅមុនលើបែបទរបស់បុគ្គលដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ ២ (ក) នៃមាត្រានេះ ដោយគោរពទៅតាមការចាត់ចំណាត់ថ្នាក់ពន្ធគយ សំណួរដែលលើកឡើងពីបែបបទនៃគោលការណ៍កិច្ចព្រមព្រៀងវាយតម្លៃគយ និង/ឬដើមកំណើតទំនិញ ។

២. ទីណាដែលអាចរកបាន សមាជិកនីមួយៗ ត្រូវអនុម័ត ឬរក្សានីតិវិធីសម្រាប់វិធានទៅមុនដែលត្រូវ :

(ក) ផ្តល់ថាអ្នកនាំចូលនៅក្នុងដែនដីរបស់វា ឬអ្នកនាំចេញ ឬអ្នកផលិតនៅក្នុងដែនដីរបស់សមាជិកដទៃអាចអនុវត្តវិធានទៅមុន មុនពេលដែលនាំចូលទំនិញដែលចោទសំណួរ ។

(ខ) ដោយតម្រូវថាបេក្ខជនសម្រាប់វិធានទៅមុនផ្តល់នូវការរៀបរាប់លំអិតអំពីទំនិញ និងព័ត៌មាន ពាក់ព័ន្ធដែលចាំបាច់សម្រាប់ដំណើរការបែបបទវិធានទៅមុន ។

(គ) អាជ្ញាធរគយរបស់វាអាច នៅក្នុងពេលណាក៏ដោយនៅក្នុងដំណាក់កាលនៃការវាយតម្លៃបែបបទសម្រាប់វិធានទៅមុន ស្នើសុំឱ្យបេក្ខជនផ្តល់ព័ត៌មានបន្ថែមក្នុងកំឡុងពេលវេលាដែលបានបញ្ជាក់ ។

(ឃ) វិធានទៅមុនណាមួយត្រូវមានមូលដ្ឋានជាក់ស្តែង និងហេតុការណ៍ដែលបានបង្ហាញដោយបេក្ខជន និងព័ត៌មានពាក់ព័ន្ធដទៃណាមួយនៅក្នុងនាមជាអ្នកធ្វើការសម្រេចចិត្ត និង ។

(ង) វិធានទៅមុនអាចចេញទៅឱ្យបេក្ខជនយ៉ាងរហ័ស ក្នុងកំឡុងពេលដែលបានបញ្ជាក់ដោយច្បាប់ បទបញ្ជា ឬការកំណត់រដ្ឋបាលរបស់សមាជិកនីមួយៗ ។

៣. សមាជិកមួយអាចបដិសេធនូវការស្នើសុំសម្រាប់វិធានទៅមុននៅពេលដែលព័ត៌មានបន្ថែមដែលបានស្នើ អនុលោមទៅតាមកថាខ័ណ្ឌ ២ (គ) នៃមាត្រានេះមិនត្រូវបានផ្តល់ក្នុងកំឡុងពេលវេលា ដែលបានកំណត់ ។

៤. ជាទិសដៅសម្រាប់កថាខណ្ឌ ១ និង ៥ នៃមាត្រានេះ និងទីណាដែលអាចរកបានសមាជិកនីមួយៗ ត្រូវអនុវត្តវិធានទៅមុនចំពោះរាល់ការនាំចូលទំនិញដែលមានរៀបរាប់នៅក្នុងវិធានដែលបាននាំចូលទៅក្នុងដែនដីរបស់វាសម្រាប់បី (៣) ឆ្នាំ ពីកាលបរិច្ឆេទនៃវិធាននោះ ឬរយៈពេលផ្សេងទៀតទាំងនោះ ដែលបានកំណត់នៅក្នុងច្បាប់ បទបញ្ជា ឬការកំណត់រដ្ឋបាលរបស់សមាជិកនោះ ។

៥. សមាជិកអាចធ្វើការកែប្រែ ឬលុបចោលវិធានទៅមុនពេលដែលកំណត់ថា វិធាននោះបានឈរលើមូលដ្ឋានកំហុសឆ្គងទៅតាមការពិតជាក់ស្តែង ឬច្បាប់ (ដែលរួមទាំងកំហុសមនុស្ស) ព័ត៌មានដែលបានផ្តល់ខុសខាន ឬមិនច្បាស់លាស់ មានការផ្លាស់ប្តូរនៅក្នុងច្បាប់ដែលមានស្រាប់នៅក្នុងកិច្ចព្រមព្រៀងនេះ ឬមានការផ្លាស់ប្តូរនៅក្នុងវត្ថុធាតុជាក់ស្តែង ឬហេតុការណ៍ដែលវិធាននេះមានមូលដ្ឋានលើ ។

៦. ទីណាដែលអ្នកនាំចេញទាមទារថា ប្រព្រឹត្តិកម្មដែលបានឱ្យចំពោះទំនិញដែលបាននាំចូលត្រូវតែគ្រប់គ្រងដោយវិធានទៅមុន អាជ្ញាធរគយអាចវាយតម្លៃការពិតជាក់ស្តែង និងហេតុការណ៍នៃការនាំចូលមានសង្គតភាពជាមួយនឹងការពិតជាក់ស្តែង និងហេតុការណ៍នៅពេលដែលវិធានទៅមុនមានមូលដ្ឋានលើ ។

**មាត្រា ៦៣.- ការអនុញ្ញាតឱ្យចូលបណ្តោះអាសន្ន**

សមាជិកត្រូវសម្របសម្រួលចរាចរទំនិញ ក្រោមការអនុញ្ញាតឱ្យចូលបណ្តោះអាសន្នឱ្យបានកាន់តែច្រើនដូចដែលអាចទៅបាន ។

**មាត្រា ៦៤.- សហប្រតិបត្តិការគយ**

ដោយមានការអនុញ្ញាតដោយច្បាប់របស់គេ សមាជិកអាចជួយគ្នាលើបញ្ហាគយ តាមការសមស្រប ។

**មាត្រា ៦៥.- តម្លាភាព**

១. សមាជិកត្រូវសម្របសម្រួលធ្វើការបោះពុម្ពឱ្យទាន់ពេលវេលា ផ្សព្វផ្សាយព័ត៌មានពីលក្ខន្តិកៈ និងបទបញ្ជា សេចក្តីសម្រេច និងវិធានស្តីពីបញ្ហាគយ ។

២. សមាជិកត្រូវផ្សព្វផ្សាយនៅលើអ៊ីនធឺណែត និង/ឬបោះពុម្ពបទប្បញ្ញត្តិលក្ខន្តិកៈ និងបទបញ្ជា និងនីតិវិធី រដ្ឋបាលគយដែលមាន ឬការបង្គាប់ដោយរដ្ឋបាលគយរបស់វា លើកលែងតែនីតិវិធីការប្រតិបត្តិច្បាប់ និងការណែនាំប្រតិបត្តិការផ្ទៃក្នុង ។

**មាត្រា ៦៦.- ចំណុចទំនាក់ទំនងព័ត៌មាន**

សមាជិកនីមួយៗ ត្រូវជ្រើសតាំងមួយ (១) ឬច្រើនចំណុចទំនាក់ទំនងព័ត៌មានដើម្បីជាអាស័យដ្ឋានសម្រាប់បុគ្គលដែលមានចំណាប់អារម្មណ៍ពាក់ព័ន្ធទៅនឹងបញ្ហាគយ និងត្រូវធ្វើឱ្យមាននៅលើអ៊ីនធឺណែត និង/ឬ បោះពុម្ពព័ត៌មានពាក់ព័ន្ធទៅនឹងនីតិវិធីសម្រាប់ការធ្វើការទំនាក់ទំនងទាំងនោះ ។

**មាត្រា ៦៧.- ការពិគ្រោះ**

អាជ្ញាធរគយរបស់សមាជិកត្រូវជំរុញការពិគ្រោះយោបល់ជាមួយគ្នា ទាក់ទងទៅនឹងបញ្ហាគយដែលប៉ះពាល់ពាណិជ្ជកម្មទំនិញរវាង និងក្នុងចំណោមសមាជិក ។

**មាត្រា ៦៨.- ការសម្ងាត់**

១. គ្មានអ្វីនៅក្នុងជំពូកនេះ ត្រូវបានបកស្រាយក្នុងការស្នើសុំឱ្យសមាជិកបង្ហាញ ឬអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានសម្ងាត់អនុលោមទៅតាមជំពូកនេះ ដែលការបង្ហាញទាំងនោះពិចារណាថា :

(ក) ផ្ទុយទៅនឹងចំណាប់អារម្មណ៍សាធារណៈ ដូចដែលបានកំណត់ដោយច្បាប់ ។

(ខ) ផ្ទុយទៅនឹងច្បាប់ណាមួយ រួមមាន ប៉ុន្តែមិនកម្រិតចំពោះការការពារបុគ្គលឯកជន ឬទំនាក់ទំនងហិរញ្ញវត្ថុ និងគណនីនៃបុគ្គលអតិថិជនរបស់ស្ថាប័នហិរញ្ញវត្ថុ ។

(គ) រារាំងដល់ការអនុវត្តច្បាប់ ។

(ឃ) វិនិច្ឆ័យប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់ ដែលអាចរួមមានជំហរប្រកួតប្រជែង ។

២. ទីណាដែលសមាជិកមួយផ្តល់ព័ត៌មានទៅសមាជិកដទៃ ដូចដែលអនុញ្ញាតនៅក្រោមជំពូកនេះ និងចាត់ព័ត៌មាននោះថាសម្ងាត់ សមាជិកដែលទទួលព័ត៌មានត្រូវរក្សាការសម្ងាត់នៃព័ត៌មាន ដោយប្រើប្រាស់វាសម្រាប់តែគោលបំណងដែលបានបញ្ជាក់ដោយសមាជិកផ្តល់ព័ត៌មាន និងមិនត្រូវបង្ហាញដោយគ្មានការអនុញ្ញាតជាលាយល័ក្ខអក្សរដោយសមាជិកផ្តល់ព័ត៌មាន ។

**មាត្រា ៦៩.- ការពិនិត្យឡើងវិញ និង ការទិនិច្ឆ័យ**

១. សមាជិកនីមួយៗ ត្រូវធ្វើឱ្យប្រាកដថា បុគ្គលណាមួយក្នុងដែនដីរបស់វា ដែលធ្វើឱ្យពិបាកដោយសេចក្តីសម្រេចគយសមហេតុផលណាមួយទៅនឹងកិច្ចព្រមព្រៀងនេះ ដែលចូលទៅដល់ការរំលឹកឡើងវិញនៃការគ្រប់គ្រងក្នុងអាជ្ញាធរគយដែលបានចេញសេចក្តីសម្រេចក្នុងគោលបំណងពិនិត្យឡើងវិញ ឬទីណាដែល

អាច ដោយអាជ្ញាធរណែនាំខ្ពស់ជាងគ្រប់គ្រង និង/ឬវិនិច្ឆ័យរំលឹកឡើងវិញនៃការកំណត់យកនៅកម្រិតចុងក្រោយ នៃវិនិច្ឆ័យពិនិត្យឡើងវិញ ដែលអនុញ្ញាតដោយច្បាប់សមាជិក ។

២. សេចក្តីសម្រេចលើការវិនិច្ឆ័យត្រូវផ្តល់ទៅអ្នកឧទ្ធរណ៍ និងមូលហេតុនៃកាសម្រេចទាំងនោះជាលាយល័ក្ខអក្សរ ។

**មាត្រា ៧០.- ការរៀបចំការអនុវត្ត និង ស្ថាប័ន**

អគ្គនាយកគយអាស៊ាន គាំទ្រដោយក្រុមការងារគយត្រូវទទួលបន្ទុកក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ បទប្បញ្ញត្តិដទៃណាមួយដែលពាក់ព័ន្ធទៅនឹងគយ ក្នុងកិច្ចព្រមព្រៀងនេះ ។

## ជំពូកទី ៧
## ស្តង់ដារ បទបញ្ជាបច្ចេកទេស និង នីតិវិធីវាយតម្លៃអនុលោមភាព

**មាត្រា ៧១.- គោលបំណង**

គោលបំណងនៃជំពូកនេះ គឺបង្កើតបទប្បញ្ញត្តិស្តីពី ស្តង់ដារ បទបញ្ជាបច្ចេកទេស និងនីតិវិធីវាយតម្លៃ អនុលោមភាព ដើម្បីឱ្យប្រាកដថាទាំងនោះមិនបង្កើតឱ្យមានឧបសគ្គមិនចាំបាច់ទៅនឹងពាណិជ្ជកម្មក្នុងការបង្កើតទីផ្សារអាស៊ានតែមួយ និងមូលដ្ឋានផលិតកម្ម និងក្នុងពេលដំណាលគ្នានេះដែរ ធានាថាឆ្លើយតបទៅនឹងគោលបំណងស្របច្បាប់របស់សមាជិក ។

**មាត្រា ៧២.- ពាក្យ និង និយមន័យ**

ពាក្យទូទៅដែលពាក់ព័ន្ធទៅនឹង ស្តង់ដារ និងការវាយតម្លៃអនុលោមភាពដែលបានប្រើប្រាស់នៅក្នុងជំពូកនេះ មានអត្ថន័យដែលបានផ្តល់ ដែលរួមមានការកែសមរម្យនៃ ISO/IEC ការណែនាំ ២ និង ISO/IEC ១៧000 នៃអង្គការអន្តរជាតិស្តីពីស្តង់ដារ (ISO) និងគណៈកម្មការអេឡិចត្រូនិចអន្តរជាតិ (IEC) ដែល បានដកស្រង់នៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការរៀបចំទទួលស្គាល់ទៅវិញទៅមក និងការរៀបចំទទួលស្គាល់ទៅវិញទៅមកនូវវិស័យនីមួយៗ របស់អាស៊ាន ។

## មាត្រា ៧៣.~ បទប្បញ្ញត្តិទូទៅ

១. សមាជិកដែលបានបញ្ជាក់ជាថ្មី និងបានសន្យាគោរពតាមសិទ្ធិ និងកាតព្វកិច្ចក្រោម កិច្ចព្រមព្រៀង ស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្ម ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១ A នៃ កិច្ចព្រមព្រៀង WTO ។

២. សមាជិកត្រូវប្រើប្រាស់វិធានការណាមួយដែលអាច និងបញ្ចូលគ្នាដើម្បីបន្ធូរ ប្រសិនបើមិនទាន់ លុបចោលទាំងស្រុងនូវរបាំងបច្ចេកទេសមិនចាំបាច់ទៅនឹងពាណិជ្ជកម្ម :

(ក) សុខដុមភាពស្តង់ដារជាតិ ដែលពាក់ព័ន្ធទៅនឹងស្តង់ដារអន្តរជាតិ និងការអនុវត្តជាក់ស្តែង ។

(ខ) ជំរុញការទទួលស្គាល់ទៅវិញទៅមកពីលទ្ធផលវាយតម្លៃអនុលោមភាពក្នុងចំណោម សមាជិក ។

(គ) អភិវឌ្ឍ និងអនុវត្តការរៀបចំទទួលស្គាល់ទៅវិញទៅមកវិស័យអាស៊ាន និងអភិវឌ្ឍរបប បទបញ្ញសុខដុមភាពអាស៊ានក្នុងការធ្វើឱ្យរៀបរយវិស័យណាដែលអាចអនុវត្តបាន ។

(ឃ) ជំរុញលើកទឹកចិត្តសហប្រតិបត្តិការក្នុងចំណោមស្ថាប័នទទួលស្គាល់គុណភាពជាតិ និង វិទ្យាស្ថានមាត្រសាស្ត្រជាតិ (NMIs) រួមទាំងអាជ្ញាធរមាត្រសាស្ត្រស្របច្បាប់ពាក់ព័ន្ធនៅក្នុង អាស៊ាន ដើម្បីជំរុញការអនុវត្តនៃការរៀបចំទទួលស្គាល់គ្នាទៅវិញទៅមក (MRAs) ក្នុងវិស័យ រៀបរយ និងមិនរៀបរយ ។

៣. ដើម្បីសម្របសម្រួលលំហូរចូលដោយសេរីនៃទំនិញរវាងអាស៊ាន សមាជិកត្រូវអភិវឌ្ឍ និង អនុវត្តកម្មវិធីធ្វើដែលសមរម្យសម្រាប់ផលិតផលដែលគ្របដណ្តប់ក្រោមរបបបទបញ្ញសុខដុមភាព ឬសេចក្តី បង្គាប់របស់អាស៊ាន ។

## មាត្រា ៧៤.~ ស្តង់ដារ

១. សមាជិកនីមួយៗ ត្រូវទទួលរ៉ាប់រងថា អាជ្ញាធរស្តង់ដារជាតិរបស់ខ្លួនត្រូវទទួលស្គាល់ និងធ្វើ តាម Code of Good Practice for Preparation ការអនុម័ត និងបែបបទស្តង់ដារដែលមានចែងនៅក្នុង ឧបសម្ព័ន្ធ ៣ នៃកិច្ចព្រមព្រៀង WTO ។

២. នៅក្នុងការធ្វើសុខដុមភាពស្តង់ដារជាតិ សមាជិកត្រូវជាជម្រើស និងការចង់បានដំបូង អនុម័ត ស្តង់ដារ អន្តរជាតិពាក់ព័ន្ធ នៅពេលដែលរៀបចំស្តង់ដារជាតិថ្មី ឬសើរើឡើងវិញនូវស្តង់ដារដែលមានស្រាប់ ។ ទីណា ដែលស្តង់ដារអន្តជាតិ មិនអាចរកបាន ស្តង់ដារជាតិត្រូវរៀបជាជួរក្នុងចំណោមសមាជិក ។

៣. សមាជិកត្រូវបានលើកទឹកចិត្តចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍស្តង់ដារអន្តរជាតិ ដោយឡែកចំពោះវិស័យដែលជាអាទិភាពពាណិជ្ជកម្មសម្រាប់អាស៊ាន ។

៤. សុខដុមាភាពស្តង់ដារជាតិដែលមានស្រាប់ និងការអនុម័តស្តង់ដារអន្តរជាតិទៅក្នុងស្តង់ដារជាតិថ្មី ត្រូវតែមានមូលដ្ឋានស្តីពី "ការអនុម័តស្តង់ដារអន្តរជាតិជាស្តង់ដារតំបន់ ឬស្តង់ដារជាតិ" ដូចដែលមានរៀបរាប់នៅក្នុង ISO/IEC ការណែនាំ ២១ ឬការកែប្រែចុងក្រោយរបស់វា ។

៥. ដរាបណាមានចាំបាច់ក្នុងការកែប្រែមាតិកា និងរចនាសម្ព័ន្ធនៃស្តង់ដារអន្តរជាតិពាក់ព័ន្ធសមាជិកត្រូវធានាថា ការប្រៀបធៀបងាយស្រួលនៃមាតិកា និងរចនាសម្ព័ន្ធនៃស្តង់ដារជាតិជាមួយ និងឯកសារយោងស្តង់ដារអន្តរជាតិ នឹងផ្តល់ព័ត៌មានដើម្បីពន្យល់ពីមូលហេតុនៃការកែប្រែ ។

៦. សមាជិកត្រូវធានា :

(ក) ការកែប្រែមាតិកានៃស្តង់ដារអន្តរជាតិមិនត្រូវបានរៀបចំ និងអនុម័តក្នុងគំនិត ឬជាមួយនឹងការប៉ះពាល់នៃការបង្កើតភាពមិនចាំបាច់របាំងបច្ចេកទេសពាណិជ្ជកម្ម និង ។

(ខ) ការកែប្រែមាតិកាមិនត្រូវដាក់កម្រិតជាងការចាំបាច់ ។

**មាត្រា ៧៥.- បទបញ្ជាបច្ចេកទេស**

១. ក្នុងការអនុម័តបទបញ្ជាបច្ចេកទេស សមាជិកត្រូវធានាថា :

(ក) ទាំងនេះមិនមែនអនុម័តក្នុងគំនិតទៅនឹង ឬជាមួយនឹងការប៉ះពាល់នៃការបង្កើតរបាំងបច្ចេកទេសពាណិជ្ជកម្ម ។

(ខ) ទាំងនេះមានមូលដ្ឋានលើស្តង់ដារអន្តរជាតិ ឬជាតិដែលបានសុដុមភាពស្តង់ដារអន្តរជាតិ លើកលែងតែទីណាដែលមូលហេតុស្របច្បាប់សម្រាប់សម្រាប់ការបំបែរចេញកើតមាន ។

(គ) មធ្យោបាយផ្សេងទៀតដែលដាក់កម្រិតពាណិជ្ជកម្មតិចតួចដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់ទុកគឺបានពិចារណាមុនពេលសម្រេចក្នុងការអនុម័តបទបញ្ជាបច្ចេកទេស ។

(ឃ) ការអនុម័តស្តង់ដារបញ្ញត្តិ គឺជៀសវាងដើម្បីធានាឧបសគ្គដែលមិនចាំបាច់សម្រាប់ពាណិជ្ជកម្មមិនត្រូវបានបង្កើត សំដៅធ្វើឱ្យប្រសើរឡើងការប្រកួតប្រជែងដោយយុត្តិធម៌នៅលើទីផ្សារ ឬវាមិននាំឱ្យមានការកាត់បន្ថយភាពទន់ភ្លន់ពាណិជ្ជកម្ម និង ។

(ង) ប្រព្រឹត្តិកម្មទៅតាមផលិតផលដែលបាននាំចូលពីសមាជិក គឺមិនមានអនុគ្រោះតិចជាងទៅនឹងផលិតផលដូចដែលមានដើមកំណើតជាតិ និងចំពោះផលិតផលដូចមានដើមកំណើតពីសមាជិកដទៃណាមួយ។

២. សមាជិកត្រូវប្រាកដថាមានតែផ្នែកទាំងនោះទេនៃស្តង់ដារមួយដែលតំណាងឱ្យការទាមទារអប្បបរមា ដើម្បីបំពេញគោលដៅដែលបានកំណត់ ដូចដែលមាននៅក្នុងបទបញ្ញាបច្ចេកទេស។

៣. សមាជិកត្រូវធានាថា ទីណាក៏ដោយដែលមានការរៀបចំ អនុម័ត និងបែបបទនៃបទបញ្ញាពាណិជ្ជកម្ម គឺដើម្បីសម្របសម្រួលដល់ការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមកតាមវិស័យរបស់អាស៊ាន។

៤. នៅពេលដែលមានតម្រូវការបទបញ្ញាបច្ចេកទេសជាបន្ទាន់ ដើម្បីជំនះលើបញ្ហាដែលកើតឡើង និងគំរាមកំហែងដែលនឹងកើតឡើងនៅក្នុងដែនដីសមាជិក និងពេលវេលាមិនបានផ្តល់ឱ្យគ្រប់គ្រាន់ឱ្យសមាជិកនោះធ្វើសុខដុមភាពស្តង់ដារជាតិពាក់ព័ន្ធ សមាជិកនោះត្រូវពិចារណាប្រើស្តង់ដារអន្តរជាតិសមរម្យ ឬផ្នែកពាក់ព័ន្ធជាជម្រើសដំបូង។

៥. សមាជិកត្រូវប្រព្រឹត្តតាមនីតិវិធីជូនព័ត៌មានដែលបានបញ្ជាក់នៅក្នុងមាត្រា ១១។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីបទបញ្ញាបច្ចេកទេសក្រោមមាត្រានេះ សមាជិកដទៃត្រូវបង្ហាញយោបល់ប្រសិនបើមានក្នុងកំឡុងហុកសិប (៦០) ថ្ងៃ នៃការជូនព័ត៌មាន។ សមាជិកនៅពេលដែលមានការស្នើសុំផ្តល់ទៅសមាជិកដទៃនូវសេចក្តីព្រាងបទបញ្ញាបច្ចេកទេស និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធទៅនឹងការបែចេញពីស្តង់ដារ អន្តរជាតិពាក់ព័ន្ធ និងនីតិវិធីវាយតម្លៃអនុលោមភាព Pre-market ដែលអាចរកបាន។

៦. លើកលែងនៅក្នុងហេតុការណ៍បន្ទាន់ សមាជិកត្រូវបានផ្តល់យ៉ាងតិចប្រាំមួយ (៦) ខែនៅចន្លោះពេលផ្សព្វផ្សាយបទបញ្ញាបច្ចេកទេស និងការចូលជាធរមានដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ សម្រាប់អ្នកផលិតនៅក្នុងសមាជិកនាំចេញដើម្បីតម្រូវផលិតផល និងការផលិតទៅតាមការទាមទាររបស់សមាជិកនាំចូល។

**មាត្រា ៧៦.- នីតិវិធីវាយតម្លៃអនុលោមភាព**

១. សមាជិកត្រូវប្រាកដថា នីតិវិធីវាយតម្លៃអនុលោមភាពមិនត្រូវបានរៀបចំ អនុម័ត ឬអនុវត្តក្នុងគំនិតថា ឬជាមួយនឹងការប៉ះពាល់នៃការបង្កើតភាពមិនចាំបាច់ទៅនឹងរបាំងបច្ចេកទេសពាណិជ្ជកម្ម និង

នីតិវិធីវាយ តម្លៃអនុលោមភាពនោះត្រូវតែប្រព្រឹត្តតាមជាមួយអ្នកផ្គត់ផ្គង់ផលិតផលដើមកំណើតនៅក្នុងដែនដីសមាជិកដទៃ គឺមិនត្រូវតឹងតែងជាងអ្នកផ្គត់ផ្គង់ផលិតផល ដូចដែលមានដើមកំណើតជាតិទេ ។

២. សមាជិកត្រូវអនុម័តនីតិវិធីវាយតម្លៃអនុលោមភាពដែលមានសង្គតភាពជាមួយស្តង់ដារ និងការអនុវត្តអន្តរជាតិ និងពេលណាក៏ដោយ នីតិវិធីទាំងនោះមិនអាចសម្រេចបានពីព្រោះ គោលបំណងស្របច្បាប់ខុសគ្នា ភាពខុសគ្នានៃនីតិវិធីវាយតម្លៃអនុលោមភាពត្រូវតែធ្វើឱ្យបានតិចតួច ដូចដែលអាចធ្វើទៅបាន ។

៣. សមាជិកត្រូវអភិវឌ្ឍ និងអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកតាមវិស័យរបស់អាស៊ាននៅក្នុងវិស័យបទបញ្ជា ទីណាដែលសមរម្យ អនុលោមទៅតាមបទប្បញ្ញត្តិកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការរៀបចំទទួលស្គាល់ទៅវិញទៅមក ។

៤. សមាជិកត្រូវទទួលយកលទ្ធផលនៃការវាយតម្លៃអនុលោមភាពផលិតដោយស្ថាប័នវាយតម្លៃអនុលោមភាពចាត់តាំងដោយសមាជិកដទៃ អនុលោមទៅតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការរៀបចំទទួលស្គាល់គ្នាទៅវិញទៅមក និងបទប្បញ្ញត្តិនៃការរៀបចំទទួលស្គាល់គ្នាទៅវិញទៅមកតាមវិស័យ របស់អាស៊ាននីមួយៗ នៅគ្រប់វិស័យបទបញ្ជា ។

៥. សមាជិកត្រូវបង្កើតការសហប្រតិបត្តិការក្នុងចំណោមស្ថាប័នទទួលស្គាល់គុណភាពជាតិ និងវិទ្យាស្ថាន មាត្រសាស្ត្រជាតិ (NMIs) រួមទាំងច្បាប់មាត្រសាស្ត្រនៅក្នុងអាស៊ានដើម្បីសម្របសម្រួលដល់ការអនុវត្ត MRAs ចំពោះវិស័យបទបញ្ជា និងមិនមែនបទបញ្ជា ។

**មាត្រា ៧៧.- ទីផ្សារពិនិត្យមើលជាមុន**

១. សមាជិកត្រូវបង្កើតប្រព័ន្ធទីផ្សារពិនិត្យមើលជាមុនដើម្បីបន្ថែមលើការអនុវត្តការរៀបចំទទួលស្គាល់ទៅវិញទៅមកវិស័យអាស៊ាន និងរបប និង/ឬការណែនាំបទបញ្ជាសុដុមភាពអាស៊ាន ។

២. អាជ្ញាធរពាក់ព័ន្ធដែលទទួលធ្វើប្រព័ន្ធទីផ្សារពិនិត្យមើលជាមុនរបស់សមាជិក ត្រូវចាប់យកសកម្មភាពចាំបាច់ដើម្បីធានាការប្រព្រឹត្តិនៃផលិតផលដែលដាក់នៅលើទីផ្សារទៅតាមការរៀបចំទទួលស្គាល់ទៅវិញទៅមកវិស័យអាស៊ាន និងរបប និង/ឬការណែនាំបទបញ្ជាសុដុមភាពអាស៊ាន ។

៣. សមាជិកត្រូវធានាថា ច្បាប់ចាំបាច់ និងហេដ្ឋារចនាបច្ចេកទេសត្រូវមាន ដើម្បីគាំទ្រប្រព័ន្ធទីផ្សារពិនិត្យមើលជាមុន ។

៤. ប្រសិទ្ធិភាពនៃប្រព័ន្ធទីផ្សារពិនិត្យមើលជាមុនត្រូវតែពង្រឹងបន្ថែមទៀតតាមរយៈការបង្កើតប្រព័ន្ធប្រយ័ត្នប្រយែងក្នុងចំណោមសមាជិកអាស៊ាន ។

**មាត្រា ៧៨.- ការអនុវត្ត**

១. សមាជិកត្រូវចាប់យកវិធានការចាំបាច់ទាំងអស់ដើម្បីធានាការអនុវត្តការរៀបចំទទួលស្គាល់ទៅវិញទៅមកវិស័យអាស៊ាន និងរបបបទបញ្ជាសុដុមភាពអាស៊ាន និងបទប្បញ្ញត្តិពាក់ព័ន្ធកិច្ចព្រមព្រៀងនេះ នៅក្នុងកំឡុងពេលដែលមាននៅក្នុងកិច្ចព្រមព្រៀងដែលបានរៀបរាប់ និងដើម្បីភាពប្រាកដនៃការប្រព្រឹត្តិទៅតាមការទាមទារសុដុមភាពដែលបានរៀបរាប់រួច ។

២. បរិធានខាងក្រោម និងបរិធានណាមួយនាពេលអនាគតដែលបានឯកភាពដោយសមាជិក ដើម្បីអនុវត្ត បណ្តាបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវតែផ្គុំជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ :

(ក) កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីការរៀបចំទទួលស្គាល់ទៅវិញទៅមក ។

(ខ) ការរៀបចំទទួលស្គាល់ទៅវិញទៅមកវិស័យអាស៊ានសម្រាប់បរិក្ខារដើរដោយអគ្គិសនី និងអគ្គិសនី ។

(គ) កិច្ចព្រមព្រៀងស្តីពីរបបបទបញ្ជាសុដុមភាពអាស៊ានសម្រាប់បរិក្ខារដើរដោយអគ្គិសនី និងអគ្គិសនី ។

(ឃ) កិច្ចព្រមព្រៀងស្តីពីកម្មវិធីបទបញ្ជាគ្រឿងសំអាងសុដុមភាពអាស៊ាន ។

៣. គណៈកម្មាធិការពិគ្រោះយោបល់របស់អាស៊ានសម្រាប់ស្តង់ដារ និង គុណភាព (ACCSQ) ត្រូវទទួលខុសត្រូវចំពោះ:

(ក) កំណត់សម្គាល់ និង បញ្ចូលវិស័យ MRAs ។

(ខ) ត្រួតពិនិត្យប្រសិទ្ធិភាពនៃការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ដោយគោរពទៅតាមស្តង់ដារ បទបញ្ជាបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព ។

(គ) ផ្តល់ការគាំទ្រទៅដល់គណៈកម្មាធិការវិស័យរួម នៅពេលដែលតម្រូវ និង ។

(ឃ) សហការជាមួយលេខាធិការដ្ឋានអាស៊ាន ដើម្បីផ្តល់ព័ត៌មានត្រឡប់ជាប្រចាំស្តីពីការអនុវត្តកិច្ចព្រមព្រៀងនេះ ។

៤. ACCSQ ត្រូវផ្តល់ការគាំទ្រ និងសហប្រតិបត្តិការក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានពាក់ព័ន្ធ (FTAs) ជាមួយដៃគូពាណិជ្ជកម្ម រួមទាំងការកសាងសមត្ថភាព និងកម្មវិធីពង្រឹងស្ថាប័នសម្រាប់ជំពូក ស្តង់ដារ បទបញ្ជាបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពនៅក្នុងពាណិជ្ជកម្មសេរីអាស៊ានទាំងនោះ ។

៥. ACCSQ ត្រូវចាប់យកសកម្មភាពចាំបាច់ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធិភាពរបស់ការរៀបចំទទួលស្គាល់ទៅវិញទៅមកវិស័យអាស៊ាន និងរបបបទបញ្ញាសុដុមភាពអាស៊ាន ។

## ជំពូកទី ៨
## វិធានការអនាម័យ និង ភូតគាមអនាម័យ

### មាត្រា ៧៩.- គោលបំណង

គោលបំណងនៃជំពូកនេះគឺ :

(ក) សម្របសម្រួលពាណិជ្ជកម្មរវាង និងក្នុងចំណោមសមាជិក នៅពេលដែលកំពុងការពារមនុស្ស សត្វ រុក្ខជាតិមានជីវិត ឬសុខភាព នៅក្នុងសមាជិកនីមួយៗ ។

(ខ) ផ្តល់ក្របខ័ណ្ឌ និងការណែនាំទៅតាមតម្រូវការនៅក្នុងបែបបទនៃវិធានការអនាម័យ និងភូតគាមអនាម័យក្នុងចំណោមសមាជិក ដោយឡែកដើម្បីសម្រេចការសន្យាដែលមានចែងនៅក្នុងផែនការសមាគមសេដ្ឋកិច្ចអាស៊ាន ។

(គ) ពង្រឹងសហប្រតិបត្តិការក្នុងចំណោមសមាជិកដើម្បីការពារមនុស្ស សត្វ រុក្ខជាតិមានជីវិត ឬសុខភាព និង ។

(ង) សម្របសម្រួល និងពង្រឹងការអនុវត្តនៃជំពូកនេះ ទៅតាមគោលការណ៍ និងវិន័យនៅក្នុង *កិច្ចព្រមព្រៀងស្តីពីបែបបទនៃវិធានការអនាម័យ និងភូតគាមអនាម័យ* ដែលមាននៅក្នុងឧបសម្ព័ន្ធ ១ A ទៅនឹងកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងនេះ ។

### មាត្រា ៨០.- និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ :

(ក) **ស្តង់ដារអន្តរជាតិ ការណែនាំ និងអនុសាសន៍** ត្រូវមានអត្ថន័យដូចគ្នាទៅនឹង ឧបសម្ព័ន្ធ A នៃកថាខណ្ឌ ៣ របស់កិច្ចព្រមព្រៀង SPS ។

(ខ) **វិធានការអនាម័យ ឬភូតគាមអនាម័យ** ត្រូវមានអត្ថន័យដូចគ្នាទៅនឹងឧបសម្ព័ន្ធ A នៃកថាខណ្ឌ ១ របស់កិច្ចព្រមព្រៀង SPS និង ។

(គ) **កិច្ចព្រមព្រៀង** SPS មានន័យថា កិច្ចព្រមព្រៀងស្តីពីបែបបទនៃវិធានការអនាម័យ និងភូតគាមអនាម័យ ដែលមាននៅក្នុងឧបសម្ព័ន្ធ ១ A របស់កិច្ចព្រមព្រៀង WTO ។

**មាត្រា ៨១.- បទប្បញ្ញត្តិទូទៅ និង ភាតព្វកិច្ច**

១. បទប្បញ្ញត្តិនៃជំពូកនេះអនុវត្តចំពោះវិធានការអនាម័យ និងភូតគាមអនាម័យនៃសមាជិកដែលអាចប៉ះពាល់ផ្ទាល់ ឬប្រយោលដល់ពាណិជ្ជកម្មរវាង និងក្នុងចំណោមសមាជិក ។

២. សមាជិកបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ចដោយគោរពទៅតាមសមាជិកដទៃក្រោមកិច្ចព្រមព្រៀង SPS ។

៣. សមាជិកនីមួយៗ សន្យាអនុវត្តគោលការណ៍នៃកិច្ចព្រមព្រៀង SPS ក្នុងការអភិវឌ្ឍបែបបទ ឬទទួលស្គាល់វិធានការអនាម័យ និងភូតគាមអនាម័យណាមួយក្នុងគោលដៅសម្របសម្រួលពាណិជ្ជកម្មរវាង និងក្នុងចំណោមសមាជិកនៅពេលដែលមានការពារមនុស្ស សត្វ រុក្ខជាតិមានជីវិត ឬសុខភាពនៅក្នុងសមាជិកនោះ ។

៤. នៅក្នុងការអនុវត្តវិធានការអនាម័យ និងភូតគាមអនាម័យរបស់គេ សមាជិកភាពត្រូវតែណែនាំអ្វីដែលអាចអនុវត្តបាន ដោយស្តង់ដារអន្តរជាតិពាក់ព័ន្ធ ការណែនាំ និងអនុសាសន៍ដែលបានបង្កើតដោយអង្គការអន្តរជាតិដូចជា Codex Alimentarius Commission (Codex) អង្គការពិភពលោកសម្រាប់សុខភាពសត្វ (OIE) សន្ធិសញ្ញាការពាររុក្ខជាតិអន្តរជាតិ (IPPC) និងអាស៊ាន ។

៥. សមាជិក តាមរយៈនេះ ព្រមព្រៀងថា ច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់បែបបទនៃវិធានការ SPS នៅក្នុងដែនដីរបស់ពួកគេត្រូវដែលរៀបរាប់នៅឧបសម្ព័ន្ធ ៩ ដែលចូលរួមជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។ សមាជិក តាមរយៈនេះ ព្រមព្រៀងដើម្បីប្រាកដថាច្បាប់អនាម័យ និងភូតគាមអនាម័យ បទបញ្ជា និង នីតិវិធីក្នុងស្រុក ដូចដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ៩ ដែលមានរួចជាស្រេច អាចរកបាន និងចូលប្រើប្រាស់បានដោយសមាជិកដែលចាប់អារម្មណ៍ ។

៦. ការកែប្រែណាមួយទៅនឹងច្បាប់អនាម័យ និងភូតគាមអនាម័យ បទបញ្ជា និងនីតិវិធីក្នុងស្រុកត្រូវតែជាកម្មវត្ថុនៃមាត្រា ១១ ។

**មាត្រា ៨២.- ការអនុវត្ត និង ការរៀបចំស្ថាប័ន**

១. ដើម្បីប្រសិទ្ធិភាពនៃការអនុវត្តជំពូកនេះ គណៈកម្មាធិការអាស៊ានស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ (AC-SPS) ត្រូវបង្កើតដើម្បីរៀបចំកិច្ចប្រជុំគណៈកម្មាធិការយ៉ាងតិចមួយឆ្នាំម្តងក្នុងចំណោមសមាជិក។

២. មុខងារនៃ AC-SPS ត្រូវ :

(ក) សម្របសម្រួលផ្លាស់ប្តូរព័ត៌មានលើបញ្ហាទាំងនោះដែលកើតមានឡើងពីអនាម័យ ឬភូតគាមអនាម័យនៅក្នុងសមាជិក និងមិនមែនសមាជិក និងផ្លាស់ប្តូរ ឬឧទ្ទេសនាមបទបញ្ជា និងស្តង់ដែលពាក់ព័ន្ធទៅនឹងអនាម័យ និងភូតគាមអនាម័យនៃសមាជិក ដែលអាចប៉ះពាល់ដោយផ្ទាល់ ឬប្រយោលដល់ពាណិជ្ជកម្មរវាង និងក្នុងចំណោមសមាជិក។

(ខ) សម្របសម្រួលសហប្រតិបត្តិការនៅក្នុងវិស័យវិធានការអនាម័យ និងភូតគាមអនាម័យរួមទាំងការកសាងសមត្ថភាព ជំនួយបច្ចេកទេស និងផ្លាស់ប្តូរអ្នកជំនាញ ដោយផ្អែកលើហិរញ្ញវត្ថុសមរម្យដែលមាន និងច្បាប់ និងបទបញ្ជាដែលមាននៃសមាជិកនីមួយៗ។

(គ) បើអាចទៅបាន រាល់ដំណោះស្រាយបញ្ហាអនាម័យ និងភូតគាមអនាម័យ ក្នុងគំនិតសម្របសម្រួលពាណិជ្ជកម្មរវាង និងក្នុងចំណោមសមាជិក។ AC-SPS អាចបង្កើតក្រុមការងារសម្រាប់ពិគ្រោះមូលដ្ឋានវិទ្យាសាស្ត្រ ដើម្បីរកឱ្យឃើញ និងដោះស្រាយបញ្ហាដោយឡែកដែលអាចកើតឡើងពីបែបបទវិធានការអនាម័យ ឬភូតគាមអនាម័យ និង។

(ឃ) ផ្តល់របាយការណ៍ជាប្រចាំនៃការអភិវឌ្ឍ និងអនុសាសន៍ក្នុងការអនុវត្តជំពូកនេះទៅក្រុមប្រឹក្សា AFTA តាមរយៈ SEOM សម្រាប់សកម្មភាពបន្ត។

៣. សមាជិកនីមួយៗ ត្រូវបង្កើតចំណុចទំនាក់ទំនងសម្រាប់ប្រសិទ្ធិភាពទំនាក់ទំនង និងសហប្រតិបត្តិការ។ បញ្ជីចំណុចទំនាក់ទំនងដែលបានចាត់តាំងបង្ហាញនៅក្នុងឧបសម្ព័ន្ធ ១០។

៤. សមាជិកនីមួយៗ ត្រូវធានាថាព័ត៌មានដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១០ ត្រូវតែធ្វើឱ្យបច្ចុប្បន្នភាព។

**មាត្រា ៨៣.- ការជូនព័ត៌មានក្រោមស្ថានភាពបន្ទាន់**

១. សមាជិកនីមួយៗ ត្រូវទទួលស្គាល់តម្លៃនៃការផ្លាស់ប្តូរព័ត៌មាន ដោយឡែកក្នុងករណីបន្ទាន់ស្តីពី វិបត្តិ សុវត្ថិភាពម្ហូបអាហារ របាំង ការត្រួតពិនិត្យជម្ងឺប៉េស និង/ឬការកើតមានឡើងនៃជម្ងឺ និងវិធានការ អនាម័យ និងភូតគាមអនាម័យរបស់វា។

២. សមាជិកត្រូវប្រញាប់ជូនព័ត៌មានទៅចំណុចទំនាក់ទំនងទាំងអស់ និងលេខាធិការដ្ឋានអាស៊ាន ពេលដែល ស្ថានភាពខាងក្រោមកើតឡើង :

(ក) ក្នុងករណីដែលវិបត្តិសុវត្ថិភាពម្ហូបអាហារ ជម្ងឺប៉េស ឬការកើតមានឡើងនៃជម្ងឺ និង។

(ខ) វិធានការអនាម័យ ឬភូតគាមអនាម័យប្រឆាំង និងប៉ះពាល់ដល់ការនាំចេញ សមាជិកដទៃ ត្រូវបានពិចារណាជាចាំបាច់ដើម្បីការពារមនុស្ស សត្វ ឬរុក្ខជាតិមានជីវិត ឬសុខភាពរបស់សមាជិក នាំចូល។

៣. សមាជិកនាំចេញត្រូវផ្តល់ព័ត៌មានតាមលទ្ធភាពដែលអាចទៅបាន បើអាចទៅសមាជិកនាំចូល ប្រសិនបើសមាជិកនាំចេញរកឃើញថា ទំនិញដែលបាននាំចេញអាចមានពាក់ព័ន្ធសំខាន់ទៅនឹងហានិភ័យ អនាម័យ និងភូតគាមអនាម័យ។

**មាត្រា ៨៤.- សមមូលភាព**

១. សមាជិកនីមួយៗ ត្រូវបញ្ចូលថ្មី និងពង្រឹងសហប្រតិបត្តិការបន្ថែមលើសមមូលភាពទៅតាមកិច្ច ព្រមព្រៀង SPS និងស្តង់ដារអន្តរជាតិ ការណែនាំ និងអនុសាសន៍ដែលពាក់ព័ន្ធ ដើម្បីសម្របសម្រួល ពាណិជ្ជកម្មរវាង និងក្នុងចំណោមសមាជិក។

២. ដើម្បីសម្របសម្រួលពាណិជ្ជកម្ម សមាជិកអាចអភិវឌ្ឍការរៀបចំសមមូលភាព និងផ្តល់ យោបល់សេចក្តីសម្រេចសមមូលភាព ដោយឡែកទៅតាមមាត្រា ៤ នៃកិច្ចព្រមព្រៀង SPS និងទៅតាម ការណែនាំ ដែលបានផ្តល់ដោយស្ថាប័នស្តង់ដារអន្តរជាតិ និងតំបន់ពាក់ព័ន្ធដែលមានឈ្មោះថា Codex, OIE, IPPC និង អាស៊ាន និងដោយគណៈកម្មាធិការស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យដែលបានបង្កើត ទៅតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង SPS ។

**មាត្រា ៨៥.‿ សហប្រតិបត្តិការ**

១. សមាជិកនីមួយៗ ត្រូវផ្តល់ឱកាសសម្រាប់សហប្រតិបត្តិការបន្ថែម ជំនួយបច្ចេកទេស សហការ និងផ្លាស់ប្តូរព័ត៌មានជាមួយសមាជិកដទៃស្តីពីបញ្ហាអនាម័យ និងភូតគាមអនាម័យនៃចំណាប់អារម្មណ៍ទៅវិញទៅមក សង្គតភាពជាមួយនឹងគោលបំណងនៃជំពូកនេះ និងការសន្យាដែលមានចែងនៅក្នុងផែនការសមាគមសេដ្ឋកិច្ចអាស៊ាន។

២. សមាជិកត្រូវពង្រឹងសហប្រតិបត្តិការបន្ថែមសម្រាប់ត្រួតពិនិត្យ និងបំបាត់ជម្ងឺប៉េស និងជម្ងឺផ្សេងៗ ដែលកើតមានឡើង និងករណីបន្ទាន់ផ្សេងទៀតពាក់ព័ន្ធទៅនឹងវិធានការអនាម័យ ឬភូតគាមអនាម័យ ក៏ដូចជាការជួយសមាជិកដទៃឱ្យប្រព្រឹត្តទៅតាមកិច្ចព្រមព្រៀង SPS ។

៣. ក្នុងការអនុវត្តបទប្បញ្ញត្តិកថាខណ្ឌ ១ នៃមាត្រានេះសមាជិកត្រូវសម្របសម្រួលការងារសកម្មភាពរបស់គេដែលបានបង្កើតឡើងនៅក្នុងបរិបទតំបន់ និងពហុភាគី ក្នុងគោលដៅជៀសវាងការត្រួតលើគ្នាដែលមិនចាំបាច់ និងធ្វើឱ្យអតិបរមាលទ្ធផលល្អនៃការខិតខំប្រឹងប្រែងរបស់សមាជិកនៅក្នុងវិស័យនេះ។

៤. សមាជិកពីរ (២) ណាមួយអាច តាមការព្រមព្រៀងទៅវិញទៅមក សហប្រតិបត្តិការលើការអនុម័តល័ក្ខខ័ណ្ឌតំបន់រួមទាំងទស្សនះពីជម្ងឺប៉េស និងតំបន់ដែលមិនមានជម្ងឺ និងតំបន់ដែលមានជម្ងឺប៉េសទាប ឬជម្ងឺច្រើនលើសលប់ ទៅតាមកិច្ចព្រមព្រៀង SPS និងស្តង់ដារអន្តរជាតិ ការណែនាំ និងអនុសាសន៍ពាក់ព័ន្ធ ដើម្បីសម្របសម្រួលពាណិជ្ជកម្មរវាងសមាជិក។

## ជំពូកទី ៩
## វិធានការកែប្រែផលប៉ះពាល់ពាណិជ្ជកម្ម

**មាត្រា ៨៦.‿ វិធានការការពារ**

សមាជិកនីមួយៗ ដែលជាសមាជិក WTO រក្សាសិទ្ធិ និងកាតព្វកិច្ចក្រោមមាត្រា XIX នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីវិធានការការពារ ឬមាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម។

**មាត្រា ៨៧.~ ភារកិច្ច Anti-dumping និង ប៉ះប៉ូវ**

១. សមាជិកបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ចដោយគោរពគ្នាទៅវិញទៅមកពាក់ព័ន្ធទៅនឹងបែបបទនៃ Anti-Dumping ក្រោមមាត្រា VI នៃ GATT ១៩៩៤ និង *កិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍មាត្រា* VI *កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤* ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១A របស់កិច្ចព្រមព្រៀង WTO ។

២. សមាជិកបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ចដោយគោរពគ្នាទៅវិញទៅមកពាក់ព័ន្ធទៅនឹងវិធានការឧបត្ថម្ភ និងប៉ះប៉ូវក្រោមមាត្រា XVI នៃ GATT ១៩៩៤ និង *កិច្ចព្រមព្រៀងស្តីពីវិធានការឧបត្ថម្ភធន និងប៉ះប៉ូវ* ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១A របស់កិច្ចព្រមព្រៀង WTO ។

## ជំពូកទី ១០
## បទប្បញ្ញត្តិរៀបចំស្ថាប័ន

**មាត្រា ៨៨.~ យន្តការណែនាំ និង ពិគ្រោះ**

ការពិគ្រោះអាស៊ានសម្រាប់ដោះស្រាយពាណិជ្ជកម្ម និងបញ្ហាវិនិយោគ (ACT) និងស្ថាប័នត្រួតពិនិត្យការប្រព្រឹត្តតាម (ACB) ដែលមានចែងនៅក្នុងសេចក្តីប្រកាសស្តីពី *ASEAN Concord II (Bali Concord II)* អាចត្រូវបានសំអាងលើដើម្បីដោះស្រាយវិវាទដែលអាចកើតឡើងពីកិច្ចព្រមព្រៀងនេះ។ សមាជិកណាមួយដែលជាអ្នកមិនមានបំណងប្រើប្រាស់ ACT/ACB អាចឧបាស្រ័យទៅលើយន្តការដែលបានផ្តល់នៅក្នុង *ពិធីសារអាស៊ានស្តីពីយន្តការធ្វើឱ្យប្រសើរឡើងនូវការដោះស្រាយវិវាទ*។

**មាត្រា ៨៩.~ ដោះស្រាយវិវាទ**

ពិធីសារអាស៊ានស្តីពីយន្តការធ្វើឱ្យប្រសើរឡើងនូវការដោះស្រាយវិវាទ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ និងការកែប្រែទាំងនោះ ត្រូវអនុវត្តចំពោះវិវាទដែលកើតឡើងពី ឬភាពខុសគ្នារវាងសមាជិក ដែលពាក់ព័ន្ធទៅនឹងការបកស្រាយ ឬការអនុវត្តនៃកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៩០.- ការរៀបចំស្ថាប័ន**

១. រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) ត្រូវ ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ បង្កើតក្រុមប្រឹក្សាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ( AFTA) ដោយរួមមាន ការជ្រើសរើសកម្រិតរដ្ឋមន្ត្រីមួយ (១) រូប ពីសមាជិកនីមួយៗ និងអគ្គលេខាធិការអាស៊ាន។ នៅក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន ក្រុមប្រឹក្សា AFTA ត្រូវគាំទ្រដោយកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ច (SEOM)។ ដើម្បីបំពេញមុខងារ SEOM អាចបង្កើតស្ថាប័នទៅតាមការសមរម្យ ដើម្បីជួយពួកគេដូចជា គណៈកម្មាធិការសម្របសម្រួលស្តីពីការអនុវត្ត ATIGA (CCA)។ SEOM ក្រោមការជ្រោមជ្រែងដោយ CCA ត្រូវធានានូវប្រសិទ្ធិភាពអនុវត្តកិច្ចព្រមព្រៀងនេះ និងត្រូវសម្របសម្រួល និងគាំទ្រដោយស្ថាប័នបច្ចេកទេសបណ្តាគណៈកម្មាធិការក្រោមកិច្ចព្រមព្រៀងនេះ។

២. សមាជិកនីមួយៗ ត្រូវបង្កើតស្ថាប័នជាតិ AFTA ដែលត្រូវបម្រើជាជំណុចទំនាក់ទំនងសម្រាប់សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងនេះ។

៣. លេខាធិការដ្ឋានអាស៊ានត្រូវ :

(ក) ផ្តល់ការគាំទ្រទៅ AEM និងក្រុមប្រឹក្សា AFTA ក្នុងការគ្រប់គ្រង សហប្រតិបត្តិការ និងពិនិត្យឡើងវិញការអនុវត្តកិច្ចព្រមព្រៀងនេះ ក៏ដូចជាជួយក្នុងបញ្ហាពាក់ព័ន្ធទាំងអស់ និង។

(ខ) ត្រួតពិនិត្យ និងរាយការណ៍ទៀងទាត់ទៅក្រុមប្រឹក្សា AFTA ស្តីពីភាពជឿនលឿនក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។

## ជំពូកទី ១១

## អវសានបញ្ញត្តិ

**មាត្រា ៩១.- ពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងដទៃទៀត**

១. ដោយយោងទៅលើកថាខណ្ឌ ២ នៃមាត្រានេះ កិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានទាំងអស់ ដែលមានស្រាប់ មុនពេលចូលជាធរមាននៃ ATIGA ត្រូវតែមានសុពលភាពបន្ត។

២. សមាជិកត្រូវព្រមព្រៀងលើបញ្ជីនៃកិច្ចព្រមព្រៀងជំនួសក្នុងកំឡុងប្រាំមួយ (៦) ខែពីកាលបរិច្ឆេទចូលជាធរមាន និងបញ្ជីនោះត្រូវភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ និងបម្រើជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

៣. ក្នុងករណីដែលគ្មានសង្គតភាពរវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ានណាមួយដែលមិនអាចជំនួសក្រោមកថាខណ្ឌ ២នៃមាត្រានេះ កិច្ចព្រមព្រៀងនេះត្រូវតែលប់លើ ។

**មាត្រា ៩២.- ការកែប្រែ ឬជំនួសដោយកិច្ចព្រមព្រៀងអន្តរជាតិ**

ប្រសិនបើកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ឬបទប្បញ្ញត្តិដែលចែងនៅក្នុងនោះ ឬបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀង ឬបទប្បញ្ញត្តិទាំងនោះត្រូវបានកែប្រែ សមាជិកត្រូវពិគ្រោះថាតើវាចាំបាច់ក្នុងការកែប្រែកិច្ចព្រមព្រៀងនេះ លើកលែងតែកិច្ចព្រមព្រៀងនេះចែងផ្សេងពីនេះ ។

**មាត្រា ៩៣.- ឧបសម្ព័ន្ធ ឯកសារភ្ជាប់ និងបរិធាននាពេលអនាគត**

១. ឧបសម្ព័ន្ធ និងឯកសារភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងនេះ ត្រូវផ្គុំជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ។

២. សមាជិកអាចអនុម័តបរិធានច្បាប់នៅថ្ងៃអនាគត អនុលោមទៅតាមបណ្តាបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៩៤.- វិសោធនកម្ម**

១. បណ្តាបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ អាចកែប្រែតាមរយៈការព្រមព្រៀងទៅវិញទៅមកលើវិសោធនកម្ម នៅពេលដែលមានការសរសេរជាលាយល័ក្ខអក្សរដោយសមាជិក ។

២. ថ្វីបើមានកថាខណ្ឌ ១ នៃមាត្រានេះឧបសម្ព័ន្ធ និងឯកសារភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងនេះអាចកែប្រែតាមរយៈការយល់ព្រមលើការកែប្រែដោយក្រុមប្រឹក្សា AFTA ។ វិសោធកម្មដែលពោលខាងលើត្រូវជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ និងបម្រើជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៩៥.- ការពិនិត្យឡើងវិញ**

ក្រុមប្រឹក្សា AFTA ឬតំណាងដែលបានចាត់តាំងត្រូវជួបគ្នាម្តងក្នុងមួយ (១) ឆ្នាំនៃកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងបន្ទាប់មកពីរ (២) ឆ្នាំម្តង ឬទៅតាមពេលវេលាសមរម្យដើម្បីពិនិត្យ ឡើងវិញកិច្ចព្រមព្រៀងនេះ សម្រាប់គោលបំណងបំពេញឱ្យបានទិសដៅនៃកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៩៦.- ការចូលជាធរមាន**

១. កិច្ចព្រមព្រៀងនេះត្រូវចុះហត្ថលេខា ដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន។

២. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន បន្ទាប់ពីសមាជិកទាំងអស់បានជូនព័ត៌មាន ឬទីណាដែលចាំបាច់ តម្កល់បរិធាននៃសច្ចាប័នជាមួយអគ្គលេខាធិការដ្ឋានអាស៊ាន នៅពេលដែលបញ្ចប់នីតិវិធីផ្ទៃក្នុងដែលមិនត្រូវឱ្យលើសពីមួយរយប៉ែតសិប ( ១៨០) ថ្ងៃ បន្ទាប់ពីការចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ។

៣. អគ្គលេខាធិការដ្ឋានអាស៊ានត្រូវជូនព័ត៌មានជាបន្ទាន់ដល់សមាជិកទាំងអស់ស្តីពីការជូនព័ត៌មាន និងការតម្កល់បរិធាននីមួយៗ នៃសច្ចាប័នដោយយោងទៅលើកថាខណ្ឌ ២ នៃមាត្រានេះ។

**មាត្រា ៩៧.- ការបម្រុងទុក**

គ្មានការបម្រុងទុកណាមួយត្រូវបានធ្វើឡើង ដោយគោរពទៅតាមបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ។

**មាត្រា ៩៨.- ការតម្កល់ឯកសារ**

កិច្ចព្រមព្រៀងនេះ ត្រូវបានតម្កល់នៅអគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកត្រូវបញ្ជូនជាបន្ទាន់នូវច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវមួយច្បាប់ដល់សមាជិកនីមួយៗ។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោមដែលបានទទួលសិទ្ធិប្រទានពេញលេញពីរដ្ឋាភិបាលរៀងៗ ខ្លួនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន។

**ធ្វើ**នៅ ឆាអាម ថៃឡង់ដ៍ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ជាច្បាប់ដើមតែមួយ ជាភាសាអង់គ្លេស។

សម្រាប់រដ្ឋាភិបាលប្រ៊ុយណេដារ៉ូសាឡឹម

លឹម ជក សេង

រដ្ឋមន្ត្រីទី ២ នៃក្រសួងការបរទេស និង ពាណិជ្ជកម្ម

សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

ម៉ារី អែលកា ប៉ាងហ្គីទូ
រដ្ឋមន្ត្រីពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

ណាំ វីយាកេត
រដ្ឋមន្ត្រីឧស្សាហកម្ម និង ពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលម៉ាឡេស៊ី

ម៉ូឃីឌីន ប៊ីន មហាម៉េត យេសស៊ីន
រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

ស៊ូ ថា
រដ្ឋមន្ត្រីក្រសួងផែនការជាតិ និង អភិវឌ្ឍន៍សេដ្ឋកិច្ច

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

ផីតថី ប៊ី ហ្វាវីឡា
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

លឹម ហុង គៀង
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

សម្រាប់រដ្ឋាភិបាលថៃឡង់ដ៏

ផនទីវ៉ា នាកាសៃ
រដ្ឋមន្ត្រីពាណិជ្ជកម្ម

សម្រាប់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

វ៉ូ ហ៊្វី ហ៊ុង
រដ្ឋមន្ត្រីឧស្សាហកម្ម និង ពាណិជ្ជកម្ម

(ត ទៅរាជកិច្ចលេខ ៦៨)

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៦០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សម្មានត្ថមជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន០២រូប ពីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ មកក្នុងក្របខ័ណ្ឌនគរបាលជាតិ ក្រសួងមហាផ្ទៃ និងបំពាក់ឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ដោយរក្សាឋានៈ និងមុខងារដដែល នៅក្នុងអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជូនមន្ត្រី ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ញ៉ាយ គីមលី

២- លោក នាក់ យុទ្ធា

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៨០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល
